ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- សុន្ទរកថា សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបើកសន្និសីទលើកទី១ ស្ដីអំពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍»
- អគ្គលេខាធិការរងអង្គការសហប្រជាជាតិ ទស្សនកិច្ចព្រះរាជបណ្ណាល័យហ្គូដម៉ៃ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា លេខ២៩៣ ខែឧសភា ឆ្នាំ២០២៤

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

### សំបុត្រ


◆ សុន្ទរកថា សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ..... ១

◆ សុន្ទរកថាស្វាគមន៍របស់លោក ឆាំង យុ ក្នុងពិធីបើកសន្និសីទលើកទី១ ស្ដីពី «អនាគតកម្ពុជា .......... ៨

◆ សុន្ទរកថាស្វាគមន៍របស់លោក ឆាំង យុ ក្នុងពិធីបិទសន្និសីទលើកទី១ ស្ដីពី «អនាគតកម្ពុជា ....... ១១

◆ សេចក្ដីថ្លែងអំណរគុណដ៏ស្មោះស្ម័គ្រ........... ១៤

◆ អគ្គលេខាធិការរងអង្គការសហប្រជាជាតិ ទស្សនកិច្ចព្រះរាជបណ្ណាល័យ ហ្វូងម៉ែ......... ១៦

◆ ខ្លឹមសារអត្ថានុរូបនៃព្រះរាជបណ្ណាល័យ ហ្វូងម៉ែ ដែលជាសំណង់ប្រវត្តិសាស្ត្រកម្ពុជា .......... ១៨


### ផ្នែកឯកសារ


◆ ផ្លោក អ៊ិត ហៅ ខា ៖ លេខាវរសេនាតូច ..... ២១


### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


◆ សាលយុត្តិតេជោ .............................. ២៤

◆ ពួយ ម៉ុក ៖ ផ្ដល់បទសម្ភាសន៍ដល់យុវជន ... ២៦

◆ ម៉ី កុប ៖ ចែករំលែកចំណេះដឹងពីការថែទាំសុខភាព និងរឿងរ៉ាវឆ្លងកាត់របបខ្មែរក្រហម ......... ២៨

◆ សារ៉ាយ លន់ ៖ ជំងឺសន្លាក់ខ្ញុំបានធូរស្រាល ... ៣០

◆ ហម ជន ៖ ចែករំលែកចំណេះដឹងអំពីការថែទាំសុខភាព និងរឿងរ៉ាវឆ្លងកាត់របបខ្មែរ ....... ៣៣

◆ ឡុង ចាំ ៖ ចែករំលែកចំណេះដឹងអំពីការថែទាំសុខភាព និងរឿងរ៉ាវឆ្លងកាត់របបខ្មែរ ....... ៣៥

◆ អន សំ ៖ ចែករំលែកចំណេះដឹងអំពីការថែទាំសុខភាព និងរឿងរ៉ាវឆ្លងកាត់របបខ្មែរ ....... ៣៩

◆ អ៊ូច ខេង៖ អាការជំងឺរបស់ខ្ញុំបានធូរស្រាល .. ៤២




សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាអញ្ជើញចូលរួមជាអធិបតីពិធីបើកសន្និសីទលើកទី១ ស្ដីពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍» (រូបខាងឆ្វេង) អមដំណើរដោយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាស្ថាបនិកព្រះរាជបណ្ណាល័យ ហ្វូងម៉ែ (រូបខាងស្ដាំ)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

### ផ្នែកវេទិកាពិភាក្សាសាធារណៈ


◆ អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តពោធិ៍សាត់ ទស្សនាព្រះរាជបណ្ណាល័យ ហ្វូងម៉ែ .................... ៤៥

◆ មជ្ឈមណ្ឌលផ្សះផ្សាវាលវែងរៀបចំដំណើរទស្សនកិច្ចសិក្សាអំពីសិទ្ធិមនុស្ស និង ....... ៤៧

◆ គ្រូបង្គោលថ្នាក់ជាតិមុខវិជ្ជាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ បង្ហាញចំណាប់អារម្មណ៍...... ៥១


### ផ្នែកស្រាវជ្រាវរកគ្រួសារ


◆ជីវិតកូនប្រុសពុកក្នុងគុកខ្មែរក្រហម (ត) .... ៥៨



**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧ ៥៣.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា



**ស្នេរលេខនេះ ៖** ហ៊ុន ម៉ាណែត, ឆាំង យុ, សូ ហ្វារីណា, សោម ប៊ុនថន, មីន សាណាស់, ផេង ពង្សរ៉ាស៊ី, លី រ៉ាឌី, មឿន ស្រីណុច, ឡាំ ស្រីនីត និង ហង្ស ឆាំឆាន

**អ្នកនិពន្ធ និងស្រាវជ្រាវ៖** មីន សាណាស់ **អ្នកបកប្រែ៖** លីម អ៊ីភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន

**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង



Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# សុន្ទរកថា សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ក្នុងពិធីបើកសន្និសីទលើកទី១ ស្តីអំពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍» ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤

ហ៊ុន ម៉ាណែត



សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាអញ្ជើញចូលរួមជាអធិបតីពិធីបើកសន្និសីទលើកទី១ ស្តីពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍» នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឯកឧត្តម លោកជំទាវ សមាជិកសមាជិការព្រឹទ្ធសភារដ្ឋសភា សមាជិកសមាជិការរាជរដ្ឋាភិបាល លោកជំទាវ អាលីស វ៉ៃរីមូ ឌឺរីទូ (Alice Wairimu Vderitu) អគ្គលេខាធិការរង និងជាទីប្រឹក្សាពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិស្តីអំពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍ លោកស្រីជេនីហ្វ័រ វ៉ែតម៉ែន និងលោកបណ្ឌិត ជេកគ្វីនមេកអាលីសស្ទឺ តំណាងការិយាល័យយុត្តិធម៌ឧក្រិដ្ឋកម្មសកលសហរដ្ឋអាមេរិក គណៈអធិបតី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ វាគ្មិនទាំងអស់ កម្មវិធីទាំងមូល និងជនរួមជាតិទាំងអស់ជាទីមេត្រី។ ខ្ញុំពិតជាមានការសោមនស្សជាអនេក ដែលបានចូលរួម និងថ្លែងសុន្ទរកថាគន្លឹះក្នុងសន្និសីទលើកទី១ ស្តីអំពី“**អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍**” ការការពារការឆ្លើយតប តាមរយៈការអប់រំ និងការថែទាំសុខភាពដែលត្រូវបានរៀបចំឡើងដោយទីស្តីការ

គណៈរដ្ឋមន្ត្រី អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អ.វ.ត.ក កងយោធពលខេមរភូមិន្ទ និងជាពិសេសមជ្ឈមណ្ឌលឯកសារកម្ពុជា។ ជាបឋមខ្ញុំសូមអរគុណចំពោះគំនិតផ្តួចផ្តើមដ៏ថ្លៃថ្លានេះ ដើម្បីលើកកម្ពស់អប់រំអំពីអំពើប្រល័យពូជសាសន៍នៅសាលយុត្តិតេជោ ដែលជាអតីតបន្ទប់សវនការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ វត្តមានរបស់យើងនៅថ្ងៃនេះ គឺបង្ហាញការទទួលស្គាល់នូវការរួមចំណែកដ៏សំខាន់របស់ អ.វ.ត.ក ដែលបានផ្តល់យុត្តិធម៌ជូនជនរងគ្រោះ និងអ្នករស់រានមានជីវិតពីរបបប្រល័យពូជសាសន៍ សាលាក្តីកូនកាត់មួយនេះបានឆ្លុះបញ្ចាំងពីភាពជាម្ចាស់ដ៏រឹងមាំរបស់ប្រជាជនកម្ពុជាក្នុងការប្រឈមមុខក្នុងអតីតកាលដ៏សែនលំបាក និងមានការគាំទ្រពីប្រទេសជាមិត្តក្នុងក្របខ័ណ្ឌនៃអង្គការសហប្រជាជាតិ យើងខ្ញុំសូមយកឱកាសនេះ ថ្លែងអំណរអរគុណចំពោះការគាំទ្រទាំងបច្ចេកទេស និងហិរញ្ញវត្ថុជាដៃគូនានា ដើម្បីភាពជោគជ័យរបស់ អ.វ.ត.ក។ នេះមិនមែនជារឿងចៃដន្យទេ ដែលព្រឹត្តិការណ៍នេះត្រូវបានប្រារព្ធឡើងនៅក្នុងទិវានៃការចងចាំនៅថ្ងៃ២០ ឧសភា ព្រោះជាថ្ងៃប្រជាជាតិកម្ពុជា ទាំងមូលត្រូវរំឭកឡើងវិញអំពីអំពើប្រល័យពូជសាសន៍ជាតិខ្លួនឯង ដែលធ្វើឡើងដោយរបបខ្មែរក្រហម ខ្ញុំសូមបួងសួងរំឭកទៅដល់វិញ្ញាណក្ខន្ធជនរងគ្រោះកម្ពុជា ទាំងអស់ព្រមទាំងវិញ្ញាណក្ខន្ធវីរជនខ្មែរ និងយោធិនស្ម័គ្រចិត្តវៀតណាមដែលបានពលីជីវិតដើម្បីរំដោះប្រទេស និងប្រជាជនកម្ពុជាចេញពីរបបប្រល័យពូជសាសន៍ដ៏សាហាវយង់ឃ្នង។ ឯកឧត្តមលោកជំទាវលោកលោកស្រី ការរំឭកឡើងវិញអំពីអំពើប្រល័យពូជសាសន៍ គឺជាចំណោទដ៏ឈឺចាប់មួយសម្រាប់កម្ពុជា យ៉ាងណាក៏ដោយ ការឈឺចាប់នេះបានដាក់បន្ទុកឲ្យយើងមានការទទួលខុសត្រូវក្នុងការការពារសង្គម និងមនុស្សជំនាន់ក្រោយអំពីអំពើប្រល័យពូជសសាន៍ ដើម្បីកុំឲ្យសង្គមប្រឈមនឹងការឈឺចាប់ ដែលមិនអាចពិពណ៌នាបានសារជាថ្មីទៀត នេះជាកាតព្វកិច្ចរបស់យើងទាំងអស់គ្នាក្នុងការធានាថា អំពើឃោរឃៅអមនុស្សធម៌នេះនឹងមិនកើតឡើងវិញទៀតក្នុងប្រទេសដ៏ទៃ ថ្ងៃនេះខ្ញុំចង់ចែករំលែកការពិចារណាខ្លះអំពីគោលការណ៍និងវិធីសាស្ត្ររបស់កម្ពុជាក្នុងការខិតខំប្រឹងប្រែងជាបន្តបន្ទាប់របស់យើង ដើម្បីកសាងអនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍។

**ទី១:** អំពីភាពចាំបាច់កម្ពុជាក្នុងនាមប្រជាជាតិមួយឯកភាពគ្នាលើប្រវត្តិសាស្ត្រ អនាគតរបស់ប្រទេសមួយ គឺពឹងផ្អែកលើឆន្ទៈរបស់ប្រទេសនោះក្នុងការប្រឈមមុខជាមួយនឹងអតីតកាល ប៉ុន្តែដើម្បីធ្វើបែបនេះបាន លុះត្រាតែប្រជាជាតិនោះមានការឯកភាពគ្នាលើការបកស្រាយអំពីអតីតកាល និងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗ ដែលទាក់ទងនឹងសង្គ្រាម និងសន្តិភាពរបស់ប្រទេស សម្រាប់កម្ពុជាប្រវត្តិសាស្ត្រទាក់ទងនឹងថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ថ្ងៃ២៣ តុលា ឆ្នាំ១៩៩១ និងការសម្រេចបាននូវសន្តិភាពពេញលេញទាំងស្រុងតាមរយៈនយោបាយ ឈ្នះ ឈ្នះ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨ ដែលមានសម្តេចតេជោជាស្ថាបនិកមគ្គុទេសក៏ឯក ត្រូវតែមានការបកស្រាយតែមួយ និងមានភាពរឹងមាំ ដើម្បីចៀសវាងការប្រឌិតរឿងរ៉ាវផ្សេងៗ ដើម្បីកេងចំណេញនយោបាយ ដោយបំពានលើយុត្តិធម៌លើជនរងគ្រោះពីអំពើប្រល័យពូជសាសន៍ ក៏ដូចជាការលើកកិច្ចខិតខំប្រឹងប្រែងបង្រួបបង្រួមជាតិរបស់យើង ដើម្បីរៀបរាប់ឡើងវិញអំពីប្រវត្តិសាស្ត្រអំពើប្រល័យពូជសាសន៍នៅកម្ពុជា យើងត្រូវតែទទួលស្គាល់នូវអំពើឃោរឃៅដែលរបបខ្មែរក្រហមបានប្រព្រឹត្ត យើងពិតជាមិនអាចមានទឡ្ហីករណ៍ណាមួយដើម្បីការពារពួកគេពីឧក្រិដ្ឋកម្មដ៏ឃោរឃៅប្រឆាំងនឹងមនុស្សជាតិបែបនេះបានឡើយ។ ថ្ងៃ៧ មករា ឆ្នាំ១៩៧៩ គឺជាថ្ងៃរំដោះ ឬថ្ងៃកំណើតទីពីររបស់អ្នករស់រានមានជីវិតនៅកម្ពុជារាប់លាននាក់ ហើយជាមួយនឹងវិសាលភាពនៃឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបែបនេះ យើងពិតជាមិនអាចអត្ថាធិប្បាយអំពី




*សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត ថ្លែងសុន្ទរកថាបើកសន្និសីទលើកទី១ ស្តីអំពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍» នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ថ្ងៃ៧មករា ដេរុងពីនេះបានឡើយៗ ដូចគ្នានេះដែរ ដើម្បីនិយាយអំពីដំណើរការសន្តិភាពរបស់ប្រទេសកម្ពុជាយើងត្រូវមានការយល់រួមគ្នា និងការកំណត់ឲ្យបានច្បាស់លាស់រវាងសមិទ្ធផលនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស និងសមិទ្ធផលនៃនយោបាយឈ្នះ ឈ្នះៗ ជាការពិត ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រទាំងពីរបានជួយពង្រឹងទៅវិញទៅមក ប៉ុន្តែរបត់ប្រវត្តិសាស្ត្រសំខាន់បំផុតនៃសន្តិភាពរបស់កម្ពុជាគឺកើតចេញពីលទ្ធផលដ៏ត្រចះត្រចង់នៃនយោបាយឈ្នះ ឈ្នះ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨ នៅពេលដែលអង្គការចាត់តាំងនយោបាយ និងរចនាសម្ព័ន្ធកម្លាំងប្រដាប់អាវុធខ្មែរក្រហមត្រូវបានរំសាយ ទាំងស្រុង ហើយកម្លាំងទាំងអស់របស់ខ្មែរក្រហមត្រូវបានធ្វើសមាហរណកម្មក្នុងសង្គមកម្ពុជា នេះជាសច្ចភាពនៃព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដែលបានបិទបញ្ចប់សង្គ្រាមស៊ីវិល និងការឈឺចាប់របស់ប្រជាជនកម្ពុជាដែលបានអូសបន្លាយរយៈកាល ពាទសវត្សរ៍ៗ ទាល់តែក្រោយការអនុវត្តដោយជោគជ័យនៃនយោបាយ ឈ្នះ ឈ្នះ ទើបកម្ពុជាចាប់ផ្តើមទទួលបាននូវសន្តិភាពពេញលេញ និងយូរអង្វែងរួម ទាំងឯកភាពជាតិ និងការឯកភាពក្នុងផ្លូវកង ទ័ពព្រម ទាំងទទួលបាននូវការគ្រប់គ្រងពេញលេញលើបូរណភាពទឹកដីរបស់ខ្លួននៅក្រោមដំបូលរដ្ឋធម្មនុញ្ញតែមួយ និងក្រោមម្លប់នៃព្រះមហាក្សត្រតែមួយអង្គ នេះគឺជាអច្ឆរិយហេតុសង្គមដ៏វិសេសវិសាល ដែលកម្ពុជាពុំធ្លាប់ជួបប្រទះក្នុងរយៈពេល៥០០ឆ្នាំចុងក្រោយនៃប្រវត្តិសាស្ត្ររបស់ខ្លួនៗ កិច្ចការផ្សារនេះជាកិច្ចការសំខាន់បច្ចុប្បន្ននេះ និងពេលនេះយើងអាចមានសាក្សីដែលនៅរស់មានលោកអ៊ំ មីង ពូដែលជាអ្នករងគ្រោះផ្ទាល់នៅទីនេះ ហើយអ្នកនៅទីនេះដែលកើតមុនសង្គ្រាម ខ្ញុំអាចថាឆ្លងកាត់ជាសាក្សីផ្ទាល់ដែលយើងអាចដឹងផ្ទាល់ពីតថភាព និងការវិវឌ្ឍន៍សង្គមរបស់យើង ប៉ុន្តែ២០ឆ្នាំ ៣០ឆ្នាំទៀតអត់មានទេ មានតែការរៀនសូត្រពីឯកសារ ដូច្នេះត្រូវចាំបាច់ឲ្យមានការឯកភាពគ្នាទៅលើឯកសារទៅលើការបកស្រាយឲ្យបានច្បាស់លាស់ ដើម្បីខ្មែរយើងបានយល់ច្បាស់ និងចាំច្បាស់ដោយគ្មានភាពស្រពេចស្រពិលអំពីប្រវត្តិសាស្ត្រដ៏ជូរចត់មួយនេះ បើសិនមិនមានការឯកភាពក្នុងជាតិរបស់យើងគ្រាន់តែប្រវត្តិសាស្ត្ររបស់យើងពីកិច្ចការមានការ

ប្រឡុំ ក្មេងជំនាន់ក្រោយអាចមិនដឹងច្បាស់ ហើយការចាំនូវប្រវត្តិសាស្ត្រដ៏ពិតប្រាកដមិនមែនដើម្បីចាំនូវអំពើអាក្រក់នៃភាពខ្មៅងងឹតនៃប្រវត្តិសាស្ត្រនោះទេ ប៉ុន្តែឲ្យយើងចងចាំ ហើយដឹងថាអ្វីដែលត្រូវចៀសវាងកុំឲ្យនាំប្រទេសយើងធ្លាក់ចូលក្នុងសង្គ្រាមទៀត។ កង់ប្រវត្តិសាស្ត្រវាវិវដ្តសឹងតែដល់កន្លែងមកដល់អ្វីដែលកើតមានបច្ចុប្បន្នក្នុងបញ្ហានៃជម្លោះនយោបាយភូមិសាស្ត្រក៏ធ្លាប់កើតមាននៅទសវត្សរ៍ទី៧០ ដែលកម្ពុជាពេលនោះ ត្រូវចូលក្នុងកង់នេះហើយជាប់តែម្តង អញ្ចឹងការចៀសវាងឲ្យបានច្បាស់ ហើយចាំឲ្យបានច្បាស់អំពីប្រវត្តិសាស្ត្ររបស់យើងនេះជាកិច្ចការសំខាន់។

**ទី២:** ការស្វែងរកយុត្តិធម៌ដែលមានការទទួលស្គាល់ជាអន្តរជាតិ គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការបង្កើតប្រវត្តិសាស្ត្ររួមនៃអំពើប្រល័យពូជសាសន៍សម្រាប់ទាំងអស់គ្នា ដោយមិនប្រកាន់និន្នាការនយោបាយ ខ្ញុំយល់ថា នេះជាមូលហេតុដ៏ចម្បងបំផុតដែលបានធ្វើឲ្យសម្តេចតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រីកម្ពុជា គាំទ្រការបង្កើត អ.វ.ត.ក ដោយច្បាប់របស់កម្ពុជាកាលពីឆ្នាំ២០០១។ ជាការពិតតុលាការនៃអតីតសាធារណរដ្ឋប្រជាមានិតកម្ពុជាបានកាត់ទោសមេដឹកនាំនៃរបបខ្មែរក្រហមរួចហើយកាលពីឆ្នាំ១៩៧៩។ យ៉ាងណាក្តី ថ្នាក់ដឹកនាំនិងសង្គមកម្ពុជាបានទទួលស្គាល់ថា សាលក្រមរបស់ អ.វ.ត.ក ដែលចូលរួមជួយពង្រឹងមូលដ្ឋាននៃការពិត និងជួយផ្តល់យុត្តិធម៌បន្ថែមទៀតសម្រាប់ប្រជាជាតិកម្ពុជា ព្រមទាំងនិងបានចូលរួមជួយព្យាបាលស្នាមរបួសរបស់អ្នករស់រានមានជីវិត និងជួយពង្រឹងការកសាងសន្តិភាព និងការបង្រួបបង្រួមជាតិ តាមរយៈ អ.វ.ត.ក កម្ពុជាបានបង្ហាញពីការប្រកាន់ភ្ជាប់នូវគោលការណ៍ការទទួលខុសត្រូវដើម្បីការពារ (Responsibility to protect) ហើយការដែល អ.វ.ត.ក មានលក្ខណៈមានជាសាលាក្តីកូនកាត់ ដែលគាំទ្រដោយអង្គការសហប្រជាជាតិក៏បានអនុញ្ញាតឲ្យ អ.វ.ត.ក នាំយកមេរៀនសំខាន់ៗទាំងនេះផ្តល់ទៅសហគមន៍អន្តរជាតិ ដើម្បីធានាថា ពិភពលោកនឹងលែងជួបប្រទះនៃសោកនាដកម្មនៃអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបោសសម្អាតជាតិសាសន៍ទៀតហើយ។

**ទី៣:** ឈរលើមូលដ្ឋាននៃយុត្តិធម៌សង្គម ទាំងមូលត្រូវតែបន្តរំឭកជានិច្ចអំពីបុសគល់នៃសោក-



សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាអញ្ជើញចូលរួមជាអធិបតីពិធីបើកសន្និសីទលើកទី១ ស្តីពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍» នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤។ (ហ្វេសប៊ុក សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

នាដកម្មពីអតីតកាល ដើម្បីអនុញ្ញាតឲ្យបទពិសោធន៍លំបាកបំផុតនៃអតីតកាល អាចចូលរួមចំណែកក្នុងការការពារបានកាន់តែប្រសើរឡើងទៅអនាគត ត្រង់ចំណុចនេះ ខ្ញុំចង់សង្កត់ធ្ងន់លើការរួមបញ្ចូលគ្នានៃកត្តាផ្សំផ្សេងៗដ៏ស្មុគស្មាញ ដែលនាំឲ្យកម្ពុជាធ្លាក់ចូលក្នុងរបបប្រល័យពូជសាសន៍ និងសង្គ្រាមស៊ីវិលអស់រយៈពេលពាទសវត្សរ៍ នៅពេលដែលកម្ពុជាបានបាត់បង់ឯកភាពផ្ទៃក្នុងរវាងក្រុមនយោបាយផ្សេងទៀតផ្សេងៗគ្នា ដោយមិនមានការឯកភាពគ្នាក្នុងផ្លូវកងទ័ពកម្ពុជាអាចទទួលរងការជ្រៀតជ្រែកពីបរទេស ហើយទីបំផុតកម្ពុជាអាចបាត់បង់នូវភាពជាម្ចាស់ និងម្ចាស់ការនៅក្នុងការគ្រប់គ្រងលើជោគវាសនាជាតិខ្លួនឯងភាពឈឺចាប់របស់ប្រជាជាតិកម្ពុជា ដោយសារការលូកដៃពីអំណាចបរទេសគួបផ្សំនឹងអយុត្តិធម៌សង្គមផ្ទៃក្នុងប្រទេស ដែលស្តែងឡើងតាមរយៈគម្លាត មាន ក្រ បានបង្កឲ្យមានភាពតានតឹងសង្គម និងការស្អប់ខ្ពើមព្រម ទាំងជំរុញឲ្យកើតមានឡើងនូវមនោគមវិជ្ជាជ្រុលនិយមនៃរបបប៉ុលពត។ សង្គមរបស់យើងត្រូវតែក្រើនរំឭកជាដំរាបអំពីមេរៀនទាំងនេះ ដើម្បីធានាថា យើងមិនអាចដើរលើផ្លូវដដែលនោះទេ ហើយលើសពីនេះ យើងក៏ត្រូវតែកែសម្រួល ឬសម្របស្ថានភាពសង្គមរបស់យើងនៅពេលណាដែលចាំបាច់ ដើម្បីការពារកុំឲ្យមនោគមវិជ្ជាជ្រុលនិយមចាប់ផ្តើមកកើត ឬចាក់ឫស យើងមិនអាចអនុញ្ញាតឲ្យសមាសធាតុណាមួយនៃសង្គមបណ្តុះពន្លកនៃវប្បធម៌នយោបាយជ្រុលនិយមបន្តទៀតនោះឡើយ។ តាមរយៈការជំរុញការតស៊ូ វណ្ណៈ ការស្អប់ខ្ពើមប្រឆាំងនឹងអាជ្ញាធរ ការផ្លាស់ប្តូររបបដែលផ្ទុយនឹងគោលការណ៍ប្រជាធិបតេយ្យ និងការរើសអើងពូជសាសន៍ កំហុសពីអតីតកាលបានប្រាប់យើងឲ្យចេះបង្រួបបង្រួមជាតិខ្មែរឲ្យបានរឹងមាំ និងជំរុញឲ្យយើងកសាងសង្គមឲ្យកាន់តែប្រសើរប្រកបដោយបរិយាបន្នសម្រាប់ទាំងអស់គ្នា នេះគឺជាកាតព្វកិច្ចរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ និងយុត្តិធម៌សង្គម ដើម្បីធានានូវបរិយាបន្នភាពនៅក្នុងប្រព័ន្ធគ្រប់គ្រងក៏ដូចជាការអភិវឌ្ឍន៍ជាតិយើង។

**ទី៤**: យើងត្រូវតែទទួលស្គាល់ថាការអប់រំអំពីអំពើប្រល័យពូជសាសន៍ក៏ជាយន្តការទប់ស្កាត់អំពីប្រល័យពូជសាសន៍នៅកម្រិតជាតិយើងបានរៀបចំព្រឹត្តិការណ៍ជាច្រើនជារៀងរាល់ឆ្នាំ ដើម្បីបង្កើតជាចលនាជាតិ នៅក្នុងការរំឭកអំពីអំពើប្រល័យពូជសាសន៍ យើងត្រូវធានាឲ្យបាននូវការការពារថែរក្សានូវទិដ្ឋភាពរូបវន្ត និងអរូបីនៃប្រវត្តិសាស្ត្រ រួមមានការរក្សាទីតាំងឧក្រិដ្ឋកម្ម និងភស្តុតាងក៏ដូចជាការនិទានប្រវត្តិសាស្ត្រដោយផ្ទាល់មាត់។ ទន្ទឹមនឹងការថែរក្សាទីតាំងប្រវត្តិសាស្ត្រភស្តុតាង និងបណ្ណសារឲ្យបានត្រឹមត្រូវ យើងក៏ត្រូវខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីបញ្ជ្រាបការពិតដ៏សែនលំបាកទាំងនេះទៅកាន់មនុស្សជំនាន់ក្រោយដែលអាចមានគម្លាតពីការយល់ដឹងផ្សេងគ្នាបើប្រៀបធៀបជាមួយអ្នកឆ្លងកាត់របបប្រល័យពូជសាសន៍ យើងត្រូវតែបន្តនិយាយរឿងទាំងនេះពីមួយជំនាន់ទៅមួយជំនាន់ទៀត ទោះបីជាការនិយាយរឿងនេះបង្កឲ្យមានការឈឺចាប់ក៏ដោយ នេះគឺជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពបំផុត ព្រោះមានតែអ្នកដែលធ្លាប់បានឆ្លងកាត់ប៉ុណ្ណោះទើបអាចរៀបរាប់ពីបទពិសោធន៍របស់ពួកគេបានល្អបំផុត។ ក្រោយពីបញ្ចប់ដំណើរការកាត់ក្តី អ.វ.ត.ក ត្រូវបានអនុវត្តមុខងារដែលនៅសេសសល់ ជាពិសេសពាក់ព័ន្ធនឹងការអប់រំអំពីអំពើប្រល័យពូជសាសន៍ ជាមួយបទពិសោធន៍ជាក់ស្តែងនៅក្នុងបន្ទប់សវនាការ និងបណ្ណសារយ៉ាងទូលំទូលាយ អ.វ.ត.ក ក៏ជាតួរអង្គអនុវត្តដ៏ល្អបំផុតក្នុងការអប់រំអំពីអំពើប្រល័យពូជសាសន៍ បន្ថែមលើនេះ អ.វ.ត.ក ក៏អាចពន្យល់ដល់ពិភពលោកអំពីវិធីសាស្ត្រត្រឹមត្រូវដែលប្រជាជនកម្ពុជាអាចប្រឈមមុខដោយផ្ទាល់ និងផ្សះផ្សាជាមួយអតីតកាលដ៏សោកសៅនេះ តាមរយៈដំណើរការកាត់ក្តីដោយមិនលម្អៀង និងភាពជាម្ចាស់ដ៏រឹងមាំរបស់ប្រជាជនកម្ពុជា ស្ថាប័នរដ្ឋាភិបាលទាំងអស់ ទាំងយោធា និង

ស៊ីវិល ត្រូវតែគាំទ្រការអប់រំអំពីអំពើប្រល័យពូជសាសន៍សម្រាប់មនុស្សជំនាន់ក្រោយ យើងត្រូវតែធានាថា ការបង្រៀនប្រវត្តិសាស្ត្រត្រូវបានដាក់បញ្ចូលយ៉ាងត្រឹមត្រូវនៅក្នុងកម្មវិធីសិក្សារបស់សាលារដ្ឋ និងឯកជន ចាប់ពីអនុវិទ្យាល័យរហូតដល់សាកលវិទ្យាល័យ ហើយគ្រូបង្រៀនទាំងអស់របស់យើងអាចចូលរួមជាកម្លាំង ដើម្បីផ្សព្វផ្សាយការអប់រំអំពីអំពើប្រល័យពូជសាសន៍នៅក្នុងសាលារៀនទូទាំងប្រទេស ការអប់រំពីអំពើប្រល័យពូជសាសន៍មិនចាំបាច់កំណត់តែមេរៀនប្រវត្តិសាស្ត្រនោះទេ យើងក៏អាចបញ្ចូលទៅក្នុងមុខវិជ្ជាគ្រប់ប្រភេទចាប់ពីសីលធម៌ និងអក្សរសាស្ត្រខ្មែររហូតដល់ការសិក្សាពីភាពជាអ្នកដឹកនាំ និងការអភិវឌ្ឍន៍ជំនាញទន់ផ្សេងទៀតផងដែរ។ យើងក៏អាចស្វែងរកវិធីច្នៃប្រឌិតផ្សេងៗ ដើម្បីរៀបរាប់រឿងរ៉ាវពិបាកទាំងនេះទៅកាន់មនុស្សដែលមានវ័យ និងជំនាន់ផ្សេង រួមមានតាមរយៈសិល្បៈ មាតិកាឌីជីថល គំនូរជីវចលជាដើម។ យើងចាំបាច់ត្រូវសង្កត់ធ្ងន់ថា កាតព្វកិច្ចលើកកម្ពស់ការអប់រំពីអំពើប្រល័យពូជសាសន៍ គឺជាកាតព្វកិច្ចរបស់យើងទាំងអស់គ្នា មិនមែនតែរាជរដ្ឋាភិបាលម្នាក់ឯងនោះទេ។ សន្និសីទថ្ងៃនេះ គឺជាគំរូដ៏ប្រសើរនៃកិច្ចសហប្រតិបត្តិការល្អសាមគ្គីភាពរវាងតួអង្គពាក់ព័ន្ធផ្សេងៗ ខ្ញុំសូមអរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជា DC-Cam ដែលបានជួយរាជរដ្ឋាភិបាលនៅក្នុងការដាក់បញ្ចូលការបង្រៀនអំពីប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍ទៅក្នុងការអភិវឌ្ឍន៍វិជ្ជាជីវៈ និងស្ថាប័ននិងសម្រាប់សកម្មភាពផ្សព្វផ្សាយក្នុងមជ្ឈដ្ឋានជាតិ និងអន្តរជាតិដោយប្រើប្រាស់ប្រវត្តិសាស្ត្រ ដើម្បីត្រិះរិះពិចារណា និងបំផុសគំនិតសម្រាប់អនាគតកម្ពុជា។

**ទី៥:** ចំណុចចុងក្រោយនិងសំខាន់បំផុតគឺយើងត្រូវតែការពារសន្តិភាពដែលសម្រេចបានដោយលំបាកលំបិនបំផុតនេះឲ្យខានតែបាន ទោះក្នុងតម្លៃណាក៏ដោយ។ កាតព្វកិច្ចនេះមិនមែនជាកាតព្វកិច្ចសម្រាប់តែប្រជាជាតិកម្ពុជាតែប៉ុណ្ណោះទេ ប៉ុន្តែវាជាកាតព្វកិច្ចសម្រាប់សហគមន៍អន្តរជាតិទាំងមូលផងដែរ ដែលយើងឃើញថា សង្គ្រាមនៅទូទាំងពិភពលោកមិនដែលបានផ្តល់ផលល្អសម្រាប់ប្រជាជាតិណាមួយនៅសាកលលោកនោះទេ។ ជាសក្សានុម័តសង្គ្រាម គឺជាស្ថានការណ៍ដែលបន្តឲ្យមានការសម្លាប់រង្គាលប្រឆាំងនឹងជនស៊ីវិលដោយគ្មានរើសអើងដោយសារតែការប្រយុទ្ធគ្នារបស់ក្រុមប្រដាប់អាវុធ។ នៅពេលដែលសង្គ្រាមកើតឡើងហើយគ្មានឡើយសិទ្ធិមនុស្ស គ្មានឡើយប្រជាធិបតេយ្យ។ ដូច្នេះនេះគឺជាការទទួលខុសត្រូវរបស់រដ្ឋ និងប្រជាជនទាំងអស់គ្នាក្នុងការការពារសន្តិភាពនៅក្នុងការឲ្យតម្លៃដល់សន្តិភាពដែលសម្រេចបានមកជាមួយនឹងការលះបង់មិនអាចកាត់ថ្លៃបាននោះទេ ដោយមិនត្រូវភាន់ច្រឡំថា សន្តិភាពបានមកដោយឯងៗនោះទេ មេដឹកនាំអនាគតរបស់កម្ពុជា ទាំងអស់ត្រូវចៀសវាងពីការចូលរួមក្នុងផែនការនយោបាយដែលជំរុញការផ្លាស់ប្តូររបបដោយវិធីសាស្ត្រមិនប្រជាធិបតេយ្យ ហើយត្រូវតែប្រកាន់ភ្ជាប់នៅមនសិការនៃការទទួលខុសត្រូវក្នុងការការពារសន្តិភាពឲ្យខានតែបាន។ ឈរលើគោលការណ៍ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញរបស់ខ្លួន និងធម្មនុញ្ញនៃអង្គការសហប្រជាជាតិកម្ពុជានឹងបន្តអនុវត្តគោលនយោបាយការបរទេសឯករាជ្យផ្អែកលើច្បាប់ កសាងទំនាក់ទំនងនៃសហប្រតិបត្តិការល្អរវាងកម្ពុជាជាមួយនឹងប្រទេសទាំងអស់ក្នុងពិភពលោក និងជាមួយអង្គការអន្តរជាតិនានា ព្រមទាំងហ្នឹងបន្តចូលរួមយ៉ាងសកម្មក្នុងបុព្វហេតុសន្តិភាព ស្ថិរភាព សន្តិសុខ និងវិបុលភាពនៅក្នុងតំបន់និងលើពិភពលោក យើងនឹងបន្តការពារខ្លួនប្រឆាំងនឹងការប្រឌិត ដែលមានចេតនាអាក្រក់នៅក្នុងគោលដៅបង្ខូចកេរ្តិ៍ឈ្មោះរបស់កម្ពុជា និងប្រឆាំងរាល់ការប៉ុនប៉ងទាំងឡាយណាដែលចង់ធ្វើឲ្យកម្ពុជាធ្លាក់ទៅក្នុងអន្ទាក់នៃការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ ហើយប្រែក្លាយកម្ពុជាឲ្យទៅជាសមរភូមិនៃសង្គ្រាមត្រជាក់សារជាថ្មីម្តងទៀត។

ឯកឧត្ដម លោកជំទាវ លោក លោកស្រី ការប្រឈមនឹងអតីតកាល គឺជាអស្រែកផ្លូវចិត្តដ៏ធ្ងន់សម្រាប់កម្ពុជា ដោយសារតែអំពើឃោរឃៅយង់ឃ្នងនៃរបបខ្មែរក្រហម និងការឈឺចាប់ជាច្រើនទសវត្សរ៍របស់ប្រជាជនខ្មែរយើង។ យ៉ាងណាក្ដី ការប្រឈមមុខនឹងអតីតកាលមិនចាំបាច់ផ្ដោតតែលើសោកនាដកម្មដែលប្រជាជនកម្ពុជាជួបប្រទះក្នុងសតវត្សរ៍ទី២០នោះទេ។ ប្រជាជនកម្ពុជាត្រូវតែមានសង្ឃឹមជាមួយនឹងការពិតដែលប្រជាជាតិយើងបានរស់រានប្រកបដោយភាពរឹងមាំ យើងក៏ជាគំរូសម្រាប់ប្រទេសផ្សេងទៀតនៅជុំវិញពិភពលោក ដែលកំពុងទទួលរងបញ្ហានិងដោតវាសនាស្រដៀងគ្នានេះ កិច្ចការដែលកម្ពុជាបានធ្វើទាក់ទងនឹងការអប់រំពីអំពើប្រល័យពូជសាសន៍ក៏ជាជោគជ័យដ៏លេចធ្លោមួយនៅលើឆាកអន្តរជាតិ កិច្ចការ ដែលកម្ពុជាបានធ្វើអាចយកទៅប្រើប្រាស់ដើម្បីធ្វើជាមេរៀនសម្រាប់ការអភិវឌ្ឍន៍របស់ប្រទេសក្រោយជម្លោះផ្សេងទៀត។ ប្រជាជនកម្ពុជាត្រូវតែមានមោទនភាពថា ពួកយើងគឺជាអ្នកឈ្នះចុងក្រោយបំផុត ទោះទៅលើរបបប្រល័យពូជសាសន៍ខ្មែរក្រហម ហើយពួកយើងគឺជាគំរូនៃការខិតខំកសាងអនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍។ ខ្ញុំសូមបញ្ចប់សុន្ទរកថានេះ ដោយការថ្លែងអំណរគុណចំពោះអង្គការសហប្រជាជាតិ និងប្រទេសជាមិត្តសម្រាប់ការគាំទ្រដល់សាលាក្ដីអន្តរជាតិកូនកាត់មួយនេះ។ ជាមួយនឹងការសន្យានិងការផ្ដល់ការគាំទ្រផ្នែកនយោបាយ និងហិរញ្ញវត្ថុដែលអនុវត្តឲ្យ អ.វ.ត.ក បានបញ្ចប់ដំណើរការតុលាការប្រកបដោយជោគជ័យ ជាមួយនឹងការទទួលស្គាល់ជាអន្តរជាតិ ដើម្បីប្រយោជន៍នៃការចងចាំប្រវត្តិសាស្ត្រ និងការអប់រំអំពីអំពើប្រល័យពូជសាសន៍ ក៏ដូចជាការពង្រឹង និងការថែរក្សាដោយសុខសន្តិភាព និងការបង្រួបបង្រួមជាតិ តទៅមុខខ្ញុំសូមអំពាវនាវឲ្យមានការបន្តការគាំទ្រពីភាគីពាក់ព័ន្ធទាំងអស់ទៅក្នុងការផ្សព្វផ្សាយអប់រំពីអំពើប្រល័យពូជសាសន៍ ជាពិសេសតាមរយៈការថែរក្សាការពារ និងការប្រើប្រាស់បណ្ណសារជាង២លានទំព័រ ដែលប្រមូលបានពីដំណើរការតុលាការរបស់ អ.វ.ត.ក ដើម្បីស្រាវជ្រាវ និងសាធារណៈអ្នកស្រាវជ្រាវ និងសាធារណជនទូទៅក្នុងតំបន់ និងពិភពលោក អាចយល់កាន់តែច្បាស់អំពីប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ឈានទៅបង្កើតអនាគតពិភពលោកមួយដែលគ្មានអំពើប្រល័យពូជសាសន៍។ ខ្ញុំសូមជូនពរដល់អង្គសន្និសីទទទួលបានជោគជ័យត្រចះត្រចង់ជាមួយនឹងការពិភាក្សាប្រកបដោយភាពសកម្ម និងផ្លែផ្កា ខ្ញុំសូមជូនពរអ្នកចូលរួមទាំងអស់បានប្រកបទៅដោយសុខភាពល្អ វិបុលភាព សុភមង្គល ជោគជ័យគ្រប់ភារកិច្ច សូមអរគុណ។



លោកជំទាវ អាលីស វ៉ៃរីមូ ឌីរីទូ អគ្គលេខាធិការរង និងជាទីប្រឹក្សារបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ស្ដីអំពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ថ្លែងសុន្ទរកថាគន្លឹះ ក្នុងពិធីបើកសន្និសីទលើកទី១ ស្ដីអំពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍» នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សុន្ទរកថាស្វាគមន៍របស់លោក ឆាំង យុ

## ក្នុងពិធីបើក សន្និសីទលើកទី១ ស្ដីពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍» ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤

**ឆាំង យុ**



លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាស្ថាបនិកព្រះរាជបណ្ណាល័យ ហ្វូងម៉ៃ ឡើងថ្លែងសុន្ទរកថាបើកសន្និសីទលើកទី១ ស្ដីពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍» នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

- សូមគោរព សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់!
- សូមគោរពឯកឧត្តមលោកជំទាវ សមាជិក សមាជិកានៃព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល
- សូមគោរព លោកជំទាវ អាលីស អ៊ែរីមូ ឌីរីទូ អគ្គលេខាធិការរង និង ជាទីប្រឹក្សាពិសេសរបស់អង្គការសហប្រជាជាតិ ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍
- សូមគោរពលោកជំទាវ ប៊ិត វ៉ាន់សាក់ អគ្គរដ្ឋទូតសហរដ្ឋអាមេរិក ការិយាល័យយុត្តិធម៌ព្រហ្មទណ្ឌសកល នៃក្រសួងការបរទេសសហរដ្ឋអាមេរិក
- សូមគោរព ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ
- សូមគោរព អ៊ំ ពូ មីង ដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងប្អូនៗដែលជាអ្នកស្រាវជ្រាវវ័យក្មេង ជាទីគោរព និងជាទីស្នេហា!

ខ្ញុំបាទ ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាស្ថាបនិកព្រះរាជបណ្ណាល័យ ហ្វូងម៉ៃ សូមគោរពស្វាគមន៍សន្និសីទលើកទី១ ក្រោមប្រធានបទ «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍»។ ទូលព្រះបង្គំ ខ្ញុំបាទសូមថ្លែងអំណរព្រះគុណ និងអំណរគុណយ៉ាងជ្រាលជ្រៅ ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា, សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល, សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា, សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងកងកម្លាំងប្រដាប់អាវុធ មានជាអាទិ៍ នាយទាហាន និងពលទាហាននៃកងយោធពលខេមរភូមិន្ទ និងនាយនគរបាល ពលនគរបាលជាតិ។

ខ្ញុំបាទសូមដឹងគុណដល់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ ដែលតែងតែផ្តល់ជំនួយគាំទ្រយ៉ាងខ្ជាប់ខ្ជួន មកមជ្ឈមណ្ឌលឯកសារកម្ពុជា។ សន្និសីទលើកទី១នេះ មិនអាចប្រព្រឹត្តទៅបានឡើយ ប្រសិនបើពុំមានការគាំទ្រទាំងអស់ខាងលើនេះទេ។

ខ្ញុំបាទ សូមគោរពអរគុណយ៉ាងក្រៃលែង ឯកឧត្តមនាយឧត្តមសេនីយ៍ ម៉ៅ សុផាន់ មេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក ដែលអនុញ្ញាតឲ្យខ្ញុំបាទ ប្រើប្រាស់ទីតាំង សាលយុត្តិតេជោ ដ៏មានសារសំខាន់ ដើម្បីរៀបចំសន្និសីទក្នុងថ្ងៃនេះ។ ការគាំទ្រ និងការជួយជ្រោមជ្រែងដ៏សស្រាក់សស្រាំពីសំណាក់ឯកឧត្តមនាយឧត្តមសេនីយ៍ គឺពិតជាមានសារសំខាន់យ៉ាងធំធេង ក្នុងការជំរុញឲ្យសន្និសីទនេះប្រព្រឹត្តទៅបានយ៉ាងល្អប្រសើរ។


លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាស្ថាបនិកព្រះរាជបណ្ណាល័យ ហ្វូងម៉ៃ ឡើងថ្លែងសុន្ទរកថាបើកសន្និសីទលើកទី១ ស្តីពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍» នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សមត្ថភាពរបស់កម្ពុជាក្នុងការសម្រេចបាននូវអនាគតមួយដោយគ្មានអំពើប្រល័យពូជសាសន៍ គឺពឹងផ្អែកយ៉ាងសំខាន់ទៅលើភាពអង់អាចមោះមុតរបស់កម្ពុជា ក្នុងការប្រឈមតទល់ជាមួយនឹងប្រវត្តិសាស្ត្ររបស់ខ្លួន ព្រមទាំងប្រែក្លាយមេរៀនជាគំរូទាំងអស់នេះ ទៅជាយុទ្ធសាស្ត្រប្រកបដោយអត្ថន័យសម្រាប់អនាគតកាល។ សន្និសីទលើកទី១នេះ គឺជាជំហានដ៏ចាំបាច់មុតមាំឈានទៅសម្រេចបានដំណើរដ៏វែងឆ្ងាយមួយ។

ក្រុមការងាររៀបចំសន្និសីទមានគោលបំណងបង្កើតជាសហគមន៍អន្តរកាលមួយ ដោយប្រមូលផ្តុំនូវអ្នកជំនាញផ្នែកសិទ្ធិមនុស្ស និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ នៅក្នុងសង្គមក្រោយជម្លោះ ដែល អាចចែករំលែកការយល់ឃើញប្រកបដោយភាពច្នៃប្រឌិត និងការអនុវត្តប្រសើរបំផុតឲ្យរួមគ្នាកសាងនូវសន្តិភាព ប្រកបដោយនិរន្តរភាពនៅក្នុង

ប្រទេសកម្ពុជានិងសង្គមដទៃផ្សេងទៀត។ សន្និសីទក្នុងថ្ងៃនេះ គឺជាសន្និសីទដំបូងបង្អស់ ដែលនឹងដើរតួនាទីជាមូលដ្ឋានគ្រឹះសម្រាប់បណ្ដាញទំនាក់ទំនងនេះ។

ជាថ្មីម្ដងទៀត ខ្ញុំបាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា, ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ, ភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិ, ឯកឧត្តម លោកជំទាវ លោក-លោកស្រី អ្នកនាងកញ្ញា ដែលបានចំណាយពេលចូលរួមនៅក្នុងព្រឹត្តិការណ៍ដ៏មានសារសំខាន់នាថ្ងៃនេះ។ ខ្ញុំបាទទន្ទឹងរង់ចាំត្រងត្រាប់ស្ដាប់ការចែករំលែកទស្សនៈយល់ឃើញ និងមតិយោបល់ដ៏ថ្លៃថ្លារបស់សម្ដេច ឯកឧត្តម លោកជំទាវ លោក-លោកស្រី អ្នកនាងកញ្ញា។

**ឆាំង យុ**
**នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា**



ភ្ញៀវកិត្តិយសអញ្ជើញចូលរួមសន្និសីទលើកទី១ ស្ដីអំពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍» ដែលប្រព្រឹត្តទៅនៅថ្ងៃទី ២០-២២ ខែឧសភា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



លោកជំទាវ ប៊េត វ៉ាន់សាក់ អគ្គរដ្ឋទូតសហរដ្ឋអាមេរិក ការិយាល័យយុត្តិធម៌ព្រហ្មទណ្ឌសកលនៃក្រសួងការបរទេសសហរដ្ឋអាមេរិក ថ្លែងសុន្ទរកថាក្នុងពិធីបើកសន្និសីទលើកទី១ «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍» នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សុន្ទរកថាស្វាគមន៍របស់លោក ឆាំង យុ ក្នុងពិធីបិទ សន្និសីទលើកទី១ ស្តីពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍»

ឆាំង យុ




*សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានក្រុមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញចូលរួមជាអធិបតីពិធីបិទសន្និសីទលើកទី១ ស្តីពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍» នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

- សូមគោរព សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់!

- សូមគោរព ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល

- សូមគោរព លោកជំទាវ អាលីស វ៉ៃរីមូ ន៉ឺរីទូ អគ្គលេខាធិការរង និង ជាទីប្រឹក្សាពិសេស របស់អង្គការសហប្រជាជាតិ ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍

- សូមគោរព លោកជំទាវ ប៊ែត វ៉ាន់សាក់ អគ្គរដ្ឋទូតសហរដ្ឋអាមេរិក ការិយាល័យយុត្តិធម៌ព្រហ្មទណ្ឌសកល នៃក្រសួងការបរទេសសហរដ្ឋអាមេរិក

- សូមគោរព ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ

- សូមគោរពអ៊ំ ពូមីង ដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងប្អូនៗដែលជាអ្នកស្រាវជ្រាវវ័យក្មេង ជាទីគោរព និងជាទីស្នេហា!

ខ្ញុំបាទ ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងស្ថាបនិកព្រះរាជបណ្ណាល័យ ហ្វូងម៉ែ។ ស្របពេលដែលយើងគ្រោងនឹងបិទបញ្ចប់សន្និសីទលើកទី១ ក្រោមប្រធានបទ «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍» ខ្ញុំបាទសូមសម្តែងអំណរគុណក្រៃលែង វត្តមានសម្តេច ឯកឧត្តម លោកជំទាវ លោក-លោកស្រី អ្នកនាងកញ្ញា ដែលបានចូលរួម ញ៉ាំងឲ្យសន្និសីទនេះប្រព្រឹត្តទៅដោយរលូន និងជោគជ័យ។

ទូលព្រះបង្គំ ខ្ញុំបាទសូមគោរពថ្លែងអំណរព្រះគុណ និងអំណរគុណយ៉ាងជ្រាលជ្រៅ ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា, សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល, សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា, សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែនប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងកងកម្លាំងនៃកងយោធពលខេមរភូមិន្ទ ដែលរួមមានមន្ត្រីយោធា និងមន្ត្រីនគរបាល។



សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា (ដើរខាងមុខ) អមដំណើរដោយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាស្ថាបនិកព្រះរាជបណ្ណាល័យ ហ្វូងម៉ែ អញ្ជើញចូលរួមជាអធិបតីពិធីបិទសន្និសីទលើកទី១ ស្តីពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍» នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំបាទមានសេចក្តីដឹងគុណដល់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិដែលតែងតែផ្តល់ ជាជំនួយគាំទ្រយ៉ាងខ្ជាប់ខ្ជួន ចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជា។ សន្និសីទលើកទី១នេះមិនអាចប្រព្រឹត្តទៅបាន ឡើយប្រសិនបើពុំមានការគាំទ្រទាំងអស់ខាងលើនេះទេ។

ខ្ញុំបាទ សូមគោរពអរគុណយ៉ាងក្រៃលែង ជាថ្មីម្តងទៀតចំពោះ ឯកឧត្តមនាយឧត្តមសេនីយ៍ ម៉ៅ សុផាន់ មេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក ដែលអនុញ្ញាតឲ្យខ្ញុំបាទ ប្រើប្រាស់ទីតាំង សាលយុត្តិតេជោ ដ៏មានសារសំខាន់ ដើម្បីរៀបចំសន្និសីទ ញ៉ាំងឲ្យសន្និសីទនេះប្រព្រឹត្តទៅបានយ៉ាងល្អប្រសើរ។

សន្និសីទលើកទី១នេះ គឺគ្រាន់តែជាជំហានដំបូងប៉ុណ្ណោះ ក្នុងការឈានទៅសម្រេចបានអនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍។

សន្និសីទនេះ ចាប់ផ្តើមដើមដំបូងជាមួយនឹងបេសកកម្មក្នុងការបង្កើតជាសហគមន៍អន្តរកាលមួយ ដោយគួបផ្សំប្រមូលផ្តុំនូវអ្នកជំនាញផ្នែកសិទ្ធិមនុស្ស និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅក្នុងសង្គមក្រោយជម្លោះ។ ខ្ញុំបាទ ទន្ទឹងរង់ចាំផ្តើការរួមសហការគ្នា ក្នុងការកសាងនូវសន្តិភាពប្រកបដោយនិរន្តរភាពនៅក្នុងប្រទេសកម្ពុជា និងសង្គមដទៃផ្សេងទៀត តាមរយៈសន្និសីទជាបន្តបន្ទាប់នាពេលអនាគត។

ជាថ្មីម្តងទៀត ខ្ញុំបាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា, ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ, ភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិ, ឯកឧត្តម លោកជំទាវ លោក-លោកស្រី អ្នកនាងកញ្ញា ដែលបានចំណាយពេលចូលរួមនៅក្នុងព្រឹត្តិការណ៍ដ៏មានសារសំខាន់នាថ្ងៃនេះ និងជំរុញឲ្យសន្និសីទនេះប្រព្រឹត្តទៅដោយជោគជ័យ។



សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានក្រុមឧត្ដមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា អមដំណើរដោយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាស្ថាបនិកព្រះរាជបណ្ណាល័យហ្វូងម៉ែ អញ្ជើញទស្សនាពិព័រណ៍រូបថតប្រវត្តិសាស្ត្រក្នុងពិធីបិទសន្និសីទលើកទី១ ស្ដីពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍» នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤។ (ហ្វេសប៊ុក សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន)








# សេចក្តីថ្លែងអំណរគុណដ៏ស្មោះស្ម័គ្រ ជូនចំពោះប្អូនៗដែលជាអ្នកស្រាវជ្រាវវ័យក្មេង



រូបរាប់ពីឆ្វេង៖ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាស្ថាបនិកព្រះរាជបណ្ណាល័យ ហ្វូង ម៉ែ, ឯកឧត្តមបណ្ឌិត ដាតុ អូស្មាន ហាហ្សាន់ ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកម្មពិសេស, លោកជំទាវ អាលីស វៃរីមូ ឌីរីទូ អគ្គលេខាធិការរង និងជាទីប្រឹក្សាពិសេសរបស់អង្គការសហប្រជាជាតិ ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍, លោកជំទាវ ជា លាង អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូលនៃព្រះរាជាណាចក្រកម្ពុជា, លោកជំទាវ ចាន់ សុទ្ធាវី ប្រធានគណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃព្រឹទ្ធសភា និងអ្នកស្រី សូ ហ្វារីណា នាយិការងមជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងសន្និសីទលើកទី១ ស្តីពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍» ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

តាងនាមឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានសហការជាមួយខុទ្ទកាល័យសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសាលាច្បាប់ប៊ិសលីនៃសកលវិទ្យាល័យថេមផល សហរដ្ឋអាមេរិក ខ្ញុំសូមសម្តែងនូវការដឹងគុណចំពោះការចូលរួមរបស់ប្អូនៗដែលជាអ្នកស្រាវជ្រាវវ័យក្មេង នៅក្នុងសន្និសីទលើកទី១ស្តីពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍» ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២០ ដល់ ២២ ខែឧសភា ឆ្នាំ២០២៤ កន្លងទៅនេះ។

ការចូលរួមរបស់ប្អូនៗនៅក្នុងសន្និសីទនេះគឺពិតជាមានសារសំខាន់ដែលឈានដល់ការសម្រេចបាននូវភាពជោគជ័យ។ សន្និសីទនេះទៀតសោតគឺជាជោគជ័យដ៏អស្ចារ្យមួយ ដោយសារមានការចូលរួមប្រកបដោយយុទ្ធសាស្ត្រពីភាគីដែលពាក់ព័ន្ធគ្រប់កម្រិត ចាប់តាំងពីការរៀបចំផែនការ និងការអនុវត្តក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅនៅក្នុងប្រទេសកម្ពុជា តំបន់អាស៊ីអាគ្នេយ៍ និងនៅក្នុងពិភពលោក។

ខណៈពេលដែលអ្នករៀបចំសន្និសីទកំពុងធ្វើការបូកសរុបរបាយការណ៍ ដោយរៀបរាប់ពីចំណុចគន្លឹះសំខាន់ៗ សេចក្តីថ្លែងពីគោលនយោបាយ និងជំហានជាយុទ្ធសាស្ត្របន្ទាប់នោះ ខ្ញុំសូមបង្ហាញប្អូនៗនូវចំណុចជាក់លាក់មួយចំនួន ដែលសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានសង្កត់ធ្ងន់នៅក្នុងសុន្ទរកថាបើកៗ សម្តេចមហាបវរធិបតី បានបញ្ជាក់យ៉ាងច្បាស់នូវតួនាទីដ៏សំខាន់របស់ពលរដ្ឋកម្ពុជា រួមទាំងយុវជននៅក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ។

អនាគតកម្ពុជា ទាមទារឲ្យយើងមានការប្តេជ្ញាចិត្តខ្ពស់ ដើម្បីការពារនិងសិក្សាអំពីអតីតកាល។ បន្ថែមលើសនេះទៀត អនាគតកម្ពុជា ទាមទារឲ្យមានការខិតខំដល់ការរៀនសូត្រពីអតីតកាល ដើម្បីធានាថាអំពើប្រល័យពូជសាសន៍មិនកើតឡើងជាថ្មីទៀតនៅក្នុងប្រទេសកម្ពុជា នៅក្នុងតំបន់ និងនៅក្នុងពិភពលោកៗ ការបង្ការឧក្រិដ្ឋកម្មឃោរឃៅ កុំឲ្យកើតមានក្នុងពេលអនាគត ចាប់ផ្តើមជាមួយនឹងការឈ្វេងយល់អំពីថាតើឧក្រិដ្ឋកម្មឃោរឃៅនេះបានកើតឡើងយ៉ាងដូចម្តេចនៅក្នុងពេលអតីតកាល ដូច្នេះការចូលរួមរបស់ប្អូនៗនៅក្នុងសន្និសីទនេះ គឺជាជំហានដ៏សំខាន់ឆ្ពោះទៅសម្រេចបាននូវកិច្ចខិតខំប្រឹងប្រែងនេះៗ



ភ្ញៀវកិត្តិយសអញ្ជើញចូលរួមសន្និសីទលើកទី១ស្តីពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍»ៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណប្អូនៗសារជាថ្មីចំពោះការចូលរួមនៅក្នុងសន្និសីទនេះ ដែលញ៉ាំងឲ្យសន្និសីទសម្រេចបាននូវភាពជោគជ័យៗ យើងទាំងអស់គ្នាមានសេចក្តីរំភើបចំពោះភាពជោគជ័យនៃសន្និសីទនេះ ហើយ ទន្ទឹងរង់ចាំឱកាសនាពេលខាងមុខ ក្នុងការអប់រំអំពីការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ ដែលឈានចេញពីភាពជោគជ័យនេះៗ ខ្ញុំសូមជូនពរប្អូនៗនិងក្រុមគ្រួសារ ឲ្យមានសុខភាពល្អ និងទទួលបានពរជ័យគ្រប់ប្រការៗ សូមប្អូនៗទទួលយកនូវសេចក្តីគោរពរាប់អានពីខ្ញុំៗ

**សូ ហ្វារីណា**

នាយិការងមជ្ឈមណ្ឌលឯកសារកម្ពុជា



អ្នកស្រី សូ ហ្វារីណា នាយិការង មជ្ឈមណ្ឌលឯកសារកម្ពុជា (រូបខាងឆ្វេង) និងលោកជំទាវ អាលីស វ៉ៃរីម៉ូ ឌីរីទូ អគ្គលេខាធិការរង និងជាទីប្រឹក្សាពិសេសរបស់អង្គការសហប្រជាជាតិ ដើម្បីទប់ស្កាត់អំពីប្រល័យពូជសាសន៍ នៅសន្និសីទលើកទី១ ស្តីពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍»ៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អគ្គលេខាធិការ រងអង្គការសហប្រជាជាតិ ទស្សនកិច្ចព្រះរាជបណ្ណាល័យហ្លួងម៉ែ
## នៃមជ្ឈមណ្ឌលឯកសារកម្ពុជា

**សោម ប៊ុនថន**



លោកជំទាវ អាលីស វៃរីម៉ូ ឌីរីទូ អគ្គលេខាធិការរង និងជាទីប្រឹក្សាពិសេសរបស់អង្គការសហប្រជាជាតិ ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ ទស្សនកិច្ចព្រះរាជបណ្ណាល័យ ហ្លួងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅរសៀលថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៤ លោកជំទាវ អាលីស វៃរីម៉ូ ឌីរីទូ អគ្គលេខាធិការរងអង្គការសហប្រជាជាតិ និងជាទីប្រឹក្សាពិសេសទទួលបន្ទុកការទប់ស្កាត់អំពើប្រល័យពូជសាសន៍ រួមទាំងគណៈប្រតិភូ ទស្សនកិច្ចព្រះរាជបណ្ណាល័យ ហ្លួងម៉ែ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយមានការទទួលស្វាគមន៍យ៉ាងកក់ក្តៅពីលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាស្ថាបនិកព្រះរាជបណ្ណាល័យ ហ្លួងម៉ែ។

លោកជំទាវ អាលីស វៃរីម៉ូ ឌីរីទូ អញ្ជើញទស្សនកិច្ចព្រះរាជបណ្ណាល័យ ហ្លួងម៉ែ នៃមជ្ឈមណ្ឌលឯកសារកម្ពុជានៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៤ គឺមួយថ្ងៃមុនពេលលោកជំទាវ អញ្ជើញជាអធិបតី និងថ្លែងសុន្ទរកថាគន្លឹះនៅក្នុងពិធីបើកសន្និសីទលើកទី១ ស្តីអំពី «**អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍**»៖ ការពារ និងឆ្លើយតបតាមរយៈការអប់រំ និងការថែទាំសុខភាព នៅសាលយុត្តិតេជោ

បញ្ជាការដ្ឋានកងទ័ពជើងគោក នៃកងយោធពលខេមរភូមិន្ទ ក្រសួងការពារជាតិ (អតីតសាលសវនាការអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា) ដែលប្រព្រឹត្តឡើងពីថ្ងៃទី២០ ដល់ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤។

សន្និសីទលើកទី១ ស្តីអំពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍» នេះ រៀបចំដោយ ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា, មជ្ឈមណ្ឌលឯកសារកម្ពុជា និង សាលាច្បាប់ ប៊ឺសលី នៃសាកលវិទ្យាល័យ ថេមផល សហរដ្ឋអាមេរិក និងឧបត្ថម្ភដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ និងគាំទ្រដោយ បញ្ជាការដ្ឋានកងទ័ពជើងគោក នៃកងយោធពលខេមរភូមិន្ទ ក្រសួងការពារជាតិ។









លោកជំទាវ អាលីស វ៉ៃរីម៉ូ ឌឺរីទូ អគ្គលេខាធិការរង និងជាទីប្រឹក្សាពិសេសរបស់អង្គការសហប្រជាជាតិ ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ ទស្សនកិច្ចព្រះរាជបណ្ណាល័យ ហ្វូងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ខ្លឹមសារអត្ថន័យនៃព្រះរាជបណ្ណាល័យហ្វូងម៉ែ ដែលជាសំណង់ប្រវត្តិសាស្ត្រកម្ពុជាក្នុងសម័យទំនើប

**ឆាំង យុ**



រូបពីឆ្វេងទៅស្តាំ៖ លោក ប្រាយ យ៉ាន់ដេល អ្នករចនាប្លង់ស្ថាបត្យកម្ម, បណ្ឌិត ម៉ាគើស ហ្សីមម័រ សមាជិកក្រុមប្រឹក្សាភិបាលមជ្ឈមណ្ឌលឯកសារកម្ពុជា, សាស្ត្រាចារ្យ បណ្ឌិត សូ សុគន្ធារី ស្ថាបត្យករ, លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និង ជាស្ថាបនិកព្រះរាជបណ្ណាល័យហ្វូងម៉ែ, លោក ដេវីដ កាង អ្នករចនាប្លង់, លោក គ្រេក ខាន័រ នាយករងក្រុមហ៊ុនស្ថាបត្យកម្ម ហ្សាហា ហាឌីត នៅក្នុងកិច្ចប្រជុំស្តីពី សំណង់ស្ថាបត្យកម្ម ផ្សះផ្សា ការបំប្លែងពីភាពសោកសង្រេង មកជាក្តីសង្ឃឹម នៅសណ្ឋាគារ ហាយយ៉ាត់ រីជិនស៊ី កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ គឺជាសំណង់អគារ និម្មាបនកម្មស៊ីវិល័យ សម័យទំនើប ឈរយ៉ាងស្កឹមស្កៃលើទឹកដីអច្ឆរិយ ក្រោមម្លប់សន្តិភាព នាសម័យតេជោ អគ្គមគ្គទេសក៍ឯក និងជាស្ថាបនិកនយោបាយ ឈ្នះឈ្នះ នៃកម្ពុជា ជាបុព្វធីការី ដែលយកជីវិតជាដើមទុន ដើម្បីភាពសុខសាន្តត្រាន និងវឌ្ឍនភាពនៃទឹកដីជាតិមាតុភូមិ និងប្រជាពលរដ្ឋ។ ឆ្លងចូលមកដល់សម័យថ្នាក់ដឹកនាំជាបញ្ញវន្ត ដែលត្រូវបានទទួលស្គាល់ និងគាំទ្រក្លុកទឹកក្លុកដីពីប្រជាជាតិខ្មែរ និងបរទេស ដែលជាសន្ទានការីប្រកបដោយកតញ្ញុតាប្រាជ្ញាគតិបណ្ឌិត, ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ គឺជាកញ្ចក់ឆ្លុះឲ្យឃើញនូវសមិទ្ធផលជាសារវន្តដូចខាងក្រោម៖

- ជានិមិត្តរូបនៃការគោរពចំពោះវិញ្ញាណក្ខន្ធបុព្វបុរសខ្មែរគ្រប់ជំនាន់ ដែលបានស្លាប់បាត់បង់ជីវិតដោយសារសង្គ្រាមអាណានិគម សង្គ្រាមស៊ីវិល (សង្គ្រាមមនោគមវិជ្ជា) និងអំពើប្រល័យពូជសាសន៍
- ជានិមិត្តរូបនៃមនសិការជាតិប្រកបដោយកតញ្ញុតាវេទីចំពោះដូនតាខ្មែរ ដែលបានបន្សល់ទុកនូវទឹកដី អរិយធម៌ វប្បធម៌ សាសនា ប្រពៃណី និងសង្គមជាតិ



កិច្ចប្រជុំពិភាក្សា ស្តីអំពីសំណង់ស្ថាបត្យកម្មផ្សះផ្សា ការបំប្លែងពីភាពសោកសង្រេង មកជាក្តីសង្ឃឹមដោយមាន ការចូលរួមពីសិស្សស្ថាបត្យកម្មចំនួន ១៥០នាក់ នៅសណ្ឋាគារ ហាយយ៉ាត រីជិនស៊ី កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

- ជានិមិត្តរូបនៃបដិការគុណ ចំពោះពលិកម្មរបស់វីរជនយុទ្ធជនដូនតា និងព្រលឹងអាណោចអាធ័ម
- ជានិមិត្តរូបនៃការការពារសិទ្ធិ ស្វែងរកយុត្តិធម៌ជូនជនរួមឈាម ដែលបានស្លាប់យ៉ាងអាណោចអាធ័មក្នុងរបបអាវញ្ញវាសីបីឆ្នាំ ប្រាំបីខែ និងម្ភៃថ្ងៃ
- ជានិមិត្តរូបនៃទឡ្ហីករណ៍សមត្ថភាព គំនិត ប្រាជ្ញាញាណ និងពលានុភាព ខេមរា បច្ចាជនជំនាន់ថ្មី (យុវជន) អាចធ្វើបាន
- ជាភស្តុតាងនៃសាមគ្គីភាពក្រោមរដ្ឋធម្មនុញ្ញតែមួយ មហាសេ្នហ៍ក្សត្រតែមួយ រាជរដ្ឋាភិបាលតែមួយ កងកម្លាំងប្រដាប់អាវុធតែមួយ ដើម្បីរក្សាសន្តិភាព និងអភិវឌ្ឍន៍
- ធ្វើនវានុវត្តកម្មពីបុព្វការី (មនុស្សជំនាន់មុន) មកសន្តានការី (មនុស្សជំនាន់ថ្មី) ស្របតាមសត្យានុម័តភាពនៃសង្គម ក្នុងបរិបទសាកលភាវូបនីយកម្មសង្គម
- ស្តម្ភនៃកិត្យានុភាព ដែលពុំធ្លាប់មានពីបុព្វកាលទាំងក្នុងប្រទេសនិងពិភពលោក ដែលដូនតាបានបន្សល់ទុកនូវសម្បត្តិបេតិកភណ្ឌឲ្យកូនខ្មែរជំនាន់



កិច្ចប្រជុំពិភាក្សា ស្តីអំពីសំណង់ស្ថាបត្យកម្មផ្សះផ្សា ការបំប្លែងពីភាពសោកសង្រេង មកជាក្តីសង្ឃឹមដោយមាន ការចូលរួមពីសិស្សស្ថាបត្យកម្មចំនួន ១៥០នាក់ នៅសណ្ឋាគារ ហាយយ៉ាត រីជិនស៊ី កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រោយ ឯព្រះរាជបណ្ណាល័យ ហ្លួងម៉ែ ជាបណ្តុំឯកសារប្រាជ្ញាស្មារតីសម្រាប់មនុស្សជំនាន់ថ្មី និងជំនាន់បន្តបន្ទាប់

- ព្រះរាជបណ្ណាល័យ ហ្លួងម៉ែ មានអគារចំនួនប្រាំ ដែលមានឈ្មោះដូចខាងក្រោមនេះ ៖

  * សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និង សុភមង្គល
  * ព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា



កិច្ចប្រជុំពិភាក្សាស្ដីអំពីសំណង់ស្ថាបត្យកម្មផ្សះផ្សា ការបំប្លែងពីភាពសោកសង្រេង មកជាក្ដីសង្ឃឹមដោយមានការចូលរួមពីសិស្សស្ថាបត្យកម្មចំនួន ១៥០នាក់ នៅសណ្ឋាគារ ហាយយ៉ាត រីជិនស៊ី កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

*** សម្ដេច អគ្គមហាសេនាបតី តេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

*** សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន**

*** សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

នៅថ្ងៃទី២២ ខែឧសភា លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំការប្រជុំនិងពិភាក្សាទៅលើប្រធានបទការផ្សះផ្សា ដោយផ្ដោតសំខាន់ទៅលើ ស្ថាបត្យកម្មក្នុងការបំប្លែងពីភាពសោកសង្រេង មកជាក្ដីសង្ឃឹម ជាមួយនិស្សិតស្ថាបត្យកម្មចំនួន ១៥០នាក់, សាស្ត្រាចារ្យបណ្ឌិត សូ សុគន្ធារី ស្ថាបត្យករ, លោក ដេវ៉ា កាង វិស្វករផ្នែករចនាប្លង់មកពីប្រទេសអង់គ្លេស, លោក គ្រេក ខានរ័ នាយករងក្រុមហ៊ុន ហ្វាហា ហាឌីដ មកពីប្រទេសអង់គ្លេស, លោក ប្រាយយ៉ាន់ ដេល អ្នករចនាប្លង់ស្ថាបត្យកម្មសិតស្ដូឌីយូ មកពីសហរដ្ឋអាមេរិក និងបណ្ឌិត ម៉ាគើស ហ្សីមម័រ សមាជិកក្រុមប្រឹក្សាភិបាលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅសណ្ឋាគារ ហាយយ៉ាត់ រីជិនស៊ី ក្នុងទីក្រុងភ្នំពេញ។

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតែងតែផ្ញើបច្ចុប្បន្នភាពលើគម្រោងសាងសង់នេះជូនដល់រាជរដ្ឋាភិបាលកម្ពុជា និងទូលថ្វាយសម្ដេចព្រះមហាក្សត្រី នរោត្ដម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្ដីថ្លៃថ្នូរ និង សុភមង្គល និងគោរពជម្រាបជូនខុទ្ទកាល័យសម្ដេចបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា, សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានក្រុមឧត្ដមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា។

# ផ្លោក អ៊ិត ហៅ ខា ៖ លេខាវរសេនាតូច៧០៤ កងពល១៧៤

**មីន សាណាស់**



កងយោធាខ្មែរក្រហមនៅសមរភូមិ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ផ្លោក អ៊ិត ហៅ ខា ភេទប្រុស អាយុ២៣ឆ្នាំ (១៩៧៧) ស្រុកកំណើតនៅភូមិវាល ឃុំទ្រា ស្រុកស្ទោង ខេត្តកំពង់ធំ។ ក្នុងអាយុ១២ឆ្នាំ ខា បានចូលរៀននៅសាលាវត្តហប់ ឃុំទ្រា។ រៀនបានដល់ថ្នាក់ទី៩ ខា ក៏ឈប់រៀន រួចមកជួយធ្វើការរកស៊ីឪពុកម្ដាយនៅផ្ទះរហូតដល់ឆ្នាំ១៩៧០។ ខា ត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៧ ដែលមានឯកសារចម្លើយសារភាពចំនួន២៥ទំព័រ។ ខា ត្រូវទទួលបទចោទធ្ងន់ធ្ងរពីអង្គការគឺ ការរៀបចំផែនការវាយយកភូមិភាគកណ្ដាល។ ខាងក្រោមនេះជាការដកស្រង់ចេញពីសេចក្ដីរាយការណ៍របស់អ្នកសួរឈ្មោះ មាក និង ហេង ក្នុងមន្ទីរស-២១ ជូនកម្មាភិបាលថ្នាក់លើ អំពីករណីរបស់ ផ្លោក អ៊ិត ហៅ ខា គឺ៖

## សកម្មភាពមុនរំដោះ

ខែមិថុនា ឆ្នាំ១៩៧០ ខា ចូលធ្វើជាឈ្លបភូមិវាល ឃុំទ្រា ដោយមានឈ្មោះ មាស អតីតជាមេចោរព្រៃ (ឆ្នាំ១៩៧៣ ជាប្រធានឃុំទ្រា ស្រុកស្ទោង បច្ចុប្បន្នក្បាប់មិនបាន) ជាអ្នកនាំចូល។ ខា ធ្វើការជាឈ្លបបានបីខែ មាស បានអប់រំ ខា ថា បដិវត្តន៍លំបាក និងលើកពីកម្លាំងខ្មែរស ខ្លាំង អាចវាយបដិវត្តន៍ឈ្នះ រួចក៏ហៅ ខា ចូលធ្វើជាខ្មែរស។ បន្ទាប់មកឈ្មោះ មាស បាននាំ ខា ឲ្យទៅជួបឈ្មោះ កេង អតីតជាចោរព្រៃ (ឆ្នាំ១៩៧៣ ជាប្រធានភូមិដងតាអែក) ដើម្បីរួមគ្នាធ្វើសកម្មភាពកសាងកម្លាំងខ្មែរស។ សកម្មភាព

កសាងកម្លាំងនេះ ក៏អប់រំកសាងបានចំនួនបីនាក់គឺ ខុម, យន់ និង យាន។

ឆ្នាំ១៩៧១ មាស បានណែនាំ ខា ឲ្យស្គាល់ខ្មែរខ្មែរស ដែលមានឈ្មោះ ថូ, ហែម និង វ៉ា។ ក្រោយពីស្គាល់គ្នារួច ក៏ចុះធ្វើសកម្មភាពសម្រាប់គណៈឃុំចំណាលិច។ តែសកម្មភាពនេះត្រូវបែកការណ៍ អង្គការក៏កម្ទេចកម្លាំងឲ្យបែកគ្នាអស់។

ឆ្នាំ១៩៧៣ ខា ធ្វើជាប្រធានក្រុមឈ្លបឃុំវាល ក៏ជាឆ្នាំដែល មាស, ថូ និង ហែម បញ្ចូល ខា ទៅជាសមាជិក សេ-អ៊ី-អា។ ក្នុងតួនាទីជាសមាជិក សេ-អ៊ី-អា ខា ត្រូវកសាងកម្លាំង សេ-អ៊ី-អា ឲ្យចូលបង្កប់ខ្លួនក្នុងជួរបដិវត្តន៍ និងត្រូវបំផ្លាញចលនាបដិវត្តន៍។ ចំណែកអង្គការក៏ដឹកនាំឈ្មោះ សាំ, វ៉ា និង ខា ចូលកងវរសេនាតូច៤០៥ នៅក្នុងតំបន់៤២។ បន្ទាប់មកឈ្មោះ សាំ, វ៉ា និង ខា ក៏ទៅភ្ជាប់ខ្សែទាក់ទងថ្មី មានឈ្មោះ ខឿន អតីតគ្រូបង្រៀន, រាប មានតួនាទីជាប្រធានវរសេនាធំ៦០១ កងពល១៧៤ និង អុល អនុវរសេនាតូច៤០៥។ ក្រោយមកទៀត រាប បានចាត់តាំង ខា ឲ្យទាក់ទងឈ្មោះ យឿន។ យឿន បាននាំ ខា ឲ្យស្គាល់ឈ្មោះ ឆាយ មានតួនាទីក្នុងឆ្នាំ១៩៧៤ ជាប្រធានកងពិសេសវរសេនាតូច៤០៨ និង យ៉េន អតីតជាទាហានឲ្យចូលរួមធ្វើសកម្មភាពបំផុសយុវជនរត់ទៅតំបន់ខ្មាំងអស់ចំនួន ៩ នាក់។

ឆ្នាំ១៩៧៤ រាប បាននាំ ខា ឲ្យស្គាល់ ស៊ីម គឺជាប្រធានវរសេនាធំ៣៣ កងពល១១៧។ តាមរយៈ ស៊ីម, ខា បានស្គាល់ខ្សែរយៈ សេ-អ៊ី-អា ថ្មីទៀតមានឈ្មោះ អែក មាននាទីជាអនុវរសេនាតូច៧០៤ វរសេនាធំ៦០ កងពល១៧៤។ ដល់ខែមេសា ឆ្នាំ១៩៧៤ អង្គការស្រាប់តែដកអង្គភាព៤០៧ ឲ្យទៅការពារប្រជាជននៅស្រុកតាំងគោក តំបន់៤២ ក្នុងពេលនោះ រាប ក៏បានហៅ វ៉ា, ស្វាញ, អែក និង ខា មកប្រជុំដាក់ផែនការថ្មីគឺ៖ បំផុសចលនាប្រជាជនឲ្យរត់ចូល ទាហាន បង្កទំនាស់ជាមួយកងទ័ពស្រុក និងកម្ទេចប្រជាជនដែលស្រឡាញ់បដិវត្តន៍។ ក្រោយពីទទួលផែនការថ្មី ខា និង បក្ខពួកខាងលើ បានបង្កទំនាស់បាញ់គ្នាទៅវិញទៅមកជាមួយកងទ័ពស្រុកតាំងគោក ចលនាប្រជាជនរត់ចូលតំបន់ខ្មាំងអស់ ៣០គ្រួសារ ចាប់ប្រជាជនដែលស្រឡាញ់បដិវត្តន៍យកទៅសម្លាប់ចោលអស់២គ្រួសារ។ ដល់ខែកក្កដា ឆ្នាំ១៩៧៤ អង្គការដក ខា និង រាប មកនៅវរសេនាតូច៤១០ តំបន់៤២។ មកដល់អង្គភាពថ្មី រាប បាននាំ ខា ទៅ ទាក់ទងឈ្មោះ វ៉ាត នាទីអនុវរសេនាតូច៤១០ កងតំបន់៤២។ សែ នាទីអនុនយោបាយវរសេនាតូច៧០១។ នា នាទីអនុយោធាវរសេនាតូច៧០១។ អ៊ិន អនុក្រុមវរសេនាតូច៧០១។ ស្រួយ នាទីប្រធានក្រុមវរសេនាតូច៧០១។ សឿន យោធាវរសេនាតូច៧០១។ ក្រាញ់ សមាជិកវរសេនាតូច៧០១។ ផា មេក្រុមវរសេនាតូច៧០១។ ណៃ យុវជនវរសេនាតូច៧០១។ វ៉ាន់ មេក្រុមវរសេនាតូច៧០១។ ស្រ៊ុន មេក្រុមវរសេនាតូច៧០១។

**សកម្មភាពក្រោយរំដោះ**

ឆ្នាំ១៩៧៥ ក្រោយថ្ងៃរំដោះបានទីក្រុងភ្នំពេញ រាប និង ស៊ីម បានហៅកម្លាំង សេ-អ៊ី-អាទាំងអស់ប្រជុំដាក់ផែនការថ្មី ដោយមានសមាជិកចូលរួមដូចជា ខា, សែ, នា, អែក, ស្វាញ, នីន និងកម្លាំងថ្មីបន្ថែមម្នាក់ទៀតឈ្មោះ ហេង ជាអតីតគ្រូបង្រៀន បច្ចុប្បន្នជាអនុលេខាវរសេនាតូច៧០១ វរសេនាធំ៦០១ កងពល១៧៤ (អង្គការចាប់ក្នុងឆ្នាំ១៩៧៧)។ ខ្លឹមសារក្នុងការប្រជុំ គឺលើកផែនការចំនួន២៖ គឺ១) ដុតបំផ្លាញសម្ភារក្នុងក្រុងកំពង់ចាម និង២) ជម្លៀសទាហានយកទៅប្រគល់ឲ្យឈ្មោះ គុល មានតួនាទីជាលេខាតំបន់៤២ ទុកត្រៀមវាយបកមកអង្គការវិញ។ ក្រោយទទួលផែនការរួច ខា, សែ និង នា បានដឹកនាំកម្លាំង១០នាក់ ធ្វើសកម្មភាពដុតផ្ទះថ្មចោលអស់ ៥ និង ដុតគ្រាប់បែកអស់ចំនួន ១០៥គ្រាប់ ឆេះអស់មួយឃ្លាំង។ ចំណែកសមាជិកដទៃទៀត ទៅប្រមូលទាហានពីក្រុងកំពង់ចាមបានចំនួន៥០នាក់ យកទៅប្រគល់ឲ្យឈ្មោះ គុល តាមខ្លឹមសារប្រជុំ ដោយលាក់ទុកនៅក្នុងភូមិព្រៃសំភាស ឃុំទួលឃ្លាំង ស្រុកស្ទឹងត្រង់។

ឆ្នាំ១៩៧៦ ខា និងបក្ខពួកបានបាញ់កាណូតដឹកសម្ភារមួយគ្រឿងឲ្យលិចនៅកណ្ដាលទន្លេដោយ



កងយោធាខ្មែរក្រហមនៅសមរភូមិ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

យកលេសថា កាណូតហៅមិនឈប់។ ខ បានលួចទាក់ទងចោរព្រៃចំនួន៣០នាក់ ឲ្យចូលមកលួចអង្ករប្រជាជននៅឃុំក្រឡា ស្រុកកំពង់សៀម។

ដើមឆ្នាំ១៩៧៧ ក្រុមរបស់ ខ រៀបចំផែនការសហការជាមួយកងទ័ពតំបន់សៀមរាប ដែលមានឈ្មោះ សុត លេខាតំបន់សៀមរាប, ហ៊ាន លេខាកងពលទ័ពតំបន់សៀមរាប ជាអ្នកដឹកនាំវាយ។ បន្ទាប់មក ខ និង ស៊ីមបានទៅទាក់ទងឈ្មោះ សារ៉ាយ, សារិន, យន និង ដួង រួមធ្វើសកម្មភាពរៀបចំកាំភ្លើងធំនៅភូមិខ្សា ត្រៀមមុខសញ្ញាវាយវរសេនាធំ៦០១ វាយពីព្រៃដើមចាន់ វត្តថ្មី ភ្នំប្រុស ភ្នំស្រី ចូលមកក្រុងកំពង់ចាម។ ចំណែកមុខសញ្ញាវរសេនាធំ៦០២ ចាប់ពីវាលវង់ ដំរីសារុម ថ្មគោល វាយចូលក្រុងកំពង់ធំ។ ផែនការមិនទាន់បានសម្រេចផង អង្គការបានចាប់ខ្លួន ដួង, សារ៉ាយ, ស៊ីម និង វ៉េង។ ខែឧសភា ឆ្នាំ១៩៧៧ រៀបបានចាត់តាំង ខ, សែ, នា, ឯក, វ៉ាន់ និងស្រួយឲ្យធ្វើសកម្មភាពដុតស្រូវក្នុងលាន ឆេះអស់ស្រូវ១០០ថាំង និងលួចដុតស្រូវក្នុងស្រែ ឆេះអស់ស្រូវ១០ហិកតា។ ខែមិថុនា ឆ្នាំ១៩៧៧ អង្គការបានដកអង្គភាពវរសេនាតូច៧០១ របស់ ខ ឲ្យមកការពារផ្លូវជាតិលេខ៧ នៅតំបន់៤១។ ក្នុងឱកាសនោះ ក្រុមកម្លាំង ខ បានទាក់ទងឈ្មោះ ហេង អនុលេខាស្រុកព្រៃឈរឲ្យរួមគ្នា ទាក់ទងយកកម្លាំងចោរព្រៃ ដើម្បីមកធ្វើសកម្មភាពក្នុងស្រុកកងមាស។ តែកម្លាំងចោរព្រៃត្រូវអង្គការកម្ទេចនៅចុងខែមិថុនា។ បន្ទាប់ពីកម្ទេចក្រុមចោរព្រៃរួច អង្គការក៏ដកអង្គភាព ខ ឲ្យមកក្រុងកំពង់ចាមវិញ។ បន្តពីនេះអង្គការចាប់ផ្តើមចាប់ខ្លួនសមាជិក សេ-អ៊ី-អា ជាបន្តបន្ទាប់។ រហូតដល់ខែកញ្ញា ឆ្នាំ១៩៧៧ រាប បានចាត់តាំងឲ្យ ខ បាញ់យុទ្ធជនឈ្មោះ សោម ចោល ព្រោះយុទ្ធជនរូបនេះបានក្តាប់ផែនការ សេ-អ៊ី-អា បាន។ ក្រោយពី ខ បាញ់ សោម រួច អង្គការក៏ចាប់ខ្លួន ខ នៅក្នុងថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៧។

**កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីចម្លើយសារភាពឯកសារ J00៦២៦។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំនិងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ ផ្ងៅក អ៊ិត ហៅ ខ ពិត ប៉ុណ្ណោះទេ?**

# សាលយុត្តិតេជោ

**ឆាំង យុ**




អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចូលរួមសន្និសីទលើកទី១ ស្តីពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍» ដែលប្រព្រឹត្តឡើងពីថ្ងៃទី ២០-២២ ខែឧសភា ឆ្នាំ២០២៤ នៅសាលយុត្តិតេជោ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សាលយុត្តិតេជោ គឺជាទីតាំងប្រវត្តិសាស្ត្រដែលធ្លាប់ជាសាលសវនាការមួយ ក្នុងចំណោមសាលសវនាការមួយចំនួនតូចនៅលើពិភពលោកបម្រើកិច្ចការយុត្តិធម៌និងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ មិនតែប៉ុណ្ណោះទៀតសោតសាលយុត្តិតេជោ ត្រូវបានចាត់ទុកថាជាសាលសវនាការមួយនៅក្នុងចំណោមសាលសវនាការមួយចំនួនតូច ដែលគាំទ្រដល់ការកាត់ទោសប្រកបដោយជោគជ័យលើបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។

សាលយុត្តិតេជោ នៅដើមដំបូងឡើយត្រូវបានកសាង និងប្រើប្រាស់ជាសាលសន្និសីទសម្រាប់កងយោធពលខេមរភូមិន្ទ។ នៅក្នុងឆ្នាំ២០០៦ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បញ្ជូនិងសម្រេចប្រគល់ទីតាំងនេះឲ្យទៅអង្គការសហប្រជាជាតិ ដើម្បីប្រើប្រាស់ជាសាលសវនាការដែលគ្រប់គ្រងរួមគ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិក្នុងការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម។ សាលសវនាការដែលបង្កើតឡើងនេះមានឈ្មោះជាផ្លូវការថា៖ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលស្គាល់ជាទូទៅថាសាលាក្តីខ្មែរក្រហម។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបង្កើតឡើងដើម្បីគាំទ្រដល់ដំណើរការកាត់ទោស

ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយមេដឹកនាំជាន់ខ្ពស់ នៃរបបកម្ពុជាប្រជាធិបតេយ្យ និងបុគ្គលទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់ជាតិ និងអន្តរជាតិ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ (ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៩)។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចាប់បដិសន្ធិចេញពីកិច្ចសហការរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ហើយគឺជាសាលាក្តីចម្រុះដំបូងបង្អស់នៅលើពិភពលោកដែលបង្កើតឡើងក្រោមច្បាប់ជាតិនិងច្បាប់អន្តរជាតិ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតំណាងឲ្យសេចក្តីប្តេជ្ញារបស់រាជរដ្ឋាភិបាលកម្ពុជា និងសហគមន៍អន្តរជាតិក្នុងការស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជា ដែលបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម អ្នកទទួលរងទុក្ខវេទនា និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលបានប្រាប់រឿងរ៉ាវអំពីជីវិតរបស់ខ្លួន។ មានការប៉ាន់ប្រមាណថា ប្រជាជនកម្ពុជាជាងពីរលាននាក់ដែលបានបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ហើយមានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមប្រមាណជាប្រាំលាននាក់ដែលរស់នៅសព្វថ្ងៃនេះ និងបានបន្តរៀបរាប់ប្រាប់រឿងរ៉ាវជីវិតរបស់ខ្លួន។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទទួលខុសត្រូវលើដំណើរការកាត់ទោសប្រកបដោយជោគជ័យទៅលើមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម និងបុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។

សាលយុត្តិតេជោ គឺជាទីតាំងប្រវត្តិសាស្ត្រដ៏សំខាន់សម្រាប់ការចងចាំនូវរឿងរ៉ាវ និងការងារដែលពាក់ព័ន្ធជាមួយសំណុំរឿងរបស់សាលាក្តីខ្មែរក្រហម ក៏ដូចជាដំណើរដ៏លំបាកលំបិនក្នុងការស្វែងរកយុត្តិធម៌ ដែលបន្តរហូតមកដល់សព្វថ្ងៃ។ នៅក្នុងឆ្នាំ២០២២ បន្ទាប់ពីប្រតិបត្តិការ ការងារអស់រយៈពេល១៦ឆ្នាំ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបិទបញ្ចប់បេសកកម្មជាប្រវត្តិសាស្ត្ររបស់ខ្លួនហើយបានប្រគល់ជូនសាលនេះទៅកាន់កងយោធពលខេមរភូមិន្ទវិញ។ បន្ទាប់ពីការប្រគល់សាលយុត្តិតេជោមកបញ្ជាការដ្ឋានកងទ័ពជើងគោកវិញ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត អតីតអគ្គមេបញ្ជាការរង មេបញ្ជាការកងទ័ពជើងគោក នៃកងយោធពលខេមរភូមិន្ទបានមានអនុសាសន៍ផ្តែផ្តាំថា សាលយុត្តិតេជោ នេះត្រូវតែរក្សាទុក ដើម្បីជាប្រវត្តិសាស្ត្រសម្រាប់ប្រជាជនកម្ពុជាជំនាន់ក្រោយឲ្យបានយល់អំពីដំណើរការកាត់ទោសអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម។







លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា, ភ្ញៀវកិត្តិយស និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចូលរួមសន្និសីទលើកទី១ ស្តីពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍» ដែលប្រព្រឹត្តឡើងពីថ្ងៃទី២០-២២ ខែឧសភា ឆ្នាំ២០២៤ នៅសាលយុត្តិតេជោ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ពួយ ម៉ុក ៖ ផ្ដល់បទសម្ភាសន៍ដល់យុវជន និងអ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តពោធិ៍សាត់

*លី រ៉ាឌី*



ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង យុវជន និងអ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តពោធិ៍សាត់ទាំង៣៨ នាក់ បានធ្វើដំណើរចេញពីទីក្រុងកំពតឆ្ពោះទៅកាន់ភូមិពស់ពង ឃុំនារាយណ៍ ស្រុកឈូក ខេត្តកំពត ដើម្បីជួបសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។
( ធី គីម ហុង/មជ្ឈមណ្ឌលឯកសារកម្ពុជា )

ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង យុវជន និងអ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តពោធិ៍សាត់ ចំនួន៣៨ នាក់ បានធ្វើដំណើរចេញពីទីក្រុងកំពត ឆ្ពោះទៅកាន់ភូមិពស់ពង ឃុំនារាយណ៍ ស្រុកឈូក ខេត្តកំពត ដើម្បីចុះជួបសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ខាងក្រោមនេះ គឺជារឿងរ៉ាវសង្ខេបរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម៖

ខ្ញុំបាទឈ្មោះ ពួយ ម៉ុក អាយុ៨៥ឆ្នាំ មានស្រុកកំណើតនៅភូមិព្រៃស្បូវ ឃុំនារាយណ៍ ស្រុកឈូក ខេត្តកំពត។ បច្ចុប្បន្នខ្ញុំរស់នៅភូមិពស់ពង ឃុំនារាយណ៍ ស្រុកឈូក ខេត្តកំពត។ ខ្ញុំមានឪពុកឈ្មោះ ពួយ ខាន់ និង ម្ដាយឈ្មោះ ប្រាក់ ភាន់។ ខ្ញុំមានបងប្អូនចំនួន៦នាក់ ក្នុងនោះប្រុសចំនួន៥នាក់ និងស្រីម្នាក់។ ខ្ញុំរៀបការប្រពន្ធទី១ ឈ្មោះ លក ហ៊ិន និង មានកូនចំនួន៣នាក់ គឺប្រុស១នាក់ និងស្រី២នាក់។ ប្រពន្ធទី២ ឈ្មោះ សេក វ៉ាន់សី អាយុ៦៥ឆ្នាំ និង មានកូនស្រី២នាក់។

ខ្ញុំចូលរៀនក្នុងឆ្នាំ១៩៦០ នៅសាលាបឋមសិក្សាវត្តទល់។ ខ្ញុំរៀនបានត្រឹមថ្នាក់ទី៧ចាស់។

នៅឆ្នាំ១៩៦៧ ខ្ញុំក៏ឈប់រៀន ហើយត្រឡប់មកជួយធ្វើការងារឪពុកម្ដាយនៅស្រុកកំណើតៗ នៅក្នុងព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ខ្ញុំរស់នៅក្នុងស្រុកកំណើតជាធម្មតាៗ រហូតដល់ឆ្នាំ១៩៧៤ កងទ័ពរំដោះខ្មែរក្រហមបានវាយដណ្ដើមបានខេត្តកំពតៗ ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ខ្ញុំត្រូវបានខ្មែរក្រហមចាត់ឲ្យធ្វើជាប្រធានសហករណ៍ភូមិស្ថិតនៅភូមិព្រៃស្បូវ ឃុំនារាយណ៍ ស្រុកឈូក ខេត្តកំពតៗ ខ្ញុំត្រូវមើលការខុសត្រូវលើប្រជាជនចំនួន ២០០នាក់ លើការដាំដុះស្រូវ ចិញ្ចឹមសត្វ និងរកម្ហូបអាហារផ្សេងៗសម្រាប់បញ្ជូនទៅតាមការដ្ឋានលើកទំនប់ម្ដេចៗ ចំពោះអាហារហូបចុករបស់ខ្ញុំក្នុងរបបខ្មែរក្រហមមិនមានអ្វីជាបញ្ហាចោទនោះទេ ព្រោះមានការហូបចុកបានសមរម្យៗ ចំណែកពេលឈឺ គឺត្រូវទៅព្យាបាល តែមិនមានការព្យាបាលត្រឹមត្រូវច្បាស់លាស់នោះទេ គឺត្រូវប្រើថ្នាំបុរាណៗ ចំពោះស្ថានភាពអំឡុងពេលនោះ ខ្ញុំមិនដែលបានឃើញការធ្វើទារុណកម្ម ការបំផ្លាញវត្តអារាម និងព្រះពុទ្ធបដិមាអ្វីនោះទេៗ

បន្ទាប់ពីរបបខ្មែរក្រហមដួលរំលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ខ្ញុំត្រូវបានខ្មែរក្រហមកៀរទៅខេត្តពោធិ៍សាត់ៗ ខ្ញុំរស់នៅក្នុងខេត្តពោធិ៍សាត់ បានប្រមាណជា២ខែ ក៏លួចរត់មកស្រុកកំណើតវិញតាមខ្នងភ្នំឱរ៉ាល់ជួរភ្នំក្រវាញៗ នៅពេលមកដល់ស្រុកកំណើត ខ្ញុំក៏ត្រូវបានកងទ័ពវៀតណាមចាប់ខ្លួន និងបញ្ជូនខ្ញុំទៅដាក់គុកនៅខេត្តហាទៀង ប្រទេសវៀតណាមប្រហែលជា ២ទៅ៣ខែ រួចបន្តទៅដាក់គុកនៅខេត្តមាត់ជ្រូក និងចុងក្រោយកងទ័ពវៀតណាមបានយកខ្ញុំមកដាក់គុកនៅស្រុកកោះអណ្ដែត ខេត្តតាកែវ អស់រយៈពេល៩ឆ្នាំៗ នៅឆ្នាំ១៩៨៩ ខ្ញុំត្រូវបានដោះលែងៗ ពេលជាប់គុកនោះ ខ្ញុំត្រូវបានវៀតណាមប្រើអំពើហិង្សាមកលើរូបខ្ញុំដូចជាវាយដំ ទាត់ធាត់ រហូតបានបន្សល់ស្លាមនៅលើក្បាលផ្នែកខាងក្រោយៗ សព្វថ្ងៃនេះ នៅពេលដែលខ្ញុំនឹកដល់របបខ្មែរក្រហម ខ្ញុំមានអារម្មណ៍ឈឺចាប់ និងនៅតែមិនយល់ថា ហេតុអ្វីបានជាខ្មែរក្រហមបំផ្លិចបំផ្លាញជាតិខ្លួនឯងបែបនេះៗ







ក្រុមការងារនៃមជ្ឈមណ្ឌលផ្សះផ្សាវាលវែង យុវជន និងអ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តពោធិ៍សាត់ចំនួន៣៨នាក់ បានធ្វើដំណើរចេញពីទីក្រុងកំពតឆ្ពោះទៅកាន់ភូមិពស់ពង ឃុំនារាយណ៍ ស្រុកឈូក ខេត្តកំពត ដើម្បីជួបសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមៗ
( ធី គឹមហុង/មជ្ឈមណ្ឌលឯកសារកម្ពុជា )

# ម៉ី កុប ៖ ចែករំលែកចំណេះដឹងពីការថែទាំសុខភាព និងរឿងរ៉ាវឆ្លងកាត់របបខ្មែរក្រហម ទៅកាន់កូនៗ និងចៅៗ

ផេង ពង្សរ៉ាស៊ី



ម៉ី កុប អាយុ៨៦ឆ្នាំ ជនជាតិខ្មែរ សព្វថ្ងៃរស់នៅភូមិវាល ឃុំក្តាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ម៉ី កុប ភេទប្រុស អាយុ៨៦ឆ្នាំ ជនជាតិខ្មែរ សព្វថ្ងៃរស់នៅភូមិវាល ឃុំក្តាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ ខ្ញុំមានជីវភាពរស់នៅមធ្យម ដោយសារមានកូនប្រុសស្រីគឺជាអ្នកចិញ្ចឹមខ្ញុំ។ សព្វថ្ងៃ ខ្ញុំមានសុខភាពមិនសូវល្អទេ និងមានជំងឺលើសឈាម។

ខ្ញុំធ្លាប់បានចូលរួមកម្មវិធីដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជាចំនួនពីរដង។ លើកទីមួយ ខ្ញុំបានជួបជាមួយចៅស្រីម្នាក់មកសួរនាំខ្ញុំអំពីប្រវត្តិឆ្លងកាត់ពីរបបខ្មែរក្រហម និងអំពីសុខភាពរបស់ខ្ញុំនាពេលបច្ចុប្បន្ន។ ក្នុងពេលសម្ភាសន៍ ខ្ញុំបានរៀបរាប់ពីរឿងរ៉ាវដែលខ្ញុំធ្លាប់បានឆ្លងកាត់របបខ្មែរក្រហម។ ខ្ញុំបានប្រាប់ពីការធ្វើការងារ ដែលខ្មែរក្រហមបានប្រើខ្ញុំឲ្យធ្វើមិនមានពេលឈប់សម្រាក។ ខ្ញុំបានទៅកាត់ស្មៅនៅអន្តរបូរីអស់រយៈពេលមួយខែ ហើយបានបន្តជីកព្រែកចាប់ពីទំនប់អន្តរបូរី រហូតដល់ព្រែកគ្រោត។ មួយវិញទៀត ខ្មែរក្រហមមិនឲ្យខ្ញុំហូបបាយឆ្អែតទេ។ ខ្ញុំពេញចិត្តចំពោះការផ្តល់កិច្ចសម្ភាសន៍ដល់ចៅស្រីនោះ ព្រោះក្មេងៗគួរតែឈ្វេងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម។

ចំពោះការជួបលើកទីពីរ គឺតាមរយៈមេឃុំក្តាញ់។ មេឃុំបានមកកាន់ផ្ទះខ្ញុំ ហើយប្រាប់ព័ត៌មានថា ខ្ញុំត្រូវទៅចូលរួមក្នុងកម្មវិធីវេទិកាអប់រំសុខភាព ពិនិត្យសុខភាព និងពិគ្រោះយោបល់អំពីបញ្ហាសុខភាព នៅក្នុងភូមិសម្តេចពាន។ មិនមានកូនចៅខ្ញុំណាម្នាក់ហាមឃាត់ខ្ញុំមិនឲ្យទៅចូលរួមទេ។ កូនចៅរបស់ខ្ញុំថែមទាំងប្រាប់ខ្ញុំថា ពួកគាត់សប្បាយចិត្តជំនួសខ្ញុំ ព្រោះខ្ញុំបានទៅពិនិត្យសុខភាពដោយមិនអស់ប្រាក់។ ខ្ញុំពេញចិត្តនឹងចូលរួមកម្មវិធីនេះណាស់ ព្រោះកម្មវិធីនេះបានធ្វើឲ្យខ្ញុំបានដឹងអំពីជំងឺផ្ទាល់ខ្លួន និងបានដឹងពីរបៀបថែទាំសុខភាព។ មុនពេលចូលរួមក្នុងកម្មវិធី ខ្ញុំសង្ឃឹមថា ខ្ញុំនឹងទទួលបានថ្នាំពេទ្យមកព្យាបាលជំងឺ ទទួលបានសេវាពិនិត្យសុខភាពដោយមិនអស់ប្រាក់ និងទទួលបានការអប់រំពីបញ្ហាសុខភាព។ មេឃុំបានប្រាប់ខ្ញុំថា

ខ្ញុំនឹងទទួលបានសេវាពិនិត្យសុខភាព ប៉ុន្តែខ្ញុំគិតថា បើមានការពិនិត្យសុខភាព គឺប្រាកដជាទទួលបានថ្នាំព្យាបាលដែរ។

នៅថ្ងៃដែលត្រូវទៅទទួលសេវាពិនិត្យសុខភាព គឺខ្ញុំទទួលបានការឧបត្ថម្ភលើការធ្វើដំណើរថែមទៀត។ ខ្ញុំមិនមានអារម្មណ៍ថាធុញទ្រាន់ចំពោះការមកទទួលសេវាពិនិត្យសុខភាពនេះទេ។ ខ្ញុំមានតែការសប្បាយចិត្ត។ ចំពោះការចូលរួមកម្មវិធី ខ្ញុំបានយល់ដឹងពីការថែទាំសុខភាព ជាពិសេសថែទាំជំងឺប្រចាំកាយដែលកំពុងកើតមានរាល់ថ្ងៃដោយខ្លួនឯង។ ខ្ញុំបានដឹងថា តើម្ហូបអាហារអ្វីដែលខ្ញុំត្រូវហូប និងត្រូវតម។ ខ្ញុំបានយល់ដឹងពីទីកន្លែង ឬមន្ទីរពេទ្យដែលខ្ញុំត្រូវទៅទទួលសេវាពិនិត្យសុខភាពឬព្យាបាលជំងឺ។ ពេលចូលរួមកម្មវិធីខ្ញុំទទួលបានការពិនិត្យសុខភាពដោយមិនអស់ប្រាក់ ស្តាប់ការអប់រំអំពីការថែទាំសុខភាព និងទទួលបានសោហ៊ុយធ្វើដំណើរទៅចូលរួមកម្មវិធី។

បន្ទាប់ពីបានចូលរួមក្នុងកម្មវិធីនេះ ខ្ញុំបានចែករំលែកទៅកាន់កូនចៅ ទាំងអស់គ្នាឲ្យចេះថែទាំសុខភាពកុំឲ្យមានជំងឺ និងយល់ដឹងពីរបៀបប្រើប្រាស់ថ្នាំពេទ្យ និងថែរក្សាខ្លួនឲ្យចៀសឆ្ងាយពីជំងឺ។ ខ្ញុំចាស់ណាស់ទៅហើយ អារម្មណ៍ចងចាំ ក៏មិនមានការចងចាំបានយូរដែរ។ ដូច្នេះ ពេលដែលកូនៗចៅៗខ្ញុំយល់ដឹងពីវិធីថែទាំសុខភាព កូនៗនិងចៅៗនឹងរំឭកខ្ញុំគ្រប់ពេល ទាំងពេលហូបចុក និងថែទាំជំងឺ។ ឥឡូវខ្ញុំមានសុខភាពធូរស្រាលជាងមុន។ ជំងឺលើសឈាមរបស់ខ្ញុំលែងសូវធ្វើទុក្ខដូចមុនទៀតហើយ។ ខ្ញុំនៅតែចង់បន្តឲ្យមានកម្មវិធីនេះទៀត ព្រោះដើម្បីឲ្យមនុស្សគ្រប់គ្នាបានដឹងពីរបៀបថែទាំសុខភាព។

## រឿងរ៉ាវឆ្លងកាត់របបខ្មែរក្រហម

ខ្ញុំមានបងប្អូនបង្កើតចំនួន ៨ នាក់ ប៉ុន្តែស្លាប់អស់ហើយ នៅតែខ្ញុំម្នាក់ប៉ុណ្ណោះ។ ខ្ញុំគឺជាកូនទី៧ក្នុងគ្រួសារ។ ក្នុងរបបខ្មែរក្រហម ខ្ញុំបានធ្វើការក្នុងកងភ្ជួរក្នុងភូមិ។ ខ្មែរក្រហមប្រើខ្ញុំឲ្យធ្វើការមិនដែលមានពេលឈប់សម្រាកឡើយ។ នៅវេលាម៉ោង១២យប់ក៏ខ្ញុំត្រូវឡើងទៅភ្ជួរស្រែដែរ។ ចំពោះការហូបចុកវិញ ខ្ញុំមិនដែលទទួលបានការហូបចុកគ្រប់គ្រាន់ឡើយ គឺមានតែបបរបីវែកតែប៉ុណ្ណោះ។ បន្ទាប់មកទៀត ខ្មែរក្រហមបានប្រើខ្ញុំឲ្យរែកដី ឃ្វាលគោ និងដកសំណាប។ ក្រោយមក ខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសឲ្យមកធ្វើការងារនៅអង្គរបូរី។ នៅទីនោះ ខ្ញុំជីកប្រឡាយ០៩ កាត់ស្មៅ និងជីកព្រែកនៅព្រៃផ្គាំ។ ខ្ញុំធ្លាប់បានឃើញប្រជាជនដួលស្លាប់ក្នុងពេលធ្វើការ និងឃើញខ្មែរក្រហមធ្វើទារុណកម្មប្រជាជនដែលលួចរបស់របរអង្គការ។ ក្រោយមក ខ្មែរក្រហមបានផ្លាស់ប្តូរខ្ញុំឲ្យមកធ្វើការងារខាងសង្គមកិច្ចវិញ។ ខ្ញុំស្វែងរកថ្នាំបូរាណនៅលើភ្នំកំចាយក្នុងខេត្តកំពតអស់រយៈពេលកន្លះខែ។ បន្ទាប់ពីរកថ្នាំបូរាណ ខ្មែរក្រហមបានប្រើខ្ញុំឲ្យទៅជីកអំបិលនៅខេត្តកំពតបន្តទៀត។ ក្នុងរបបខ្មែរក្រហមប្រជាជនបានស្លាប់ច្រើន ដោយភាគច្រើនស្លាប់ដោយសារអត់បាយ។



ម៉ី កុប អាយុ៨៦ឆ្នាំ ជនជាតិខ្មែរ សព្វថ្ងៃរស់នៅភូមិវាល ឃុំក្តាញ់ ស្រុកព្រែកប្បាស ខេត្តតាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សារ៉ាយ លន់ ៖ ជំងឺសន្លាក់ខ្ញុំបានធូរស្រាល ពីមួយថ្ងៃទៅមួយថ្ងៃ បន្ទាប់ពីបានជួបពិគ្រោះជាមួយគ្រូពេទ្យ និងលេបថ្នាំដែលគ្រូពេទ្យបានប្រាប់

**ផេង ពង្សរ៉ាស៊ី**

ខ្ញុំឈ្មោះ សារ៉ាយ លន់ ភេទស្រី អាយុ៧៣ឆ្នាំ ជាជនជាតិខ្មែរ រស់នៅភូមិក្បៀម ឃុំក្ដាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ សព្វថ្ងៃខ្ញុំនៅផ្ទះមើលចៅ។ គ្រួសារខ្ញុំមានជីវភាពមធ្យម។ ចំណែកសុខភាពរបស់ខ្ញុំគឺឈឺបួសអន្ទង់, ខ្វាញ់រុំបេះដូង, លើសឈាម និងសន្លាក់។

ខ្ញុំធ្លាប់បានជួបជាមួយក្រុមការងារ និងចូលរួមកម្មវិធីរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជាបានចំនួនបីដងមកហើយ។ លើកដំបូង ខ្ញុំបានជួបសម្ភាសន៍អំពីប្រវត្តិឆ្លងកាត់របបខ្មែរក្រហមជាមួយអ្នកស្ម័គ្រចិត្តកម្ពុជា។ លើកទីពីរ ខ្ញុំបានចូលរួមក្នុងកម្មវិធីពិនិត្យ និងពិគ្រោះយោបល់ពីបញ្ហាសុខភាពនៅក្នុងឃុំក្ដាញ់ ហើយលើកចុងក្រោយ ខ្ញុំបានចូលរួមក្នុងការជួបជុំក្នុងវេទិកាអប់រំពីការថែទាំសុខភាព និងហូបអាហារជាមួយក្រុមគ្រូពេទ្យ ព្រមទាំងក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

ខ្ញុំនៅចាំបានថា ខ្ញុំធ្លាប់បាននិយាយអំពីរឿងរ៉ាវឆ្លងកាត់របបខ្មែរក្រហមទៅដល់អ្នកមកជួបសម្ភាសន៍ខ្ញុំថា ខ្មែរក្រហមប្រើខ្ញុំឲ្យរែកដីលាមកមនុស្សយកទៅដាក់ស្រែ និងដាក់បន្លែ។ ខ្ញុំប្រាប់បន្តទៀតថា ខ្ញុំធ្លាប់ត្រូវបានជម្លៀសរហូតមកដល់ព្រំប្រទល់ប្រទេសថៃ។ ខ្ញុំពេញចិត្តចំពោះការជួបនិយាយជាមួយអ្នកស្ម័គ្រចិត្តកម្ពុជាដែលបានមកសម្ភាសន៍ខ្ញុំ ព្រោះថាខ្ញុំចង់និយាយប្រាប់រឿងពិតទៅកាន់កូនចៅជំនាន់ក្រោយឲ្យបានដឹង។



សារ៉ាយ លន់ អាយុ៧៣ឆ្នាំ ជនជាតិខ្មែរ រស់នៅភូមិក្បៀម ឃុំក្ដាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មុនពេលមានការជួបជុំលើកទីពីរ ប្រធានភូមិបានមកដល់ផ្ទះខ្ញុំ និងបានអញ្ជើញខ្ញុំឲ្យចូលរួមក្នុងវេទិកាអប់រំអំពីការថែទាំសុខភាព ការពិនិត្យសុខភាព និងពិគ្រោះយោបល់អំពីបញ្ហាសុខភាពដែលធ្វើឡើងនៅភូមិសម្ដេចពាន់។ ប្រធានភូមិបានប្រាប់ពីគោលបំណងដែលគាត់មកអញ្ជើញខ្ញុំថា ដើម្បីឲ្យទៅទទួលសេវាពិនិត្យសុខភាពរកប្រភេទជំងឺដែលមានក្នុងខ្លួន និងឲ្យចូលរួមក្នុងកម្មវិធីអប់រំសុខភាព។ សមាជិកគ្រួសារខ្ញុំទាំងអស់ មិនបានរារាំង ឬហាមឃាត់ខ្ញុំមិនឲ្យទៅ

ចូលរួមកម្មវិធីនេះទេ។ កូនចៅខ្ញុំត្រេកអរណាស់ពេលដែលបានដឹងដំណឹងនេះ ថែមទាំងបានជូនខ្ញុំទៅដល់ទីតាំងប្រជុំដើម្បីឲ្យខ្ញុំបានទៅពិនិត្យសុខភាពទៀតផង។ ខ្ញុំពេញចិត្តនឹងចូលរួមក្នុងកម្មវិធីពិនិត្យសុខភាព។ មុននឹងចូលរួមក្នុងកម្មវិធីនេះ ខ្ញុំបានគិតថា ខ្ញុំនឹងទទួលសេវាពិនិត្យសុខភាពដោយមិនអស់ប្រាក់ និងការអប់រំពីសុខភាព។

ក្នុងពេលធ្វើដំណើរទៅចូលរួមក្នុងកម្មវិធីពិនិត្យសុខភាពនៅភូមិសម្តេចពាន់ ខ្ញុំមិនភ័យព្រួយពីការចំណាយប្រាក់ដើម្បីធ្វើដំណើរទៅកាន់ទីតាំងពិនិត្យសុខភាពឡើយ ព្រោះក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានផ្តល់ប្រាក់មកខ្ញុំមួយចំនួនដើម្បីចាយវាយលើការធ្វើដំណើររបស់ខ្ញុំ។ ខ្ញុំមិនមានការធុញទ្រាន់ក្នុងការចូលរួមក្នុងកម្មវិធីនេះទេ ព្រោះខ្ញុំចង់ដឹង និងចង់ស្តាប់ក្រុមគ្រូពេទ្យប្រាប់អំពីសុខភាពក្នុងខ្លួនរបស់ខ្ញុំ។ ខ្ញុំនៅចាំថា កម្មវិធីនេះបានផ្តល់សេវាពិនិត្យសុខភាពដល់ខ្ញុំដោយមិនអស់ប្រាក់ និងផ្តល់ការអប់រំពីបញ្ហាសុខភាពទៀតផង។ កាលនោះ ខ្ញុំទទួលបានចំណេះដឹងពីកម្មវិធីខ្លះៗដែរ ដូចជា ៖ ខ្ញុំបានយល់ដឹងពីការថែទាំសុខភាព ជាពិសេស ការថែទាំជំងឺប្រចាំកាយដែលកំពុងកើតមានរាល់ថ្ងៃដោយខ្លួនឯង។ ខ្ញុំបានយល់ដឹងពីការជ្រើសរើសម្ហូបអាហារដែលជំនួយដល់សុខភាព និងម្ហូបអាហារដែលគួរចៀសវាង។ ខ្ញុំបានយល់ដឹងពីការប្រើប្រាស់ថ្នាំឲ្យបានត្រឹមត្រូវតាមប្រភេទជំងឺ។ ខ្ញុំបានយល់ដឹងពីសារសំខាន់នៃការពិនិត្យសុខភាពជាប្រចាំ (រៀងរាល់៦ខែម្តង) និងបានយល់ដឹងពីការធ្វើលំហាត់ប្រាណប្រចាំថ្ងៃ។ ខ្ញុំទទួលផលប្រយោជន៍មួយចំនួនចេញពីកម្មវិធីពិនិត្យសុខភាពដូចជា សេវាពិនិត្យសុខភាពដោយមិនអស់ប្រាក់, ការអប់រំពីបញ្ហាសុខភាព និងទទួលបានថវិកាសម្រាប់សោហ៊ុយធ្វើដំណើរទៅចូលរួមក្នុងកម្មវិធី។

បន្ទាប់ពីបានចូលរួមក្នុងកម្មវិធីពិនិត្យសុខភាព និងបានលេបថ្នាំតាមវេជ្ជបញ្ជារួចមក ជំងឺខ្វាញ់រុំបេះដូងរបស់ខ្ញុំបានធូរស្រាលជាងមុន ហើយកម្លាំងពលំរបស់ខ្ញុំ ក៏គ្រាន់បើជាងមុនដែរ។ ខ្ញុំធ្លាប់មានជំងឺសន្លាក់ពីមុនដែរ ហើយធ្លាប់បានទៅព្យាបាល ប៉ុន្តែមិនបានធូរស្រាលឡើយ។ មុនពេលចូលរួមក្នុងកម្មវិធីនេះ ខ្ញុំឈឺខ្លាំងណាស់។ ប៉ុន្តែខ្ញុំបានធូរស្រាលពីជំងឺនេះម្តងបន្តិចៗ បន្ទាប់ពីខ្ញុំបានទៅជួបគ្រូពេទ្យក្នុងកម្មវិធីជួបជុំដើម្បីពិនិត្យនិងពិគ្រោះយោបល់ពីបញ្ហាសុខភាពនៅភូមិសម្តេចពាន់រួចមក។

ខ្ញុំបានចែករំលែកព័ត៌មានពីការថែទាំសុខភាពដល់អ្នកជិតខាង និងបងប្អូនរបស់ខ្ញុំឲ្យបានយល់ដឹងពីការថែទាំសុខភាពខ្លួនឯង ពីការប្រើប្រាស់ថ្នាំឲ្យត្រឹមត្រូវតាមប្រភេទជំងឺ ពីសារសំខាន់នៃការពិនិត្យសុខភាពជាប្រចាំ និងពីការធ្វើលំហាត់ប្រាណ។

មកដល់ពេលនេះ និងទៅអនាគត ខ្ញុំនៅតែបន្តប្រើប្រាស់ចំណេះដឹងដែលបានមកពីការចូលរួមក្នុងកម្មវិធីនេះតទៅទៀត ដូចជាការអនុវត្តទៅលើការថែទាំសុខភាព ជាពិសេសការថែទាំជំងឺប្រចាំកាយដែលកំពុងកើតមានរាល់ថ្ងៃ ការហូបអាហារតាម ប្រការជ្រើសរើសម្ហូបអាហារដែលអាចទ្រទ្រង់ដល់សុខភាព និងម្ហូបអាហារដែលគួរចៀសវាង ការប្រើប្រាស់ថ្នាំឲ្យបានត្រឹមត្រូវតាមវេជ្ជបញ្ជាគ្រូពេទ្យ ការតាមដានសុខភាពជាប្រចាំ និងការទៅត្រួតពិនិត្យសុខភាពជារៀងរាល់៦ខែម្តងរួមទាំងការហាត់ប្រាណជាប្រចាំផង។

ចំពោះការចូលរួមក្នុងវេទិកាអប់រំពីការថែទាំសុខភាព ការពិនិត្យសុខភាព និងពិគ្រោះយោបល់ពីបញ្ហាសុខភាពនេះ ខ្ញុំមានអារម្មណ៍ល្អនិងពេញចិត្តណាស់ ដែលក្រុមគ្រូពេទ្យយកចិត្តទុកដាក់ពិនិត្យនិងពិគ្រោះជំងឺជាមួយមនុស្សចាស់ក្នុងភូមិ។ ខ្ញុំមានសំណូមពរឲ្យមានវេទិកាពិនិត្យសុខភាពឲ្យជួយចាស់ជរាបន្តទៀត។ ខ្ញុំមិនមានចំណុចណាមួយដែលត្រូវកែលម្អសម្រាប់ការអនុវត្តកម្មវិធីនេះទេ ព្រោះសម្រាប់ខ្ញុំពេញចិត្តនឹងកម្មវិធីនេះណាស់។

## រឿងរ៉ាវឆ្លងកាត់របបខ្មែរក្រហម

ខ្ញុំកើតក្នុងគ្រួសារក្រីក្រមួយ ដែលមានឪពុក

ឈ្មោះ សារ៉ាយ លៀង ប្រកបមុខរបរធ្វើស្រែ និងម្ដាយឈ្មោះ គីង ប៉ា។ ខ្ញុំមានបងប្អូនបង្កើតចំនួនពីរនាក់។ ខ្ញុំរៀបការជាមួយប្ដីខ្ញុំឈ្មោះ មឿន ញឹល និងមានកូនចំនួន៣នាក់ ក្នុងចំណោមនោះស្លាប់កូនស្រីពៅម្នាក់។

ក្នុងរបបខ្មែរក្រហម ខ្ញុំត្រូវបានបញ្ជូនទៅធ្វើការនៅក្នុងកងស្រួច។ ខ្មែរក្រហមបានប្រើខ្ញុំឲ្យធ្វើការរែកដីដាក់ស្រែ និងស្រោចដំណាំនៅវាំងកែវ ស្ថិតក្នុងឃុំក្តាញ់។ ក្រោយមកខ្មែរក្រហមបានបញ្ជូនខ្ញុំឲ្យស្ទូងស្រូវនៅកំពង់ចក ស្ថិតនៅខាងកើតឃុំព្រៃល្វា។ ខ្ញុំសម្រាលបានកូនស្រីម្នាក់ ហើយត្រូវបានដាក់ក្នុងមណ្ឌលកុមារ។ ក្រោយពីខ្ញុំសម្រាលកូនបានបីថ្ងៃ ខ្មែរក្រហមប្រើខ្ញុំឲ្យរែកដីបន្តទៀត។ ចំណែកឯកូនស្រីរបស់ខ្ញុំដែលទើបសម្រាលបានបីថ្ងៃនោះ ក៏បានស្លាប់បាត់បង់ជីវិតដោយសារមិនមានទឹកដោះបៅ។ ខ្ញុំឈឺចាប់ណាស់ ពេលដែលខ្ញុំត្រឡប់មកពីធ្វើការវិញ ហើយដឹងថាកូនរបស់ខ្ញុំបានស្លាប់។ នេះគឺជារឿងរ៉ាវដែលខ្ញុំចងចាំ មិនអាចបំភ្លេចបានក្នុងមួយជីវិតរបស់ខ្ញុំ។



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកព្រៃកប្បាស ខេត្តតាកែវ ចូលរួមវេទិកាអប់រំពីការថែទាំសុខភាព រៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# ហម ជន ៖ ចែករំលែកចំណេះដឹងអំពីការថែទាំសុខភាព និងរឿងរ៉ាវឆ្លងកាត់របបខ្មែរក្រហមទៅកាន់អ្នកជិតខាង និងសមាជិកគ្រួសារ

**ផេង ពង្សរ៉ាស៊ី**

ខ្ញុំឈ្មោះ ហម ជន ភេទប្រុស អាយុ៧៨ឆ្នាំ ជនជាតិខ្មែរ មានស្រុកកំណើតនៅភូមិក្បាលដំរីលើ ឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្ដាល។ បច្ចុប្បន្នខ្ញុំធ្វើជាអាចារ្យវត្ត រស់នៅភូមិក្បៀម ឃុំក្ដាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ ខ្ញុំមានជីវភាពមធ្យម និងរស់នៅសមរម្យដោយមិនខ្វះខាតអ្វីឡើយ។ សព្វថ្ងៃខ្ញុំមានជំងឺបេះដូង និងជំងឺលើសឈាម។


ហម ជន ភេទប្រុស អាយុ៧៨ឆ្នាំ បច្ចុប្បន្នរស់នៅភូមិក្បៀម ឃុំក្ដាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំធ្លាប់បានចូលរួមកម្មវិធីដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ចំនួនបីដងរួចមកហើយ។ សម្រាប់ការជួបលើកទីមួយ គឺខ្ញុំបានជួបជាមួយក្រុមអ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ខ្ញុំមានការពេញចិត្តយ៉ាងខ្លាំង នៅពេលដែលឃើញយុវជនមកជួប និងសម្ភាសន៍ខ្ញុំអំពីរឿងរ៉ាវឆ្លងកាត់របបខ្មែរក្រហម។ ខ្ញុំនៅចាំបានថា ខ្ញុំនិយាយប្រាប់ក្មួយដែលជាអ្នកស្ម័គ្រចិត្តអំពីទុក្ខលំបាករបស់ខ្ញុំ ទាំងការរស់នៅ ការហូបចុក និងការធ្វើទារុណកម្មរបស់ខ្មែរក្រហមមកលើខ្ញុំនិងប្រជាជន។

ក្នុងជំនួបលើកទីពីរ គឺតាមរយៈមេឃុំក្ដាញ់។ មេឃុំបានមកផ្ទះខ្ញុំ ហើយប្រាប់ថា គាត់អញ្ជើញខ្ញុំឲ្យទៅចូលរួមនៅក្នុងវេទិកាថែទាំសុខភាព និងពិគ្រោះយោបល់អំពីបញ្ហាសុខភាពដោយមិនគិតថ្លៃដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ ខ្ញុំភ្ញាក់ផ្អើលហើយត្រេកអរណាស់ ព្រោះខ្ញុំពុំដែលមានការអញ្ជើញពីមុនមកទេ ដើម្បីឲ្យទៅពិនិត្យសុខភាពដោយមិនបង់ថ្លៃ។ ក្នុងការចូលរួមវេទិកាពិនិត្យ មិនមានកូនចៅណាហាមឃាត់ខ្ញុំឡើយ។ មុនចូលរួម ខ្ញុំសង្ឃឹមថាខ្ញុំនឹងទទួលបានថ្នាំពេទ្យ សេវាពិនិត្យសុខភាពដោយមិនអស់ប្រាក់ និងការអប់រំពីបញ្ហាសុខភាព។ ប៉ុន្តែ ខ្ញុំមិនបានទទួលថ្នាំពេទ្យទេ បន្ទាប់បានបញ្ចប់កម្មវិធីពិនិត្យសុខភាព និងវេទិកាអប់រំពីការថែទាំសុខភាពរួច។

ក្នុងពេលធ្វើដំណើរទៅចូលរួមកម្មវិធី ខ្ញុំទទួលបានការឧបត្ថម្ភពីមជ្ឈមណ្ឌលឯកសារកម្ពុជា លើការចំណាយថ្លៃធ្វើដំណើរ។ មិនតែប៉ុណ្ណោះ អំឡុងពេលចូលរួមកម្មវិធី ខ្ញុំមិនមានអារម្មណ៍ថាធុញទ្រាន់នោះ

ទេ។ ខ្ញុំនៅចងចាំថា កម្មវិធីនេះបានផ្តល់ដល់ខ្ញុំនូវសេវាពិនិត្យសុខភាពដោយមិនអស់ប្រាក់ និងផ្តល់ការអប់រំពីបញ្ហាសុខភាព។ ខ្ញុំក៏ទទួលបានកូនសៀវភៅស្តីពីការថែទាំសុខភាពចំនួនពីរក្បាល ហើយខ្ញុំចែកមួយក្បាលឲ្យទៅផ្ទះជិតខ្ញុំដើម្បីអាន និងយល់ដឹងពីការថែទាំសុខភាព។

បន្ទាប់ពីខ្ញុំបានចូលរួមក្នុងកម្មវិធីរួចមក ខ្ញុំមានការយល់ដឹងច្រើនជាងមុនអំពីការថែទាំសុខភាពផ្ទាល់ខ្លួនប្រចាំថ្ងៃ ក៏ដូចជាការហូបអាហារណាដែលជាជំនួយដល់សុខភាព និងតមអាហារណាដែលនាំឲ្យប៉ះពាល់ដល់សុខភាព។ មិនតែប៉ុណ្ណោះ ខ្ញុំបានចែករំលែកព័ត៌មានអំពីការថែទាំសុខភាព ទៅកាន់កូនចៅជំនាន់ក្រោយ ដោយប្រាប់ឲ្យអានសៀវភៅដើម្បីបានដឹងពីរបៀបក្នុងការថែទាំសុខភាព។ ខ្ញុំក៏បានចែករំលែកទៅកាន់ប្អូនប្រុសរបស់ខ្ញុំម្នាក់ទៀតដែរ ដែលសព្វថ្ងៃប្អូនប្រុសខ្ញុំកំពុងរស់នៅឯស្រុកកោះធំ ខេត្តកណ្តាលឯណោះ។ ប្អូនប្រុសខ្ញុំ មានជំងឺលើសឈាម និងជំងឺបេះដូងដូចខ្ញុំដែរ។ ខ្ញុំបានឲ្យសៀវភៅថែទាំសុខភាពមួយក្បាល ទៅប្អូនប្រុសខ្ញុំអានដើម្បីឈ្វេងយល់ខ្លួនឯងអំពីការថែទាំសុខភាព។ ខ្ញុំបានប្រាប់ប្អូនរបស់ខ្ញុំថា ការអនុវត្តតាមសៀវភៅណែនាំពីការថែទាំសុខភាព និងការធ្វើលំហាត់ប្រាណជាប្រចាំដើម្បីឲ្យសុខភាពបានប្រសើរជាងមុន គឺជារឿងចាំបាច់សម្រាប់ការថែរក្សាអាយុឲ្យកាន់តែវែងថែមទៀត។

ក្រោយពីចូលរួមក្នុងកម្មវិធីរួចមក ស្ថានភាពជំងឺរបស់ខ្ញុំមានភាពធូរស្រាលជាងមុន ព្រោះជំងឺមិនសូវធ្វើទុក្ខដូចកាលពីពេលមុនៗ។ ខ្ញុំនៅតែចង់ឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា បន្តធ្វើវេទិកាថែទាំសុខភាពនេះទៀត ព្រោះបានជួយរំឭកពីរបៀបការថែទាំសុខភាព និងជួយឲ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទទួលបានសេវាសុខភាព និងមានអាយុកាន់តែវែងថែមទៀត។

ខ្ញុំយល់ឃើញថា វេទិកាអប់រំពីការថែទាំសុខភាពការពិគ្រោះ និងពិនិត្យសុខភាពជូនមនុស្សចាស់ៗដូចខ្ញុំ គឺជាកម្មវិធីល្អបំផុត។ ខ្ញុំសំណូមពរឲ្យក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា ជួយផ្សព្វផ្សាយ និងបង្កើតកម្មវិធីនេះឲ្យបានច្រើនថែមទៀត និងណែនាំដល់ក្មេងៗជំនាន់ក្រោយឲ្យបានដឹងពីរបៀបថែទាំសុខភាពបន្តទៀត។

## រឿងរ៉ាវឆ្លងកាត់របបខ្មែរក្រហម

ខ្ញុំមានបងប្អូនបង្កើតចំនួន៥នាក់ គឺប្រុស៣ និងស្រី២នាក់។ ប៉ុន្តែបងប្រុសខ្ញុំម្នាក់បានស្លាប់ហើយ។ ខ្ញុំបានរៀបការក្នុងឆ្នាំ១៩៦៨ ជាមួយប្រពន្ធឈ្មោះជា រៀល។ ប្រពន្ធខ្ញុំទើបស្លាប់កាលពីពីរខែកន្លងទៅនេះទេ ដោយសារជំងឺក្រពះពោះវៀន។ ខ្ញុំមានកូនចំនួន៧នាក់ គឺស្រី៣នាក់ និងប្រុស៤នាក់។

ក្នុងរបបខ្មែរក្រហម ខ្ញុំគឺជាប្រជាជនមូលដ្ឋាន។ ខ្មែរក្រហមប្រើខ្ញុំឲ្យធ្វើស្រែរួមតាមក្រុម តាមភូមិដោយមួយក្រុមមានមនុស្សចំនួន១០នាក់។ ការធ្វើស្រែទទួលបានស្រូវច្រើនគួរសមដែរ ប៉ុន្តែខ្មែរក្រហមប្រមូលដាក់ឃ្លាំងទាំងអស់។ ក្នុងអំឡុងពេលនោះ ខ្ញុំសង្កេតឃើញមានប្រជាជនថ្មីច្រើននាក់ណាស់ត្រូវបានខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញមកនៅភូមិខ្ញុំ។ ខ្មែរក្រហមបានប្រើប្រជាជនថ្មីទាំងនោះឲ្យធ្វើស្រែជាមួយអ្នកមូលដ្ឋានចាស់។ បន្ទាប់មក ខ្មែរក្រហមបានជម្លៀសខ្ញុំឲ្យទៅធ្វើការងារនៅអង្គរបូរី។ ខ្ញុំបានចូលរួមជីកព្រែកស្មើរតែគ្រប់ទឹកន្លែងនៅទីនោះជាមួយកងចល័តបុរសៗជាច្រើននាក់ទៀត។ ខ្មែរក្រហមបានអនុញ្ញាតឲ្យខ្ញុំមកលេងផ្ទះរៀងរាល់៣ខែម្តង។ ខ្ញុំមកលេងផ្ទះរយៈពេលមួយសប្តាហ៍ ក៏ត្រឡប់ទៅធ្វើការងារវិញ។ រឿងរ៉ាវដែលខ្ញុំនៅចងចាំមិនបំភ្លេច គឺខ្មែរក្រហមប្រើខ្ញុំឲ្យធ្វើការងារហួសកម្លាំង ហូបមិនឆ្អែត និងរស់នៅគ្មានសិទ្ធិសេរីភាព។

# ឡុង ចាំ ៖ ចែករំលែកចំណេះដឹងអំពីការថែទាំសុខភាព និងរឿងរ៉ាវឆ្លងកាត់របបខ្មែរក្រហម ទៅកាន់អ្នកជិតខាង និងសមាជិកគ្រួសារ

**វេង ពន្យរ៉ាស៊ី**

ខ្ញុំឈ្មោះ ឡុង ចាំ ហៅ ហុង ភេទប្រុស អាយុ ៧៩ឆ្នាំ ជាជនជាតិខ្មែរ មានទីកន្លែងកំណើតនៅភូមិវាល ឃុំក្តាញ់ ស្រុកព្រែកប្បាស ខេត្តតាកែវ។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិឃុំដដែល។ សព្វថ្ងៃខ្ញុំធ្វើស្រែ និងចុងភៅ។ ស្ថានភាពគ្រួសាររបស់ខ្ញុំមានជីវភាពមធ្យម។ ចំណែកសុខភាពបច្ចុប្បន្ន ខ្ញុំមានជំងឺលើសឈាម ជំងឺក្រពះ ជំងឺថ្លើម ជំងឺលើសជាតិអាស៊ីត និងខ្វះគ្រាប់ឈាមក្រហម។

ខ្ញុំធ្លាប់បានជួបជាមួយក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាចំនួនពីរដង។ លើកទីមួយ ខ្ញុំបានជួបសម្ភាសន៍ពីប្រវត្តិឆ្លងកាត់របបខ្មែរក្រហមជាមួយចៅ ស្រី ធីតា គឺជាអ្នកស្ម័គ្រចិត្តកម្ពុជានៅមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ហើយលើកទីពីរ ខ្ញុំបានចូលរួមវេទិកាអប់រំថែទាំសុខភាព និងការពិនិត្យសុខភាព និងពិគ្រោះយោបល់ពីបញ្ហាសុខភាព នៅក្នុងឃុំក្តាញ់ជាមួយក្រុមគ្រូពេទ្យ និងក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ខ្ញុំចាំបានថា ពេលដែលខ្ញុំជួបជាមួយចៅ ស្រី ធីតា ខ្ញុំបាននិយាយប្រាប់ពីរឿងរ៉ាវឆ្លងកាត់របបខ្មែរក្រហមថា «ខ្ញុំធ្វើការងារហត់នឿយណាស់ និងធ្លាប់ត្រូវក្រុមឈ្លបហៅទៅណែនាំទៀតផង»។ ខ្ញុំពេញចិត្តចំពោះការជួបនិយាយជាមួយអ្នកស្ម័គ្រចិត្តកម្ពុជាដែលបានមកសម្ភាសន៍ ព្រោះខ្ញុំចង់បង្ហាញឲ្យកូនចៅជំនាន់ក្រោយបានដឹងពីទុក្ខលំបាករបស់ចាស់ៗជំនាន់មុនៗ



ឡុង ចាំ ហៅ ហុង អាយុ៧៩ឆ្នាំ សព្វថ្ងៃរស់នៅភូមិវាល ឃុំក្តាញ់ ស្រុកព្រែកប្បាស ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃមួយ ប្រធានភូមិបានមកអញ្ជើញខ្ញុំឲ្យទៅចូលរួមក្នុងវេទិកាអំពីការថែទាំសុខភាព ការពិនិត្យសុខភាព និងការពិគ្រោះយោបល់ពីបញ្ហាសុខភាពនៅភូមិសម្តេចពាន់។ ខ្ញុំបានសួរគាត់ពីគោលបំណងនៃការចូលរួមប្រជុំ។ ប្រធានភូមិបានប្រាប់ខ្ញុំថា ទៅចូលរួមដើម្បីបានទទួលសេវាពិនិត្យសុខភាព រកប្រភេទជំងឺដែលមាន និងស្តាប់ការណែនាំអំពីការថែរក្សាសុខភាព។ ប្រពន្ធរបស់ខ្ញុំក៏បាន

ទៅចូលរួមដែរ ហើយមិនមានសមាជិកក្នុងគ្រួសារណាម្នាក់ មករារាំង ឬហាមឃាត់មិនឲ្យខ្ញុំចូលរួមកម្មវិធីនេះទេ។ កូន និងចៅរបស់ខ្ញុំ គឺជាអ្នកជូនខ្ញុំ និងប្រពន្ធទៅដល់ទីតាំងទៀតផង។ ខ្ញុំពេញចិត្តនឹងចូលរួមក្នុងកម្មវិធីនេះណាស់។

មុននឹងចូលរួមក្នុងកម្មវិធីនេះ ខ្ញុំគិតថា ខ្ញុំនឹងទទួលបានថ្នាំពេទ្យខ្លះមកព្យាបាលជំងឺដែលកំពុងតែកើតមានមកលើខ្ញុំ និងទទួលបានសេវាពិនិត្យសុខភាពដោយមិនអស់ប្រាក់ ព្រមទាំងទទួលបានការអប់រំពីសុខភាពទៀតផង។ ខ្ញុំគិតទៀតថា ខ្ញុំអាចនឹងត្រូវគ្រូពេទ្យបញ្ជូនខ្ញុំឲ្យមកព្យាបាលបន្តនៅមន្ទីរពេទ្យក្នុងទីក្រុងភ្នំពេញដែរ។

ក្នុងពេលធ្វើដំណើរទៅចូលរួមក្នុងកម្មវិធីដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំ ខ្ញុំពុំបានចំណាយប្រាក់ផ្ទាល់ខ្លួនដើម្បីធ្វើដំណើរទៅចូលរួមឡើយ។ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានផ្តល់ប្រាក់ខ្លះដល់ខ្ញុំដើម្បីបានធ្វើដំណើរមកចូលរួមទាំងទៅ និងមក។ ខ្ញុំមិនមានការធុញទ្រាន់ក្នុងការចូលរួមក្នុងកម្មវិធីនេះទេ ព្រោះខ្ញុំសប្បាយចិត្តនៅពេលបានជួបជុំគ្នា និងបានពិគ្រោះយោបល់ពីបញ្ហាសុខភាពរបស់ខ្ញុំ។ កាលនោះខ្ញុំនៅចាំថា ក្នុងកម្មវិធីនោះបានរៀបចំឡើងដើម្បីផ្តល់សេវាពិនិត្យសុខភាពដោយមិនអស់ប្រាក់ និងផ្តល់ការអប់រំពីបញ្ហាសុខភាព។ ខ្ញុំទទួលបានចំណេះដឹងពីកម្មវិធីនេះច្រើន។ ខ្ញុំយល់ដឹងពីការថែទាំសុខភាព ជាពិសេសការថែទាំជំងឺប្រចាំកាយដែលកំពុងកើតមានរាល់ថ្ងៃដោយខ្លួនឯង។ ខ្ញុំយល់ដឹងពីការជ្រើសរើសម្ហូបអាហារដែលអាចទ្រទ្រង់ដល់សុខភាព និងម្ហូបអាហារដែលគួរចៀសវាង។ ខ្ញុំសូមរំឭកបន្តិចដែរថា ថ្ងៃមួយ ខ្ញុំភ្លេចខ្លួន! ខ្ញុំហូបគ្រឿងសមុទ្រពីរពេល។ សុខភាពខ្ញុំចាប់ផ្តើមទ្រុឌទ្រោមភ្លាមៗ។ ខ្ញុំបានទៅកាន់មន្ទីរពេទ្យ ហើយគ្រូពេទ្យបានប្រាប់ថា មកពីខ្ញុំហូបអាហារខុស។ ខ្ញុំនៅចាំបានទៀតថា ខ្ញុំយល់ដឹងពីការប្រើប្រាស់ថ្នាំឲ្យត្រឹមត្រូវតាមប្រភេទជំងឺ។ ខ្ញុំយល់ដឹងពីការធ្វើលំហាត់ប្រាណប្រចាំថ្ងៃ។ ខ្ញុំបានដឹងពីទីកន្លែង ឬមន្ទីរពេទ្យដែលខ្ញុំគួរទៅ ដើម្បីពិនិត្យសុខភាព ឬព្យាបាលជំងឺ។ ក្នុងកម្មវិធីដែលខ្ញុំបានចូលរួមនេះ ខ្ញុំបានទទួលសេវាពិនិត្យសុខភាពដោយមិនអស់ប្រាក់ ទទួលការអប់រំពីបញ្ហាសុខភាព និងទទួលបានថវិកាសម្រាប់សោហ៊ុយធ្វើដំណើរទៅចូលរួមក្នុងកម្មវិធី។

បន្ទាប់ពីបានចូលរួមក្នុងកម្មវិធីនេះរួច ខ្ញុំបានចែករំលែកព័ត៌មានដល់អ្នកជិតខាង និងបងប្អូនខ្ញុំឲ្យបានយល់ដឹងអំពី ការថែទាំសុខភាព ជាពិសេសការថែទាំជំងឺប្រចាំកាយដែលកំពុងកើតមានរាល់ថ្ងៃដោយខ្លួនឯង, ការប្រើប្រាស់ថ្នាំឲ្យត្រឹមត្រូវតាមប្រភេទជំងឺ, សារសំខាន់នៃការពិនិត្យសុខភាពជាប្រចាំ, ការធ្វើលំហាត់ប្រាណ ទីកន្លែង ឬមន្ទីរពេទ្យដែលខ្ញុំគួរទៅពិនិត្យសុខភាព ឬព្យាបាលជំងឺ។

ភ្លាមៗបន្ទាប់ពីបានចូលរួមក្នុងកម្មវិធីនេះ និងទទួលបានក្រដាសទិញថ្នាំ (វេជ្ជបញ្ជា) រួច ខ្ញុំបានទៅទិញថ្នាំពីកន្លែងលក់ថ្នាំនៅខេត្តតាកែវ មកលេបតាមការណែនាំ។ ក្រោយការលេបថ្នាំ និងអនុវត្តតាមការអប់រំរបស់គ្រូពេទ្យ ខ្ញុំហាក់ដូចជាគ្រាន់បើជាងមុន។ ខ្ញុំមានកម្លាំងជាងមុន និងអាចធ្វើការងារបានឡើងវិញ។ ទោះបីជាយ៉ាងដូច្នេះក៏ដោយ ដោយសារខ្ញុំមានអាយុកាន់តែច្រើន ទើបខ្ញុំមានជំងឺថ្មីៗជាច្រើនមុខទៀតនាពេលថ្មីៗនេះ។ ជំងឺទាំងនោះមានដូចជា ជំងឺថ្លើម ជំងឺលើសជាតិអាស៊ីត និងជំងឺខ្វះគ្រាប់ឈាមក្រហម។ ខ្ញុំមិនបានពិគ្រោះជាមួយគ្រូពេទ្យពីប្រភេទជំងឺទាំងនេះទេ ក្នុងពេលដែលខ្ញុំបានទៅជួបគ្រូពេទ្យដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រោះខ្ញុំពុំបានដឹងទាល់តែសោះថា ខ្ញុំមានប្រភេទជំងឺទាំងនេះដែរ។ ខ្ញុំគ្រាន់តែបានពិគ្រោះជាមួយគ្រូពេទ្យអំពីជំងឺលើសឈាម និងជំងឺក្រពះ ដែលបានញាំញីខ្ញុំតាំងពីយូរមកហើយ។ ដោយសារខ្ញុំមានអាការមិនស្រួលខ្លួនញឹកញាប់ពេក ខ្ញុំក៏បានទៅកាន់ទីក្រុងភ្នំពេញ ដើម្បីពិនិត្យសុខភាព

របស់ខ្ញុំ។ ខ្ញុំបានពិនិត្យសុខភាពរបស់ខ្ញុំនៅមន្ទីរពេទ្យឯកជន អេស៊ីយូ។ នៅទីនោះ ទើបខ្ញុំដឹងថា ខ្ញុំមានជំងឺច្រើនមុខណាស់ដែលត្រូវព្យាបាល។ គ្រូពេទ្យបានឲ្យខ្ញុំទិញថ្នាំព្យាបាលជំងឺថ្លើម លើសជាតិអាស៊ីត ក្រពះ និងជំងឺខ្វះគ្រាប់ឈាមក្រហម។ គ្រូពេទ្យបានណែនាំខ្ញុំឲ្យលេបថ្នាំព្យាបាលជំងឺថ្លើមជាមុនសិន។ នៅពេលដែលជំងឺថ្លើមខ្ញុំបានជាសះស្បើយ ទើបគ្រូពេទ្យឲ្យខ្ញុំលេបថ្នាំដទៃទៀត មានថ្នាំព្យាបាលជំងឺក្រពះ ជំងឺលើសជាតិអាស៊ីត និងជំងឺឯទៀត។

មកដល់ថ្ងៃនេះ ខ្ញុំបានផ្អាកប្រើប្រាស់ថ្នាំដែលខ្ញុំបានទិញតាមវេជ្ជបញ្ជាគ្រូពេទ្យដែលខ្ញុំបានពិគ្រោះជាមួយ នៅក្នុងភូមិសម្តេចពាន់ជាបណ្តោះអាសន្នសិន។ តែខ្ញុំមិនបោះបង់ចោលរហូតទេ។ ខ្ញុំត្រូវធ្វើតាមការណែនាំរបស់វេជ្ជបណ្ឌិតនៅភ្នំពេញសិន។ បន្ទាប់ពីជាសះស្បើយពីជំងឺថ្លើមប្រភេទ «C» ជំងឺក្រពះ និងជំងឺលើសជាតិអាស៊ី ទើបខ្ញុំអាចចាប់ផ្តើមបន្តលេបថ្នាំលើសឈាមបន្តទៀតបាន។

ខ្ញុំមានអារម្មណ៍សប្បាយចិត្តដែលបានចូលរួមវេទិកាអប់រំពីការថែទាំសុខភាព និងការពិនិត្យសុខភាព និងពិគ្រោះយោបល់ពីបញ្ហាសុខភាពនេះព្រោះចង់ដឹងពីប្រភេទជំងឺ។ ខ្ញុំមានសំណូមពរខ្លះដែរសម្រាប់ការអនុវត្តកម្មវិធីនេះលើកក្រោយៗទៀត។ ចំពោះការបង្កើតកម្មវិធីនេះ ខ្ញុំគិតថាវាល្អខ្លាំងណាស់ ប៉ុន្តែខ្ញុំក៏ចង់ឲ្យមានការចែកចាយថ្នាំពេទ្យបន្ថែមទៀតដើម្បីព្យាបាលជំងឺ។ សំណូមពរមួយទៀតរបស់ខ្ញុំ គឺថា ប្រសិនជាកម្មវិធីនេះមាននាំយកម៉ាស៊ីនធំៗមកពិនិត្យសុខភាព ពីប្រភេទជំងឺទាំងអស់ដែលមាននៅក្នុងខ្លួន គឺរឹតតែប្រសើរថែមទៀត។

## រឿងរ៉ាវឆ្លងកាត់របបខ្មែរក្រហម

ខ្ញុំមានបងប្អូនបង្កើតចំនួនបីនាក់ គឺស្រី២នាក់ និងប្រុសម្នាក់។ ខ្ញុំគឺជាកូនទីពីរក្នុងគ្រួសារ។ ខ្ញុំមានឪពុកឈ្មោះ ឡុង ហ៊ួយ និងម្តាយឈ្មោះ អៀ ណាំង។ ឪពុករបស់ខ្ញុំបានស្លាប់បាត់បង់ជីវិតតាំងពីខ្ញុំអាយុ៦ឆ្នាំ។ ក្រោយពីឪពុករបស់ខ្ញុំស្លាប់ ម្តាយខ្ញុំបានប្រកប



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកព្រៃកប្បាស ខេត្តតាកែវ ចូលរួមវេទិកាអប់រំពីការថែទាំសុខភាព រៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

របរជាអ្នកតម្បាញផង និងធ្វើស្រែចម្ការផងៗ ពេលខ្ញុំអាយុ៧ឆ្នាំ ទំនេរពីការសិក្សា ខ្ញុំឆ្លៀតមកជួយធ្វើការងារស្រែចម្ការដើម្បីជួយសម្រាលបន្ទុកម្តាយខ្ញុំ។

នៅឆ្នាំ១៩៦៤ ខ្ញុំប្រឡងជាប់សញ្ញាបត្រឌីប្លូម ប៉ុន្តែខ្ញុំមិនបានបន្តការសិក្សាទៀតទេ។ ខ្ញុំត្រូវនៅជួយធ្វើស្រែ និងរស់នៅជាមួយម្តាយឯភូមិកំណើត។ នៅឆ្នាំ១៩៦៩ ខ្ញុំបានរៀបការ និងមានកូនស្រីម្នាក់។ បងប្អូនស្រីរបស់ខ្ញុំទាំងពីរមានគ្រួសារទាំងអស់។ ប្អូនស្រីម្នាក់មានប្តីធ្វើជាប៉ូលិស និងម្នាក់ទៀតមានប្តីធ្វើជាទាហាននៅខេត្តសៀមរាប។ នៅឆ្នាំ១៩៧៣ ភូមិកំណើតរបស់ខ្ញុំស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមខ្មែររំដោះ។ ពេលនោះ ប្រជាជនបានចាប់ផ្តើមចូលខ្មែរក្រហមបណ្តើរៗហើយ។ ខ្មែរក្រហមបានបង្រៀនប្រជាជនឲ្យរួមសាមគ្គីគ្នាក្នុងក្រុមដែលត្រូវបានចាត់ចែង និងហូបរួមជាមួយគ្នាក្នុងភូមិ។ ប៉ុន្តែមិនមែនដាំបាយរួម និងស្លរួមទេ គឺយើងដាំស្លតាមផ្ទះរៀងៗខ្លួន។ ពេលបាយសម្លឆ្អិនហើយ ទើបយើងដួសយកទៅហូបរួមនៅតាមរោងដែលបានរៀបចំដោយក្រុមខ្មែរក្រហមនៅក្នុងភូមិ។

លុះមកដល់ឆ្នាំ១៩៧៥ ខ្មែរក្រហមបានសម្លាប់ប្តីបងខ្ញុំ ដោយសារតែពួកគាត់ជាប់និន្នាការធ្វើការក្នុងរបប លន់ នល់។ បន្ទាប់ពីប្តីត្រូវបានសម្លាប់ បងស្រីខ្ញុំបានធ្លាក់ខ្លួនឈឺ និងក្លាយខ្លួនជាមនុស្សវិកលចរិត និងតែងតែជេរស្តីទៅកាន់ខ្មែរក្រហម ទាំងនោះជារៀងរាល់ថ្ងៃ។ មិនយូរប៉ុន្មាន ខ្មែរក្រហមបានមកចាប់បងស្រីខ្ញុំយកទៅសម្លាប់ចោលទៀត។ ជារៀងរាល់ថ្ងៃ ខ្ញុំត្រូវខ្មែរក្រហមប្រើឲ្យឡើងត្នោតនៅពេលព្រឹក និងកាប់រណ្តៅដាំល្ពៅនៅពេលថ្ងៃត្រង់។ ខ្ញុំត្រូវធ្វើការតាំងពីព្រលឹមរហូតដល់ម៉ោង១០យប់ ទើបបានសម្រាក។

រឿងរ៉ាវដែលខ្ញុំចងចាំជាងគេហើយមិនអាចបំភ្លេចបាននោះមានពីររឿងគឺ ទីមួយ ៖ «មានសមមិត្តម្នាក់បានចូលទៅក្នុងសហករណ៍ ហើយបានលួចយកស្ករ និងល្ពៅមកស្ងោរហូប។ ក្មេងៗកងឈ្លបបានឃើញ រួចក៏ស្រែកផ្តើលដល់កងឈ្លបច្រើននាក់ទៀតមកប្រសេចប្រសាចពេញសហករណ៍។ ប្រធានភូមិបានដឹងរឿងនេះ ហើយបានប្រើឲ្យក្រុមកងឈ្លបទៅហៅសមមិត្តដែលលួចស្ករនិងល្ពៅរួម ទាំងក្រុមខ្ញុំដែលដើរជាមួយសមមិត្តនោះទៅប្រជុំ។ កងឈ្លបបានវាយធ្វើបាបអ្នកលួចអាហារនោះនៅមុខខ្ញុំ និងបានព្រមានមិនឲ្យលួចទៀតទេ។ ខ្ញុំភ័យណាស់! ភ័យខ្លាចកងឈ្លបធ្វើបាប ទាំងខ្ញុំទៀត»។ ទីពីរ ៖ «នៅពេលខ្ញុំដើរទៅកាប់វល្លិក្នុងព្រៃ ខ្ញុំក៏ឃើញដំឡូងនៅតាមផ្លូវ។ ខ្ញុំក៏រើសដំឡូងនោះមកខាំហូប។ ពេលខ្មែរក្រហមឃើញខ្ញុំរើសដំឡូងមកហូប ក៏ដេញចាប់ខ្ញុំ ប៉ុន្តែដេញខ្ញុំមិនទាន់។ ខ្ញុំគិតថា ប្រហែលខ្មែរក្រហមនោះស្គាល់ខ្ញុំហើយ ទើបក្រោយមកប្រធានកងស្នើដកខ្ញុំចេញពីក្រុមឡើងត្នោត និងឲ្យខ្ញុំទៅធ្វើចម្ការវិញ។ លើកនេះខ្ញុំកាន់តែភ័យ ព្រោះខ្ញុំបានប្រព្រឹត្តដោយផ្ទាល់។ ប៉ុន្តែសំណាងល្អ ខ្ញុំបានរួចផុតពីការសង្ស័យវិញ និងបានវិលត្រឡប់មកនៅក្នុងកងឡើងត្នោតវិញ»។

ក្រោយពីរបបខ្មែរក្រហមដួលរលំទៅ ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើប្រធានឃុំ។ អស់រយៈពេលបីឆ្នាំក្រោយមក ខ្ញុំក៏សុំលាឈប់ពីមេឃុំ ដោយសារមានទំនាស់ជាមួយសមាជិកឃុំឯទៀត។ បន្ទាប់មកខ្ញុំប្រកបរបរធ្វើស្រែ និងលក់សាច់ជ្រូក។



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកព្រៃកប្បាស ខេត្តតាកែវ ចូលរួមវេទិកាអប់រំពីការថែទាំសុខភាព រៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អន សំ ៖ ចែករំលែកចំណេះដឹងអំពីការថែទាំសុខភាព និងរឿងរ៉ាវឆ្លងកាត់របបខ្មែរក្រហម ទៅកាន់អ្នកជិតខាង និងសមាជិកគ្រួសារ

ផេង ពង្សរ៉ាស៊ី



អន សំ ភេទស្រី អាយុ៧១ឆ្នាំ បច្ចុប្បន្នរស់នៅភូមិស្នោ ឃុំស្នោ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ អន សំ ភេទស្រី អាយុ៧១ឆ្នាំ ជាជនជាតិខ្មែរ មានទីកន្លែងកំណើតនៅភូមិស្នោ ឃុំស្នោ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិឃុំដដែល។ សព្វថ្ងៃ ខ្ញុំប្រកបមុខរបរធ្វើស្រែ។ ស្ថានភាពគ្រួសាររបស់ខ្ញុំមានជីវភាពក្រីក្រ។ សព្វថ្ងៃ ខ្ញុំមានជំងឺលើសឈាម ជំងឺទឹកនោមផ្អែម ជំងឺក្រពះពោះវៀន និងជំងឺធ្លាក់ស។

ខ្ញុំធ្លាប់បានជួបជាមួយក្រុមការងារ និងចូលរួមកម្មវិធីរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ចំនួនពាដងរួចមកហើយ។ កម្មវិធីទាំងនោះគឺ ខ្ញុំផ្តល់បទសម្ភាសន៍ពីប្រវត្តិឆ្លងកាត់របបខ្មែរក្រហមដល់ចៅស្រី វណ្ណេត គឺជាអ្នកស្ម័គ្រចិត្តកម្ពុជារស់នៅក្នុងភូមិនេះ ក្នុងវេទិកាអប់រំថែទាំសុខភាព ពិនិត្យនិងពិគ្រោះយោបល់ពីបញ្ហាសុខភាព។ សម្រាប់ការជួបសម្ភាសន៍ពីប្រវត្តិឆ្លងកាត់របបខ្មែរក្រហម គឺអ្នកស្ម័គ្រចិត្តកម្ពុជាជាអ្នកជួបសម្ភាសន៍ផ្ទាល់ជាមួយខ្ញុំ។ ខ្ញុំបាននិយាយរៀបរាប់រឿងរ៉ាវការងាររបស់ខ្ញុំដូចជា ទៅដីកព្រែក ទៅធ្វើការតាមកងដោយមិនមានអាហារហូបចុកគ្រប់គ្រាន់ និងនិយាយប្រាប់អំពីការចាប់ខ្លួនខ្ញុំដោយកងឈ្លបខ្មែរក្រហមនៅវត្តចារដោយសារខ្ញុំបានលួចរត់មកផ្ទះវិញ។ ខ្ញុំពិតជាពេញចិត្តជាខ្លាំងក្នុងការដែលមានអ្នកស្ម័គ្រចិត្តកម្ពុជាមកសម្ភាសន៍រឿងរ៉ាវដែលខ្ញុំធ្លាប់បានឆ្លងកាត់។

ថ្ងៃមួយ ចៅស្រី វណ្ណេត ដែលជាអ្នកស្ម័គ្រចិត្តកម្ពុជា នោះបានមកផ្ទះខ្ញុំ ហើយបានអញ្ជើញខ្ញុំឲ្យទៅចូលរួមប្រជុំនៅភូមិសម្តេចពាន់។ ចៅស្រី បានប្រាប់ថាឲ្យទៅចូលរួមវេទិកាអប់រំពីការថែទាំសុខភាព ការពិនិត្យសុខភាព និងពិគ្រោះយោបល់អំពីបញ្ហាសុខភាពដោយមិនមានបង់ប្រាក់អ្វីឡើយ។ ខ្ញុំសប្បាយចិត្តដែរ ប៉ុន្តែខ្ញុំមិនទាន់ជឿជាក់ប៉ុន្មានទេ។ ខ្ញុំក៏បានសម្រេចចិត្តទៅចូលរួមតាមការអញ្ជើញ។ នៅក្នុងគ្រួសាររបស់ខ្ញុំមិនមាននរណារារាំង ឬហាមឃាត់មិនឲ្យខ្ញុំទៅចូលរួមទេ គឺកូនៗពេញចិត្តនឹងជូនខ្ញុំទៅទៀតផង។ មុនពេលចូលរួមក្នុងកម្មវិធី ខ្ញុំបានគិតថា ខ្ញុំនឹងទទួលបានផលប្រយោជន៍ដូចជាទទួលបានថ្នាំពេទ្យ និងការពិនិត្យសុខភាពដោយមិនអស់ប្រាក់តាមការប្រាប់របស់ចៅស្រី។

ក្នុងពេលចូលរួមកម្មវិធី ខ្ញុំបានធ្វើដំណើរទៅដោយមិនបានចំណាយអ្វីឡើយ ព្រោះមជ្ឈមណ្ឌលឯកសារកម្ពុជាជាអ្នកចំណាយលើការធ្វើដំណើររបស់ខ្ញុំ។ ខ្ញុំមិនមានអារម្មណ៍ថាធុញទ្រាន់ឡើយ អំឡុងពេលចូលរួមក្នុងកម្មវិធីនេះ ដោយសារខ្ញុំបានជួបជជែកពីបញ្ហាសុខភាពជាមួយគ្រូពេទ្យ និងបានជួបជាមួយអ្នកភូមិឯទៀតៗ។ ខ្ញុំនៅចាំបានថា កម្មវិធីនោះធ្វើឡើងគឺដើម្បីផ្តល់សេវាពិនិត្យសុខភាពដោយមិនអស់ប្រាក់ មានការណែនាំអប់រំពីបញ្ហាសុខភាព ហើយបានឲ្យកូនសៀវភៅមួយដែលនិយាយអំពីការថែទាំសុខភាពដល់ខ្ញុំ និងអ្នកឯទៀតដែរ។ ខ្ញុំទទួលបានចំណេះដឹងជាច្រើនពីកម្មវិធីមួយនោះ ដូចជា បានយល់ដឹងពីការថែទាំសុខភាព ការជ្រើសរើសម្ហូបអាហារដែលល្អសម្រាប់សុខភាព ការប្រើប្រាស់ថ្នាំឲ្យត្រូវតាមប្រភេទជំងឺ បានយល់ដឹងពីការពិនិត្យសុខភាពជាប្រចាំ គឺរៀងរាល់៦ខែម្តង និងបានយល់ដឹងពីការហាត់ប្រាណដែលជាផ្នែកមួយធ្វើឲ្យសុខភាពប្រសើរឡើង។ ក្នុងកម្មវិធីនោះ ខ្ញុំទទួលបានសេវាពិនិត្យសុខភាពដោយមិនអស់ប្រាក់ ការអប់រំអំពីបញ្ហាសុខភាព ឯកសារព័ត៌មានស្តីពីការថែទាំសុខភាព និងថវិកាសម្រាប់សោហ៊ុយធ្វើដំណើរទៅចូលរួមក្នុងកម្មវិធី។

បន្ទាប់ពីបានចូលរួម និងបានទៅទិញថ្នាំលេបតាមវេជ្ជបញ្ជារួចមក ស្ថានភាពជំងឺរបស់ខ្ញុំមានសភាពធូរស្រាលច្រើនជាងមុនៗ ជំងឺទឹកនោមផ្អែមរបស់ខ្ញុំក៏បានធូរស្បើយជាងមុនៗ ជាតិស្ករក្នុងឈាមរបស់ខ្ញុំក៏មិនសូវឡើងខ្លាំងដូចមុនៗ ខ្ញុំមានសង្ឃឹមច្រើនឡើងវិញពីបញ្ហាសុខភាពរបស់ខ្ញុំ។ ដោយសារតែខ្ញុំមានសភាពធូរស្បើយច្រើនពីជំងឺ ខ្ញុំសន្យាថា ខ្ញុំនៅតែបន្តប្រើប្រាស់ចំណេះដឹង និងអនុវត្តជាប្រចាំទៅលើការថែទាំសុខភាពជាប្រចាំថ្ងៃដោយខ្លួនឯង ហូបអាហារដែលល្អសម្រាប់សុខភាព ការប្រើប្រាស់ថ្នាំឲ្យបានត្រឹមត្រូវតាមវេជ្ជបញ្ជាគ្រូពេទ្យ ការតាមដានសុខភាពជាប្រចាំ និងការហាត់ប្រាណជាប្រចាំ។

ក្រោយពេលចូលរួមក្នុងកម្មវិធី ខ្ញុំបានចែករំលែកព័ត៌មាន និងចំណេះដឹងពីការថែទាំសុខភាពទៅអ្នកជិតខាង និងកូនចៅរបស់ខ្ញុំ ដូចជា ការថែទាំសុខភាពជាប្រចាំដោយខ្លួនឯង ការប្រើប្រាស់ថ្នាំឲ្យត្រូវតាមប្រភេទជំងឺ និងការធ្វើលំហាត់ប្រាណផ្សេងៗដើម្បីជួយដល់រាងកាយ។

ខ្ញុំពិតជាមានអារម្មណ៍ថា រីករាយដែលបានចូលរួមកម្មវិធីនេះ ហើយខ្ញុំសំណូមពរឲ្យមានការបង្កើតកម្មវិធីនេះទៀត ព្រោះធ្វើឲ្យប្រជាពលរដ្ឋជាច្រើនបានយល់ដឹងពីជំងឺរបស់ខ្លួន និងចេះថែទាំសុខភាពផ្ទាល់ខ្លួន។

## រឿងរ៉ាវឆ្លងកាត់របបខ្មែរក្រហម

ខ្ញុំកើតនៅក្នុងគ្រួសារកសិករមួយដែលមានបងប្អូនចំនួន១០នាក់ គឺស្រី៦នាក់ និងប្រុស៤នាក់។ ខ្ញុំមានកូនចំនួន៣នាក់ គឺប្រុស២នាក់ និងស្រី១នាក់។ នៅសម័យខ្មែរក្រហម ដំបូង ខ្ញុំធ្វើការងារជីកព្រែកនៅស្ពានហូរឈាម ហើយនៅទីនោះមិនសូវលំបាកទេ។ ក្រោយមក ខ្ញុំត្រូវបានខ្មែរក្រហមប្រើឲ្យទៅធ្វើត្រីប្រហុកនៅខេត្តកណ្តាលរយៈពេលកន្លះខែ ជាមួយអ្នកភូមិឯទៀតៗ។ បន្តមកទៀត ខ្ញុំ និងគ្រួសារត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅធ្វើការងារផ្សេងៗពីគ្នាពីភូមិមួយទៅភូមិមួយនៅក្នុងខេត្តតាកែវ។ ខ្ញុំ

បានធ្វើការនៅក្នុងកងចល័តក្នុងស្រុកអង្គរបុរី និងធ្វើការងារជាអ្នកថែទាំកុមារតូចៗ មានដូចជា ងូតទឹក និងដុសក្អែលឲ្យកុមារៗ កាលនោះ ខ្ញុំមានអាយុប្រហែល២១ឆ្នាំ។ បន្ទាប់មក ខ្ញុំបានទៅធ្វើការងារជីកព្រែកនៅវត្តថ្មីរយៈពេល២ទៅ៣ខែ ដោយខ្ញុំនៅក្នុងកងវរសេនាតូចលេខ១៣ ដែលមានមនុស្សចំនួន៤០០នាក់។ ខ្ញុំជីកព្រែកពីទំនប់ផ្កាឈូកទៅដល់ស្ទឹងព្រែកគ្រួសស្ថិតក្នុងខេត្តកណ្ដាល។ ក្រោយមក ខ្ញុំក៏បានមកធ្វើការងារជាអ្នកលើកភ្លឺស្រែ។ ខ្ញុំត្រូវបានខ្មែរក្រហមប្រើឲ្យទៅធ្វើស្រែ បោចស្ទូងក្នុងស្រែ និងធ្វើជីលេខ១ គឺជីលាមកមនុស្ស ដើម្បីដាក់ស្រែនៅត្រពាំងត្រកៀត។

ក្រោយពីធ្វើស្រែ ខ្ញុំត្រូវបានខ្មែរក្រហមប្រើឲ្យទៅទប់ទឹកនៅត្រពាំងរកាឈូក រយៈពេលមួយយប់មួយថ្ងៃ ទើបត្រឡប់មកនៅវត្តធម្មវិន័យវិញ។ កំឡុងពេលនោះដែរ ខ្ញុំបានហូបបាយ ឆ្អែតគ្រប់គ្រាន់។ ក្រោយពីស្នាក់នៅវត្តធម្មវិន័យមួយរយៈ ខ្ញុំត្រូវបានខ្មែរក្រហមផ្លាស់មកធ្វើការនៅក្នុងឃុំស្នោវិញ។ ខ្ញុំបានរៀបការជាមួយប្ដីរបស់ខ្ញុំឈ្មោះ មុំ។ បន្ទាប់ពីរៀបការរួចហើយ ខ្ញុំនិងប្ដីបានទៅរស់នៅវត្តចារ ដោយខ្មែរក្រហមប្រើឲ្យស្ទូងដកប្រហែល២ទៅ៣ខែ ទើបរបបខ្មែរក្រហមដួលរលំ។ អំឡុងពេលកងទ័ពវៀតណាមចូលមករំដោះ ខ្ញុំបាននាំគ្នារត់ទៅដល់មើមក្របិនខាងកើតសំរោងយ៉ោង ហើយក្រោយមកទើបត្រឡប់មករស់នៅភូមិកំណើតវិញ។ នៅក្នុងរបបខ្មែរក្រហម ប្អូនរបស់ខ្ញុំដែលមានអាយុប្រហែល១០ឆ្នាំ បានស្លាប់ដោយសារកើតជំងឺកញ្ជ្រឹល។



អន សំ អាយុ៧១ឆ្នាំ បច្ចុប្បន្នរស់នៅភូមិស្នោ ឃុំស្នោ ស្រុកព្រែកប្រាស ខេត្តតាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អ៊ូច ខេង៖ អាការជំងឺរបស់ខ្ញុំបានធូរស្រាលច្រើន បន្ទាប់ពីបានទទួលសេវាពិនិត្យសុខភាពរួច

ផេង ពង្សរ៉ាស៊ី



អ៊ូច ខេង អាយុ៦៣ឆ្នាំ បច្ចុប្បន្នរស់នៅភូមិទន្លែ ឃុំស្មោ ស្រុកព្រៃកប្បាស ខេត្តតាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ អ៊ូច ខេង ភេទស្រី អាយុ៦៣ឆ្នាំ ជាជនជាតិខ្មែរ មានទីកន្លែងកំណើតនៅភូមិក្តាញ់ ឃុំក្តាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ និងទីលំនៅបច្ចុប្បន្ននៅភូមិទន្លែ ឃុំស្មោ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ សព្វថ្ងៃខ្ញុំនៅផ្ទះមើលចៅៗ។ ស្ថានភាពគ្រួសាររបស់ខ្ញុំមានជីវភាពក្រីក្រ ហើយមានសុខភាពមិនសូវល្អប៉ុន្មានទេ។ បច្ចុប្បន្ន ស្ថានភាពជំងឺរបស់ខ្ញុំមានអាការធូរច្រើនហើយ បន្ទាប់ពីបានទៅពិនិត្យសុខភាព និងទទួលបានការអប់រំពីបញ្ហាសុខភាព ជាមួយក្រុមគ្រូពេទ្យ និងក្រុមការងាររបស់មជ្ឈ-មណ្ឌលឯកសារកម្ពុជារួចមក។ ប៉ុន្តែជំងឺទាំងនេះនៅមិនទាន់ជាសះស្បើយដាច់ស្រឡះទេ។ ខ្ញុំនៅមានអាការឈឺភ្នែក ឈឺតម្រងនោម និងក្តៅសាច់បន្តិចបន្តួចៗ ជាយូរមកហើយ ខ្ញុំតែងតែស្រវាំងភ្នែកៗ អ្នកភូមិបានប្រាប់ថា ខ្ញុំកើតជំងឺកន្ទុយថ្លែន ហើយពួកគាត់បានប្រាប់ខ្ញុំឲ្យបេះស្លឹកម្ជូរមកញីលើភ្នែកកើតកន្ទុយថ្លែននោះ ដើម្បីព្យាបាល។ រយៈពេលក្រោយមកភ្នែកខ្ញុំចេះតែឈឺផ្សា និងចេញទឹកភ្នែករហូត បន្ទាប់ពីភ្នែកខ្ញុំប៉ះនឹងខ្យល់ម្តងៗ។ ឥឡូវ មិនដូចមុនទេ! ខ្ញុំបានធូរស្រាលច្រើនហើយ។

ខ្ញុំធ្លាប់បានជួបជាមួយក្រុមការងាររបស់មជ្ឈ-មណ្ឌលឯកសារកម្ពុជា ចំនួនពីរដងកន្លងមកហើយ។ ជួបលើកទីមួយ គឺជួបជាមួយក្មួយស្រីម្នាក់រស់នៅក្នុងភូមិនេះដែរ។ ក្មួយស្រីបានប្រាប់ខ្ញុំ

ថា គាត់គឺជាអ្នកស្ម័គ្រចិត្តកម្ពុជានៅមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ នេះគឺជាលើកទីមួយក្នុងជីវិតខ្ញុំ ដែលខ្ញុំត្រូវក្មួយស្រីម្នាក់នោះសួរនាំពីប្រវត្តិរបស់ខ្ញុំឆ្លងកាត់របបខ្មែរក្រហម និងសួរសុខទុក្ខអំពីបញ្ហាសុខភាពខ្ញុំ។ ខ្ញុំនៅចងចាំថា ខ្ញុំបាននិយាយប្រាប់ក្មួយស្រីនោះអំពីរឿងរ៉ាវឆ្លងកាត់របបខ្មែរក្រហមថា កាលនោះ ខ្ញុំត្រូវខ្មែរក្រហមយកទៅដាក់ក្នុងកងស្រួចគឺកងកុមារឃុំ ដោយក្នុងមួយកងៗមានក្មេងៗចំនួនពី៥០ ទៅ៦០ ឬ ជិត១០០នាក់។ កងស្រួចនេះគ្រប់គ្រងដោយប្រធានក្រុមឈ្មោះហ៊ាន។ ខ្មែរក្រហមបានបង្ខំឲ្យខ្ញុំធ្វើការងារ ដូចជា ដកស្ទូង រែកដីដំបូកដាក់ស្រែ ជម្រះស្មៅ និងកាត់ស្មៅក្នុងទឹក។ ខ្ញុំប្រាប់ក្មួយស្រីពីរឿងរ៉ាវរបស់ខ្ញុំជាច្រើនទៀត។ ខ្ញុំពេញចិត្តចំពោះការជួបសម្ភាសន៍នេះណាស់ ព្រោះខ្ញុំចង់និយាយរឿងរ៉ាវរបស់ខ្ញុំប្រាប់ដល់ក្មេងជំនាន់ក្រោយ ដើម្បីបន្ធូរអារម្មណ៍ក្នុងចិត្តដែលខ្ញុំបានលាក់កប់ជាយូរមកហើយ។

រំលងបានប្រហែលមួយខែ លោកមេឃុំក្ដាញ់បានមកអញ្ជើញខ្ញុំឲ្យទៅចូលរួមក្នុងកម្មវិធីវេទិកាអប់រំអំពីការថែទាំសុខភាព ការពិនិត្យ និងពិគ្រោះពីបញ្ហាសុខភាព។ គាត់ប្រាប់ខ្ញុំថា ខ្ញុំនឹងទទួលបានសេវាពិនិត្យសុខភាព រកប្រភេទជំងឺដែលមាន និងស្ដាប់អំពីការអប់រំសុខភាព ដោយមិនមានបង់ប្រាក់កាសឡើយ។ ខ្ញុំសប្បាយចិត្តណាស់ ព្រោះខ្ញុំអាចដឹងអំពីប្រភេទជំងឺរបស់ខ្ញុំ។ នៅក្នុងក្រុមគ្រួសារខ្ញុំវិញ គឺមិនមានសមាជិកក្នុងគ្រួសារណាម្នាក់រារាំង ឬហាមឃាត់ខ្ញុំមិនឲ្យចូលរួមកម្មវិធីនេះឡើយ។ ខ្ញុំចង់ពិគ្រោះយោបល់ជាមួយគ្រូពេទ្យពីប្រភេទជំងឺដែលកំពុងកើតមានមកលើខ្ញុំសព្វថ្ងៃនេះ ដើម្បីឲ្យខ្ញុំបានធូរស្បើយពីជំងឺ។ ខ្ញុំពេញចិត្តចូលរួមក្នុងកម្មវិធីនេះណាស់។ មុននឹងចូលរួមក្នុងកម្មវិធីនេះ ខ្ញុំគិតថា ក្រៅពីពិនិត្យ ពិគ្រោះ និងអប់រំពីបញ្ហាសុខភាព គឺខ្ញុំអាចនឹងទទួលបានថ្នាំពេទ្យខ្លះមកព្យាបាលជំងឺ។ ប៉ុន្តែខ្ញុំមិនទទួលបានថ្នាំពេទ្យឡើយ ក្រោយពេលដែលខ្ញុំបានចូលរួមក្នុងកម្មវិធីនេះរួចមក។ នេះជាការជួបលើកទីពីររបស់ខ្ញុំជាមួយក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា។ ខ្ញុំនៅចាំបានពីក្មួយស្រីដែលធ្លាប់មកជួបសួរនាំខ្ញុំ។ ខ្ញុំអរគុណក្មួយស្រីណាស់ ដែលបានជួយដល់ខ្ញុំ។ ខ្ញុំមិនគិតស្មានដល់ថា ការជួបជាមួយកូនក្មួយស្រីអាចធ្វើឲ្យខ្ញុំមានឱកាសបានមកទទួលសេវាពិនិត្យសុខភាព និងរៀនសូត្រពីការថែទាំសុខភាពដូច្នេះសោះ។

ក្នុងពេលធ្វើដំណើរទៅចូលរួមក្នុងវេទិកាអប់រំពីការថែទាំសុខភាព និងការពិនិត្យសុខភាព និងពិគ្រោះយោបល់ពីបញ្ហាសុខភាពនេះ ខ្ញុំមិនបានចំណាយថវិកាផ្ទាល់ខ្លួនក្នុងការធ្វើដំណើរទៅកាន់ទីតាំងជួបជុំឡើយ។ ខ្ញុំដឹងថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានរ៉ាប់រងទាំងអស់ក្នុងការធ្វើដំណើររបស់ខ្ញុំទាំងទៅចូលរួម និងត្រឡប់មកផ្ទះវិញ។ ខ្ញុំមានការសប្បាយចិត្តក្នុងការចូលរួមក្នុងកម្មវិធីនេះជាខ្លាំង។ កាលនោះ ខ្ញុំនៅចាំបានថា ក្នុងកម្មវិធីនោះ គឺបានផ្ដល់សេវាពិនិត្យសុខភាពដោយមិនអស់ប្រាក់ និងផ្ដល់ការអប់រំពីបញ្ហាសុខភាព ដល់ខ្ញុំនិងអ្នកភូមិជាច្រើននាក់ទៀត។ ខ្ញុំរៀនសូត្របានច្រើនពីកម្មវិធីនេះ។ ខ្ញុំយល់ដឹងអំពីការថែទាំសុខភាព ជាពិសេសការថែទាំជំងឺប្រចាំកាយដែលកំពុងកើតមានរាល់ថ្ងៃដោយខ្លួនឯង។ ខ្ញុំយល់ដឹងពីការជ្រើសរើសម្ហូបអាហារដែលអាចទ្រទ្រង់ដល់សុខភាព និងម្ហូបអាហារដែលគួរចៀសវាង។ ខ្ញុំយល់ដឹងពីការប្រើប្រាស់ថ្នាំឲ្យត្រឹមត្រូវតាមប្រភេទជំងឺ និងយល់ដឹងពីការធ្វើលំហាត់ប្រាណប្រចាំថ្ងៃ។ ក្នុងកម្មវិធីនេះដែរ ខ្ញុំទទួលបានសេវាពិនិត្យសុខភាពដោយមិនអស់ប្រាក់ ការអប់រំពីបញ្ហាសុខភាព និងអាហារ។

បន្ទាប់ពីបានចូលរួមក្នុងកម្មវិធីនេះរួច ខ្ញុំបានចែករំលែកព័ត៌មានអំពីការថែទាំសុខភាពដល់អ្នកជិតខាងរបស់ខ្ញុំ រួមទាំងបងប្អូនរបស់ខ្ញុំដែរ។ ខ្ញុំបានប្រាប់ទៅអ្នកទាំងនោះថា យើងត្រូវថែទាំសុខភាពខ្លួនឯងឲ្យបានល្អ ជាពិសេសការថែទាំជំងឺប្រចាំកាយ

ដែលកំពុងកើតមានរាល់ថ្ងៃ។ យើងត្រូវដឹងពីការជ្រើសរើសម្ហូបអាហារដែលអាចទ្រទ្រង់ដល់សុខភាពយើង និងម្ហូបអាហារដែលគួរចៀសវាង។ យើងត្រូវយល់ដឹងពីការប្រើប្រាស់ថ្នាំឲ្យត្រឹមត្រូវតាមប្រភេទជំងឺ និងត្រូវធ្វើការហាត់ប្រាណជាប្រចាំ។

បន្ទាប់ពីបានចូលរួមក្នុងកម្មវិធីនេះ និងបានទទួលវេជ្ជបញ្ជាពីគ្រូពេទ្យរួច ខ្ញុំបានទៅទិញថ្នាំពីហ្វាម៉ាស៊ីមកលេបតាមវេជ្ជបញ្ជា។ ពីមួយថ្ងៃទៅមួយថ្ងៃ ស្ថានភាពជំងឺរបស់ខ្ញុំមានសភាពធូរស្រាលជាងមុនច្រើន។ ខ្ញុំអាចសម្រាកបានគ្រប់គ្រាន់។ ខ្ញុំលែងសូវក្តៅសាច់ដូចមុន ហើយភ្នែករបស់ខ្ញុំ ក៏បានធូរស្រាលខ្លះៗដែរ។ រហូតមកដល់ពេលនេះ ខ្ញុំនៅតែបន្តប្រើប្រាស់ចំណេះដឹងដែលខ្ញុំទទួលបានពីការចូលរួមក្នុងកម្មវិធីអប់រំសុខភាព។ ខ្ញុំនៅតែបន្តការថែទាំសុខភាពខ្លួនឯងជាប្រចាំ។ ខ្ញុំហូបអាហារដែលមានវីតាមីន ហើយមិនហូបអាហារណាដែលធ្វើឲ្យសុខភាពខ្ញុំធ្លាក់ចុះឡើយ។ ខ្ញុំក៏នៅតែបន្តប្រើប្រាស់ថ្នាំឲ្យត្រឹមត្រូវតាមវេជ្ជបញ្ជាគ្រូពេទ្យ។ ខ្ញុំហាត់ប្រាណរាល់ថ្ងៃ។ ទោះជាមិនបានហាត់ប្រាណ ក៏ខ្ញុំធ្វើនេះធ្វើនោះក្នុងផ្ទះ ដូចជាការហាត់ប្រាណដែរ។ ខ្ញុំនៅតែបន្តអនុវត្តចំណេះដឹងទាំងនេះជារៀងរហូត។

ក្រោយពេលខ្ញុំបានចូលរួមក្នុងកម្មវិធីវេទិកាអប់រំពីការថែទាំសុខភាព និងការពិនិត្យសុខភាព និងពិគ្រោះយោបល់ពីបញ្ហាសុខភាពមក ភ្នែក និងជំងឺក្តៅសាច់ខ្ញុំបានធូរស្រាលមួយចំនួនហើយ។ ខ្ញុំមានអារម្មណ៍សប្បាយចិត្តដែលបានពិគ្រោះជំងឺជាមួយគ្រូពេទ្យ និងបានចែករំលែករឿងរ៉ាវក្នុងរបបខ្មែរក្រហមជាមួយអ្នកចូលរួមកម្មវិធី។ ខ្ញុំសំណូមពរឲ្យបង្កើតកម្មវិធីនេះលើកក្រោយ សូមផ្តល់ថ្នាំសង្កូវខ្លះៗដើម្បីប្រើប្រាស់ប្រចាំថ្ងៃផង។

## រឿងរ៉ាវឆ្លងកាត់របបខ្មែរក្រហម

ខ្ញុំកើតក្នុងគ្រួសារក្រីក្រមួយ មានបងប្អូនបួននាក់ គឺស្រីពីរនាក់ និងប្រុសពីរនាក់។ ខ្ញុំមានស្រុកកំណើតនៅភូមិក្តាញ់ ឃុំក្តាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ ម្តាយរបស់ខ្ញុំបានស្លាប់បាត់បង់ជីវិតតាំងពីខ្ញុំនៅតូចម្ល៉េះ។ ឪពុករបស់ខ្ញុំប្រកបរបរលក់សាច់គោ សាច់ជ្រូក និងសម្លខ្មែរ នៅក្នុងភូមិ។ រាល់ថ្ងៃឪពុកខ្ញុំដឹកសាច់គោ សាច់ជ្រូក និងសម្ល ទៅលក់តាមផ្ទះអ្នកភូមិ។ នៅថ្ងៃមួយ ឪពុករបស់ខ្ញុំបានសម្រេចចិត្តជ្រើសរើសគ្រួសារថ្មីមួយទៀត ជាមួយស្ត្រីមេម៉ាយម្នាក់នៅក្នុងភូមិជាមួយគ្នា។ ស្ត្រីមេម៉ាយនោះមានកូនបីនាក់រួចហើយ។ ឪពុករបស់ខ្ញុំបានបោះបង់របរលក់សាច់គោ សាច់ជ្រូក និងសម្លខ្មែរ ហើយប្តូរមកលក់ស្ករពាងវិញ។ ពេលយប់ឪពុកខ្ញុំរែកស្ករពីសំរោងយ៉ោង ទៅលក់នៅភូមិតាមដងទន្លេក្នុងឃុំសំប៉ាន ភូមិឫស្សីដាច់ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល។ ពេលឪពុកខ្ញុំចេញទៅជួញស្ករបាត់ ម្តាយចុងតែងតែធ្វើបាបខ្ញុំ និងមិនដែលទំនុកបម្រុងដូចជាការស្លៀកពាក់ និងការហូបចុកបានគ្រប់គ្រាន់ឡើយ។ ម្តាយចុងរបស់ខ្ញុំគិតគូរតែពីកូនបង្កើតរបស់គាត់ប៉ុណ្ណោះ។

ក្រោយមក ខ្ញុំបានចេញទៅលក់ស្ករជាមួយឪពុកខ្ញុំ ព្រោះខ្លាចម្តាយចុងធ្វើបាប។ ឪពុករបស់ខ្ញុំក៏មិនបានហាមឃាត់ខ្ញុំដែរ ព្រោះគាត់ដឹងថាប្រពន្ធក្រោយរបស់គាត់ធ្វើបាបខ្ញុំ។ ខ្ញុំរត់ពីក្រោយឪពុកខ្ញុំ ពេលគាត់រែកស្ករលក់។ ឪពុករបស់ខ្ញុំតែងតែទិញនំចំណីឲ្យខ្ញុំហូបឆ្អែតៗ ទើបយើងត្រឡប់មកផ្ទះវិញ។ ក្រោយមក ឪពុករបស់ខ្ញុំមានកូនចំនួនបួននាក់ទៀតជាមួយនឹងម្តាយចុង។

នៅក្នុងរបបខ្មែរក្រហម ខ្ញុំមិនត្រូវបានខ្មែរក្រហមជម្លៀសទៅទីណាឡើយ។ លើកលែងតែឪពុកនិងម្តាយចុងរបស់ខ្ញុំត្រូវខ្មែរក្រហមជម្លៀសទៅស្រុកអង្គរបូរី។ កូនស្រីរបស់ម្តាយក្រោយខ្ញុំឈ្មោះ ផល ហៅ ផ បានស្លាប់បាត់បង់ជីវិតនៅស្រុកអង្គរបូរី ដោយសារអត់អាហារ។ រឿងរ៉ាវដែលខ្ញុំចងចាំមិនអាចបំភ្លេចបាននោះ គឺខ្មែរក្រហមមិនឲ្យខ្ញុំរស់នៅក្នុងផ្ទះសម្បែងរបស់ខ្ញុំ ហើយមិនអនុញ្ញាតឲ្យខ្ញុំហូបដំណាំ និងផ្លែឈើដែលខ្ញុំដាំឡើយ។

# អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តពោធិ៍សាត់ ទស្សនាព្រះរាជបណ្ណាល័យហ្វ្លងម៉ែ

## នៃមជ្ឈមណ្ឌលឯកសារកម្ពុជា និងសំណេះសំណាលជាមួយលោក ឆាំង យុ

**មឿន ស្រីណុច និង ឡាំ ស្រីនីត**



នាព្រឹកថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៤ យុវជន និងអ្នកស្ម័គ្រចិត្តកម្ពុជា ចំនួន៣៨នាក់ មកពីខេត្តពោធិ៍សាត់ មកទស្សនកិច្ចសិក្សានៅព្រះរាជបណ្ណាល័យ ហ្វូងម៉ែ។
(ធី គីមហុង/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





នាព្រឹកថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៤ យុវជន និងអ្នកស្ម័គ្រចិត្តកម្ពុជាចំនួន៣៨នាក់ មកពីខេត្តពោធិ៍សាត់ បន្ទាប់ពីត្រឡប់មកពីដំណើរទស្សនកិច្ចសិក្សាតាម «ផ្លូវរថភ្លើងខ្មែរក្រហម៖ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ» ដោយផ្តោតសំខាន់ទៅលើការជម្លៀសប្រជាជនដោយបង្ខំលើកទី៣ អំឡុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) រួច យុវជន និង អ្នកស្ម័គ្រចិត្តកម្ពុជា ទាំងអស់ ត្រូវបន្តមកទស្សនកិច្ចព្រះរាជបណ្ណាល័យ ហ្វូងម៉ែ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយមានការស្វាគមន៍ពីលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។ លោកនាយកបានទទួលស្វាគមន៍ និង សួរពីចំណាប់អារម្មណ៍របស់យុវជន និងអ្នកស្ម័គ្រចិត្តអំពីការសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហមតាមរយៈ១) ការសិក្សាតាមថ្នាក់រៀន២) ការសិក្សាតាមរយៈផ្លូវរថភ្លើង និង ៣) ការចុះទៅជួបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមផ្ទាល់។ តើមួយណាមានការយល់ដឹង និងមានប្រសិទ្ធភាពខ្លាំងជាង?

បន្ទាប់ពីសំណួរខាងលើ យុវជន និង អ្នកស្ម័គ្រចិត្តភាគច្រើនបានឆ្លើយថា ការរៀនប្រវត្តិសាស្ត្រកម្ពុជា





នាព្រឹកថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៤ អ្នកស្ម័គ្រចិត្តកម្ពុជាចំនួន៣៨នាក់ មកពីខេត្តពោធិ៍សាត់ មកទស្សនកិច្ចសិក្សានៅព្រះរាជបណ្ណាល័យ ហ្វូងម៉ែ។
(ធី គីម ហុង/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) តាមរយៈចុះទៅជួបអ្នករស់រានមានជីវិតផ្ទាល់នៅតាមភូមិរបស់គាត់គឺមានប្រសិទ្ធភាពខ្ពស់ជាងគេ។ យុវជនបានយល់ដឹងរឿងរ៉ាវអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមកាន់តែច្បាស់ ដឹងពីបញ្ហាសុខភាពផ្លូវកាយ ផ្លូវចិត្ត និងសុខភាពប្រចាំថ្ងៃរបស់ចាស់ៗ។ ការជួបផ្ទាល់ធ្វើឲ្យយុវជនស្ម័គ្រចិត្តមានអារម្មណ៍កាន់តែអាណិតអាសូរដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមថែមទៀត។ ចំណែកការសិក្សាបែបធ្វើដំណើរទស្សនកិច្ចតាមផ្លូវរថភ្លើងល្អម៉្យាងដែរ ព្រោះអាចបង្កឲ្យមានការធ្វើការជាក្រុម ស្គាល់មិត្តភក្តិថ្មីៗ និងបានស្គាល់ទីកន្លែងថ្មីៗជាច្រើនដែលត្រូវសិក្សា។ អ្នកស្ម័គ្រចិត្តក៏បានលើកឡើងនូវបញ្ហាប្រឈមមួយចំនួនអំឡុងដំណើរទស្សនកិច្ចសិក្សាតាមផ្លូវរថភ្លើងខ្មែរក្រហម «ស្តីអំពីអំពើប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ ការជម្លៀសប្រជាជនដោយបង្ខំនៅដំណាក់កាលទី៣» ដូចជា៖ ១) ពេលជិះរថភ្លើងពីភ្នំពេញទៅខេត្តកំពត រថភ្លើងបានខូចនៅតាមផ្លូវ ដែលជាហេតុធ្វើឲ្យអ្នកស្ម័គ្រចិត្តមួយចំនួនហត់នឿយអស់កម្លាំង។ ២) អ្នកស្ម័គ្រចិត្តមានកិច្ចការច្រើន ធ្វើឲ្យគេងមិនបានគ្រប់គ្រាន់។ ៣) មេឃក្តៅខ្លាំង ហើយនៅថ្ងៃទី៣ នៃដំណើរទស្សនកិច្ចសិក្សាមេឃភ្លៀងខ្លាំងខណៈពេលកំពុងទស្សនាភូមិបាក់នឹម ធ្វើឲ្យយុវជនមួយចំនួនទទឹកភ្លៀង។

ឆ្លើយតបនឹងចំណុចខាងលើ លោកនាយកបានមានប្រសាសន៍ថា «បញ្ហាខាងលើ មិនមែនជាបញ្ហាធំឡើយ ដូចជាការធ្វើការងារច្រើនវាធ្វើឲ្យយើងមានភាពធន់ និងមានប្រៀបច្រើនជាងយុវជនដទៃទៀត ពីព្រោះសង្គមកាន់មានភាពប្រកួតប្រជែងច្រើនឡើងៗ។ ចំពោះការដែលមានភ្លៀងធ្លាក់មកនោះជារឿងល្អវិញទេ»។ ជាចុងក្រោយ លោកនាយកបានផ្តាំផ្ញើអ្នកស្ម័គ្រចិត្តកម្ពុជា ទាំងអស់ត្រូវរក្សាទំនាក់ទំនងជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា និងមិត្តភក្តិដែលបានចូលរួមដំណើរទស្សនកិច្ចសិក្សាតាមផ្លូវរថភ្លើងខ្មែរក្រហម អំពីអំពើប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ ការជម្លៀសប្រជាជនដោយបង្ខំនៅដំណាក់កាលទី៣នេះ។

# មជ្ឈមណ្ឌលផ្សះផ្សាវាលវែង រៀបចំដំណើរទស្សនកិច្ចសិក្សាអំពីសិទ្ធិមនុស្ស

## និងប្រជាធិបតេយ្យ និងវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដល់សិស្សមកពីខេត្តពោធិ៍សាត់

**មឿន ស្រីណុច**




*ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២៤ អ្នកស្ម័គ្រចិត្តកម្ពុជាប្រចាំខេត្តពោធិ៍សាត់ ចំនួន៣៨នាក់ ក្នុងចំណោមនោះមានស្រី២០នាក់ ចូលរួមដំណើរទស្សនកិច្ចសិក្សាអំពីសិទ្ធិមនុស្ស និងប្រជាធិបតេយ្យ ដោយផ្តោតសំខាន់លើការជម្លៀសប្រជាជនដោយបង្ខំដំណាក់កាលទី៣ និងវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។*
*(ទាវ សម្ផស្ស/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

វេលាម៉ោង៦ព្រឹក ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២៤ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង យុវជន និងអ្នកស្ម័គ្រចិត្តកម្ពុជាប្រចាំខេត្តពោធិ៍សាត់ ចំនួន៣៨នាក់ ក្នុងចំណោមនោះមានស្រី២០នាក់ បានធ្វើដំណើរពីខេត្តពោធិ៍សាត់ទៅកាន់ទីក្រុងភ្នំពេញ។ យុវជនទាំង៣៨នាក់ មកពីវិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ វិទ្យាល័យភ្នំក្រវាញ និងវិទ្យាល័យតាលោសែនជ័យ។ នៅវេលាម៉ោង១២ថ្ងៃត្រង់ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង និងអ្នកស្ម័គ្រចិត្តកម្ពុជាទាំងអស់បានមកដល់ទីក្រុងភ្នំពេញ។ នៅវេលាម៉ោង២រសៀល ក្រុមអ្នកស្ម័គ្រចិត្តបានមកជុំគ្នានៅអាគារ CJCC (ស៊ីជេស៊ីស៊ី) នៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ ដើម្បីចូលរួមវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិ-សាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ផ្តោតលើការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងការជម្លៀសប្រជាជនដោយបង្ខំដំណាក់កាលទី២




*ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២៤ អ្នកស្ម័គ្រចិត្តកម្ពុជាប្រចាំខេត្តពោធិ៍សាត់ ចំនួន៣៨នាក់ ក្នុងចំណោមនោះមានស្រី២០នាក់ បានធ្វើដំណើរពីខេត្តពោធិ៍សាត់ទៅកាន់ទីក្រុងភ្នំពេញ ដើម្បីចូលរួមដំណើរទស្សនកិច្ចសិក្សាអំពីសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ និង វេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ យុវជនទាំង៣៨នាក់ មកពីវិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ វិទ្យាល័យភ្នំក្រវាញ និងវិទ្យាល័យតាលោសែនជ័យ។ ( ទាវ សម្ផស្ស/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

និងទី៣ និយមន័យអំពើប្រល័យពូជសាសន៍ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍។

វត្ថុបំណងនៃការរៀបចំវេទិកាថ្នាក់រៀនគឺ ដើម្បីផ្តល់ឲ្យសិស្សានុសិស្សមានការយល់ដឹងនិងសិក្សារៀនសូត្របន្ថែម អំពីអត្ថប្រយោជន៍ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) និយមន័យនៃអំពើប្រល័យពូជសាសន៍ ការទប់ស្កាត់ និងកត្តាដែលនាំឲ្យកើតមានផលប៉ះពាល់នាពេលអនាគត។ យុវជនត្រូវមានគំនិតផ្លាស់ប្តូរការគិតពីការប្រព្រឹត្តអំពើហិង្សា ទៅជាការជំរុញពីការពិភាក្សាអំពីកេរដំណែលប្រវត្តិសាស្ត្រនៅក្នុងសង្គមគ្រួសារ សហគមន៍ និងប្រទេសជាតិ។

ជាកិច្ចចាប់ផ្តើមលោក ឡុង ដានី នាយកមជ្ឈមណ្ឌលដង្វះដង្វាវាលវែង និងក្រុមការងារបានប្រាប់អ្នកស្ម័គ្រចិត្តកម្ពុជា អំពីប្រវត្តិនៃការបង្កើតមជ្ឈមណ្ឌលដង្វះដង្វាវាលវែង នៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៣ ព្រមទាំងគោលបំណងចំនួន ៤ដូចខាងក្រោម៖ ១) ដើម្បីបង្ហាញពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាចាប់ពីទសវត្សរ៍ឆ្នាំ១៩៧០ រហូតដល់ទសវត្សរ៍ឆ្នាំ១៩៩០។ ២) ដើម្បីពង្រឹងដល់ដំណើរការសន្តិភាព និងការទប់ស្កាត់ជម្លោះនានាតាមរយៈកម្មវិធីអប់រំ។ កម្មវិធីអប់រំនេះ និងផ្តល់ឱកាសឲ្យសិស្សានុសិស្សជំនាន់ក្រោយដែលភាគច្រើនរស់នៅតាមទីជនបទបានមកចូលរួមរៀនសូត្រ។ ៣) លើកទឹកចិត្តដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ក្នុងការចែករំលែកអំពីរឿងរ៉ាវ និងបទពិសោធន៍ផ្ទាល់ខ្លួនដល់សិស្សានុសិស្សជំនាន់ក្រោយ។ និង ៤) ប្រមែប្រមូលរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងទីតាំងបទឧក្រិដ្ឋដែលបានបន្សល់ពីរបបខ្មែរក្រហម។

បន្ទាប់មកលោក ឡុង ដានីបានធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រខ្មែរក្រហម (១៩៧៥-១៩៧៩) លើប្រធានបទការឡើងកាន់អំណាចរបស់ខ្មែរក្រហម, ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និង ការជម្លៀសដោយបង្ខំដំណាក់កាល ទី២ និង ទី៣ និយមន័យអំពើប្រល័យពូជសាសន៍ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍។ វិធីសាស្ត្រ K-W-L និងអំណានជំពូក គឺចំណុចពិសេសក្នុងការបង្រៀនយុវជនឲ្យឆាប់ចាប់បានក្នុងមេរៀនប្រវត្តិសាស្ត្រ

ខ្មែរក្រហម។ លោក ឡុង ដានី ក៏បានរៀបរាប់ពីព្រឹត្តិការណ៍សង្ខេបដូចជា៖ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីកងទ័ពខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញបានរយៈពេល២ទៅ៣ម៉ោង មេដឹកនាំខ្មែរក្រហមបានបញ្ជាឲ្យកងទ័ពខ្មែរក្រហមចាប់ផ្តើមជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ និងទីប្រជុំជននានា ទៅធ្វើការងារពលកម្មដ៏លំបាកវេទនានៅតាមវាលស្រែនៃតំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជា។ កងទ័ពខ្មែរក្រហមបានយកលេសក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញថា សហរដ្ឋអាមេរិកនឹងមកទម្លាក់គ្រាប់បែកនៅទីក្រុងភ្នំពេញ ប្រជាជនត្រូវជម្លៀសចេញពីទីក្រុងភ្នំពេញតែរយៈពេល៣ថ្ងៃនឹងបានវិលត្រឡប់មកផ្ទះវិញហើយ ដូច្នេះប្រជាជនទាំងអស់មិនចាំបាច់យកទ្រព្យសម្បត្តិច្រើនទៅតាមខ្លួន និងចាក់សោផ្ទះទេ។ ប៉ុន្តែការពិតខ្មែរក្រហមមិនបានអនុញ្ញាតឲ្យប្រជាជនត្រឡប់មកផ្ទះវិញពេញមួយរបបកម្ពុជាប្រជាធិប-តេយ្យ (១៩៧៥-១៩៧៩)។ ចាប់តាំងពីចុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានការផ្លាស់ទីប្រជាជនជាពិសេសប្រជាជនថ្មីបង្ខំឲ្យផ្លាស់ទីពីតំបន់មួយទៅតំបន់មួយទៀត ម្តងហើយម្តងទៀត នៅក្នុងភូមិភាគកណ្តាល ភូមិភាគនិរតី ភូមិភាគបស្ចិម ភូមិភាគបូព៌ា (រួមបញ្ចូលទាំងការផ្លាស់ទីតាមរយៈរថភ្លើងពីភូមិភាគនិរតី និងភូមិភាគបស្ចិម ទៅកាន់ភូមិភាគពាយ័ព្យ)។ ការផ្លាស់ទីប្រជាជននេះពុំមានជូនដំណឹងជាមុន ដែលបង្កជាទុក្ខវេទនា និងភាពលំបាកលំបិនដល់ប្រជាជន និងសហគមន៍ជាខ្លាំង។ ចាប់តាំងពីកងទ័ពខ្មែរក្រហមធ្វើសង្គ្រាមតាមព្រំដែនជាមួយប្រទេសវៀតណាម នៅចុងឆ្នាំ១៩៧៧ ខ្មែរក្រហមចាប់ផ្តើមលែងទុកចិត្តលើកម្មាភិបាល យុទ្ធជន និងប្រជាជននៅភូមិភាគបូព៌ា។ ប្រជាជនភូមិភាគបូព៌ាត្រូវបានខ្មែរក្រហមចោទប្រកាន់ថាជាមនុស្សក្បត់អង្គការ «ក្បាលយួនខ្លួនខ្មែរ»។ ប្រជាជនភូមិភាគបូព៌ាទាំងអស់ជាគោលដៅនៃការជម្លៀសដោយបង្ខំចេញពីភូមិភាគបូព៌ាទៅភូមិភាគពាយ័ព្យភូមិភាគកណ្តាល និងភូមិភាគឧត្តរ។ ការជម្លៀសដោយបង្ខំនេះបានបណ្តាលឲ្យប្រជាជនភូមិភាគបូព៌ាជាច្រើនបានស្លាប់ដោយសារខ្មែរក្រហមសម្លាប់ អត់អាហារ និងជំងឺគ្មានថ្នាំព្យាបាល។ ចុងបញ្ចប់នៃវេទិកាថ្នាក់រៀន លោក ឡុង ដានី បានធ្វើបទបង្ហាញជាសង្ខេបអំពីដំណើរការអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សំណុំរឿង 001 និងសំណុំរឿង ០០២ (សំណុំរឿង០០២ វគ្គទី១ និងសំណុំ០០២ វគ្គទី២)។ និយមន័យអំពើប្រល័យពូជនៅសាសន៍ ធាតុផ្សំនៃអំពើប្រល័យពូជសាសន៍ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍។

## ចំណាប់អារម្មណ៍របស់អ្នកស្ម័គ្រចិត្តកម្ពុជា និង យុវជន៖ ស៊ុក វិសាល

ខ្ញុំបាទឈ្មោះ ស៊ុក វិសាល រៀនថ្នាក់ទី១២ នៅវិទ្យាល័យ ហ៊ុនសែនប្រម៉ោយ។ បន្ទាប់ពីបានចូលរួមក្នុងវេទិកាថ្នាក់រៀននេះហើយ ខ្ញុំទទួលបានចំណេះដឹងពីលោកគ្រូ ឡុង ដានី ទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យកាន់តែច្បាស់ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និង បានដឹងពីមេដឹកនាំជាន់ខ្ពស់របស់របបកម្ពុជាប្រជាធិបតេយ្យដែលបានប្រព្រឹត្តអំពើឧក្រិដ្ឋកម្មដ៏ឃោរឃៅមកលើប្រជាជន។ ខ្ញុំថែមទាំងបានដឹងពីការជម្លៀសប្រជាជនដោយបង្ខំពីទីក្រុងទៅតាមទីជនបទ ដោយយកមធ្យោបាយជាច្រើនប្រភេទផ្សេងៗគ្នា ដូចជាតាមផ្លូវគោក ផ្លូវទឹក និងផ្លូវដែក។ មួយវិញទៀតខ្ញុំគិតថា ការបង្កើតវេទិកាថ្នាក់រៀនមួយនេះ ពិតជាបានផ្តល់ផលល្អខ្លាំងណាស់សម្រាប់ខ្ញុំ ព្រោះខ្ញុំបានសិក្សាឈ្វេងយល់ពីប្រវត្តិ-សាស្ត្រប្រទេសកម្ពុជា ដែលនៅក្នុងរបបខ្មែរក្រហមបានប្រើប្រាស់របបផ្តាច់ការទៅលើប្រជាជន បង្កឲ្យបាត់បង់ជីវិតប្រជាជនអស់ជាង២លាននាក់។ ក្រោយពីខ្ញុំបានចូលរួមក្នុងវេទិកាថ្នាក់រៀននេះហើយ ខ្ញុំពិតជាមានការសោកស្តាយទៅកាន់ប្រជាជនដែលបានឆ្លងកាត់របបខ្មែរក្រហម បច្ចុប្បន្នមានអ្នកខ្លះពិការ និងបែកបាក់ បាត់បង់សាច់ញាតិបងប្អូន។

## លី និរតី

នាងខ្ញុំឈ្មោះ លី និរតី ជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យតាលោសែនជ័យ បន្ទាប់ពីបានចូលរួមក្នុងវេទិកាថ្នាក់រៀនហើយ ខ្ញុំទទួលបានចំណេះដឹងជាច្រើនដូចជា៖ ដឹងយ៉ាងស៊ីជម្រៅពីរបបកម្ពុជាប្រជាធិបតេយ្យ, ដឹងពីគោលនយោបាយរបស់ខ្មែរក្រហម, យល់ដឹងពីដំណើរការដឹកនាំប្រទេសដោយបក្សកុម្មុយនីស្ត, ការបង្ខិតបង្ខំឲ្យប្រជាជនធ្វើការងារហួសកម្លាំង គ្មានអាហារហូបគ្រប់គ្រាន់, ការបង្ខំឲ្យប្រជាជនផ្លាស់ទីពីទីក្រុងទៅទីជនបទដើម្បីធ្វើស្រែចម្ការ, ការបង្កើតសហករណ៍កម្រិតខ្ពស់ទូទាំងប្រទេស និង បានដឹងពីដើមហេតុ ដែលនាំឲ្យកើតមានសង្គ្រាម។

## នៅ ផានិត

ខ្ញុំបាទឈ្មោះ នៅ ផានិត ជាសិស្សថ្នាក់១២A នៃវិទ្យាល័យ ហ៊ុនសែនប្រម៉ោយ បន្ទាប់ពីបានចូលរួមក្នុងវេទិកាថ្នាក់រៀនក្នុងថ្ងៃនេះ ខ្ញុំបាទទទួលបានចំណេះដឹងជាច្រើនពីរបបខ្មែរក្រហម។ ក្នុងរយៈពេល៣ឆ្នាំ៨ខែ២០ថ្ងៃ ខ្មែរក្រហមបានសម្លាប់ប្រជាជនខ្មែរអស់ជាច្រើននាក់ និងបន្សល់ទុកក្មេងកំព្រា ស្ត្រីមេម៉ាយ រួមទាំងជនពិការជាច្រើន។ ខ្ញុំបានដឹងពីការជម្លៀសដោយបង្ខំមាន៣ដំណាក់កាលគឺ ដំណាក់កាលទី១នៅថ្ងៃទី១៧ ខែមេសា ដល់ខែកញ្ញា ឆ្នាំ១៩៧៥។ ដំណាក់កាលទី២ ពីខែកញ្ញា ឆ្នាំ១៩៧៦រហូតដល់ចុងឆ្នាំ។ ដំណាក់កាលទី៣ ពីចុងឆ្នាំ១៩៧៧ ដល់ចុងឆ្នាំ១៩៧៨ ហើយខ្ញុំក៏បានស្គាល់ឈ្មោះមេដឹកនាំក្នុងរបបខ្មែរក្រហម និងការកាត់ទោស ដែលមេដឹកនាំខ្មែរក្រហមបានប្រព្រឹត្តមកលើប្រជាជនស្លូតត្រង់។

ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២៤ អ្នកស្ម័គ្រចិត្តកម្ពុជាប្រចាំខេត្តពោធិ៍សាត់ ចំនួន៣៨នាក់ ក្នុងចំណោមនោះមានស្រី២០នាក់ បានធ្វើដំណើរពីខេត្តពោធិ៍សាត់ទៅកាន់ទីក្រុងភ្នំពេញ ដើម្បីចូលរួមដំណើរទស្សនកិច្ចសិក្សាអំពីសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ និង វេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ យុវជនទាំង៣៨នាក់ មកពីវិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ វិទ្យាល័យភ្នំក្រវាញ និងវិទ្យាល័យតាលោសែនជ័យ។
( ទាវ សម្ផស្ស/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា )



# គ្រូបង្គោលថ្នាក់ជាតិមុខវិជ្ជាប្រវត្តិសាស្ត្រកម្ពុជា

## ប្រជាធិបតេយ្យ បង្ហាញចំណាប់អារម្មណ៍ផ្ទាល់ខ្លួន បន្ទាប់ពីចូលរួមសន្និសីទលើកទី១ ស្ដីពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍» ពីថ្ងៃទី២០ ដល់ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤

*ផេង ពង្សរ៉ាស៊ី*




គ្រូបង្គោលប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចូលរួមសន្និសីទលើកទី១ ស្តីពី អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍ ដែលប្រព្រឹត្តឡើងពីថ្ងៃទី២០-២២ ខែឧសភា ឆ្នាំ២០២៤ នៅសាលយុត្តិតេជោ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានអញ្ជើញគ្រូបង្គោលថ្នាក់ជាតិ ផ្នែកប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) មកចូលរួមសន្និសីទលើកទីមួយ ស្តីពី «**អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍**»៖ ការពារ និងឆ្លើយតប តាមរយៈការអប់រំ និងការថែទាំសុខភាពរយៈពេល៣ថ្ងៃ គឺចាប់ពីថ្ងៃទី២០ដល់ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤។

សន្និសីទនេះ ត្រូវបានរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយខុទ្ទកាល័យរបស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងមហាវិទ្យាល័យច្បាប់ ប៊ិសស្ទី នៃសាកលវិទ្យាល័យតេមផលសហរដ្ឋអាមេរិក ដោយមានការគាំទ្រពី ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ និងផ្តល់ទីកន្លែងដោយ ទីបញ្ជាការដ្ឋានកងទ័ពជើងគោក នៃកងយោធពលខេមរភូមិន្ទ។ សន្និសីទនេះមានវាគ្មិនជាតិ និងអន្តរជាតិជាច្រើននាក់

ដែលសុទ្ធសឹងជាអ្នកជំនាញផ្នែកអប់រំ សុខាភិបាល សិទ្ធិមនុស្ស និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍បានចូលរួម។

ខាងក្រោមគឺជាចំណាប់អារម្មណ៍របស់លោកគ្រូ និងអ្នកគ្រូដែលបានចូលរួមសន្និសីទរយៈពេល ៣ថ្ងៃ៖

### ១) ស៊ីវ ឆ្លួន

ខ្ញុំបានចូលរួមនៅក្នុងសន្និសីទថ្នាក់អន្តរជាតិក្រោមប្រធានបទ «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍» ដែលមានការចូលរួមពីវាគ្មិនជាតិនិងអន្តរជាតិល្បីៗ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមកពីខេត្តក្រុងទូទាំងប្រទេសកម្ពុជា ចាប់ពីថ្ងៃទី២០ ដល់ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤ កន្លងទៅ។ សន្និសីទនេះបានផ្តល់នូវចំណេះដឹងជាច្រើនដល់ខ្ញុំ។ អ្វីដែលអស្ចារ្យគឺពេលបើកសន្និសីទ និងបិទសន្និសីទមានវត្តមានដ៏ខ្ពង់ខ្ពស់ពីសម្តេចបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ដែលជាកិត្តិយសដ៏ខ្ពង់ខ្ពស់បំផុត។

អស់រយៈពេលជិត៥០ឆ្នាំហើយ ដែលរបបខ្មែរក្រហមបានដួលរលំ ប៉ុន្តែស្នាមរបួសនៅតែឈឺចាប់នៅឡើយ ទោះបីជាតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទើបតែបិទបញ្ចប់ទៅថ្មីៗក៏ដោយ។ វត្តមានរបស់តា យាយ ទាំងអស់នៅក្នុងសន្និសីទនៅពេលនេះ គឺជាការលើកទឹកចិត្តដល់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានខិតខំប្រឹងប្រែងធ្វើការកន្លងមក ដើម្បីផ្តល់នូវការគោរព និងដឹងគុណដល់អ្នកដែលបានឆ្លងកាត់របបប្រល័យពូជសាសន៍ខ្មែរក្រហមដែលបានខិតខំតស៊ូរហូតមកដល់សព្វថ្ងៃ។ ការបង្រៀនសៀវភៅប្រវត្តិសាស្រ្ត និងសៀវភៅណែនាំគ្រូដែលចម្រាញ់ចេញពីសាច់រឿងដ៏រន្ធត់របស់ជនរងគ្រោះ របស់មជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីចែកចាយចំណេះដឹងដល់ក្មេងជំនាន់ក្រោយតាមរយៈគ្រូបង្គោលថ្នាក់ជាតិ និងថ្នាក់ខេត្ត គឺជាស្ពានចម្លងដ៏សំខាន់ក្នុងការតភ្ជាប់បទពិសោធន៍នាសម័យកាលដ៏ខ្មៅងងឹតរបស់ខ្មែរក្រហម ទៅនឹងការរីកលូតលាស់នាពេលបច្ចុប្បន្នដែលក្មេងៗត្រូវតែចូលរួម ដើម្បីកសាងអនាគតកម្ពុជាដែលគ្មានអំពើប្រល័យពូជសាសន៍។

ចាប់ពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០មក មជ្ឈមណ្ឌលឯកសារកម្ពុជា បានខិតខំយ៉ាងខ្លាំងក្លា ដើម្បីប្រមូល ចងក្រងឯកសារ ផ្សព្វផ្សាយ និងអប់រំចំណេះដឹងបន្ថែមពីរបបខ្មែរក្រហមតាមរយៈការបង្រៀនផ្លូវការ និងមិនផ្លូវការ ព្រមទាំងបោះពុម្ពទស្សនាវដ្តីស្វែងរកការពិតប្រចាំខែ និងព្រឹត្តិបត្រផ្សេងៗ ជាភាសាជាតិ និងអន្តរជាតិ ដើម្បីចែកជូនដល់អ្នកអាន។

ខ្ញុំចាប់អារម្មណ៍ខ្លាំងនៅក្នុងអង្គសន្និសីទនេះ គឺនៅថ្ងៃទីពីរអំឡុងពេលដែលវាគ្មិនពិភាក្សាលើប្រធានបទទាក់ទងនឹងការអប់រំពីអំពើប្រល័យពូជសាសន៍ ដែលមានការចូលរួមពិភាក្សាពីអ្នកជំនាញបរទេស អ្នករស់រានមានជីវិតពីរបបខ្មែរ ពុទ្ធបរិស័ទកាន់ព្រះពុទ្ធសាសនា អ្នកកាន់សាសនាអ៊ិស្លាម និងក្មួយៗដែលជាយុវជនវ័យក្មេងៗ។ ក្នុងឱកាសនោះ ខ្ញុំក៏បានរៀនសូត្របន្ថែមពីសន្និសីទដែរគឺ៖

- ឥទ្ធិពលនៃព្រះពុទ្ធសាសនា ក្នុងការបង្រៀនពីរបបខ្មែរក្រហម ដើម្បីការទប់ស្កាត់អំពើនេះនាពេលអនាគត។

- ការត្រិះរិះពិចារណាលើការសម្លាប់រង្គាល និងការកើតមានអំពើប្រល័យពូជសាសន៍ ដែលផ្តើមគំនិតចេញពីមេដឹកនាំខ្មែរក្រហម ប៉ុល ពត និង នួន ជា ព្រមទាំងកម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហមខ្លះទៀតដែលសុទ្ធសឹងជាអ្នកមានចំណេះដឹងជ្រៅជ្រះ។

សន្និសីទលើកទី១នេះ មានការចូលរួមពីគ្រប់សមាសភាព គឺ យាយ តា អ្នកប្រណិប័តន៍សាសនា កសិករ អ្នកជំនួញ មន្ត្រីចូលនិវត្តន៍ និងបរទេស។ អ្នកទាំងនេះត្រូវបានមជ្ឈមណ្ឌលឯកសារកម្ពុជា អញ្ជើញមកចូលរួមដោយមានការរៀបចំមធ្យោបាយធ្វើដំណើរ សណ្ឋាគារសម្រាប់ស្នាក់នៅ អាហារហូបចុក និងគ្រូពេទ្យចាំថែទាំ។

អ្នកចូលបានអង្គុយស្តាប់វាគ្មិនបកស្រាយដោយមិនធុញទ្រាន់ នៅក្នុងសាលម៉ាស៊ីនត្រជាក់ដ៏ទូលាយ និងគ្មានសំឡេងរំខាន។ នៅក្នុងវគ្គពិភាក្សាក៏មានការ

ចោទជាសំណួរ និងឆ្លើយយ៉ាងផុសផុលដែរ។ វត្តមានវាគ្មិនបរទេសបាននាំរឿងរ៉ាវទុក្ខវេទនារបស់ប្រជាជនកម្ពុជា ដើម្បីឲ្យមានការទទួលស្គាល់មិនត្រឹមតែក្នុងតំបន់ប៉ុណ្ណោះទេ ប៉ុន្តែបានល្បីខ្ចរខ្ចាយពេញពិភពលោកទាំងមូល។ ការបង្កើតឲ្យមានសន្និសីទលំដាប់អន្តរជាតិបែបនេះ ត្រូវប្រើរយៈពេលយូរមុននឹងលេចចេញជារូបរាងឡើង នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤។

ប្រសិនបើគ្មានជំនួយពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ ហៅកាត់ថា USAID និងការចាត់ចែងពីមជ្ឈមណ្ឌលឯកសារកម្ពុជាទេ សន្និសីទនេះនឹងពុំកើតឡើងឡើយ។ ពេលត្រឡប់ទៅផ្ទះ និងស្រុកកំណើតវិញ ខ្ញុំនិងអ្នកចូលរួមនឹងបន្តនិយាយអំពីរឿងរ៉ាវដែលកើតឡើងក្នុងរបបខ្មែរក្រហមប្រាប់ទៅសាច់ញាតិ និងសហគមន៍។

**២) សេង លីរតនៈ**

***«រយៈពេល៣ថ្ងៃ នៅសាលយុត្តិតេជោ» អនុស្សាវរីយ៍ និងការចងចាំ!***

ខ្លួនខ្ញុំផ្ទាល់ ខ្ញុំពិតជាមានមោទកភាពក្រៃលែងដែលត្រូវបានមជ្ឈមណ្ឌលឯកសារកម្ពុជា អញ្ជើញឲ្យចូលរួមក្នុងអង្គសន្និសីទលើកទី១ ក្រោមប្រធានបទ៖ «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍៖ ការពារ និងឆ្លើយតបតាមរយៈការអប់រំ និងការថែទាំសុខភាព» ពីថ្ងៃទី២០ ដល់ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤ នាសាលយុត្តិតេជោ ស្ថិតក្នុងបរិវេណបញ្ជាការដ្ឋានកងទ័ពជើងគោកនៃកងយោធពលខេមរភូមិន្ទ ដែលជាអតីតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បុសាលាក្តីខ្មែរក្រហម។

ជាកិត្តិយសដ៏ក្រៃលែងសម្រាប់រូបខ្ញុំ ដែលខ្ញុំបានចូលរួមនៅក្នុងសន្និសីទដែលមានការចូលរួមជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ពីសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា តំណាងអង្គការសហប្រជាជាតិ និងទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ ព្រមទាំងភាគីពាក់ព័ន្ធជាតិ និងអន្តរជាតិជាច្រើនរូបទៀត។ ខ្ញុំក៏សង្កេតឃើញនូវវត្តមានរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដ៏ច្រើនកុះករ នៅក្នុងអង្គសន្និសីទដែលវត្តមាននេះញ៉ាំងឲ្យអង្គពិធីទាំងមូលប្រព្រឹត្តទៅដោយរលូន និងមានអត្ថន័យបំផុត។ ក្នុងនាមខ្ញុំគឺជាគ្រូបង្រៀនប្រវត្តិវិទ្យាម្នាក់ ខ្ញុំសូមថ្លែងអំណរគុណចំពោះការរៀបចំសន្និសីទដ៏មានអត្ថន័យនេះ។

បទបង្ហាញនៅក្នុងអង្គសន្និសីទជាបន្តបន្ទាប់បានបញ្ជាក់យ៉ាងច្បាស់អំពីជំហរយ៉ាងរឹងមាំរបស់កម្ពុជាថា កម្ពុជាគឺជាម្ចាស់ប្រវត្តិសាស្ត្រដ៏ជូរចត់ដែលបានកើតឡើងកន្លងមកក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ហើយកម្ពុជាបានព្យាយាមខិតខំប្រឹងប្រែងបណ្តុះការចងចាំអំពីប្រវត្តិសាស្ត្រនេះ ដើម្បីចូលរួមជាមួយរដ្ឋាភិបាលក្នុងការរារាំង និងទប់ស្កាត់ប្រវត្តិសាស្ត្រដ៏ជូរចត់នេះមិនឲ្យកើតមាននៅលើទឹកដីរបស់ខ្លួន និងរលាយបាត់ពីក្នុងសកលលោក។

ពិតណាស់ ការពិភាក្សាដេញដោលអំពីរឿងរ៉ាវប្រវត្តិសាស្ត្រជាតិ គឺជារឿងសំខាន់ដែលមិនអាចខ្វះបាន។ ការសន្ទនាអន្តរជំនាន់រវាងយុវជនជំនាន់ក្រោយ និងអ្នកឆ្លងកាត់ប្រវត្តិសាស្ត្រខ្មែរក្រហម គឺជាគុណប្រយោជន៍មួយដ៏ធំធេង ដែលកូនចៅជំនាន់ក្រោយត្រូវតែរួមគ្នា សហការគ្នា និងពួតដៃគ្នាធ្វើយ៉ាងណាលុបបំបាត់រាល់អំពើហិង្សាគ្រប់ទម្រង់ ដើម្បីរក្សាសន្តិភាព សាមគ្គីភាព និងអភិវឌ្ឍន៍ប្រទេសជាតិឲ្យមានភាពរីកចម្រើន ដោយគ្មានការរំខានពីអំពើឃោរឃៅនាពេលអនាគត។ យ៉ាងណាមិញ ទិដ្ឋភាពផ្នែកច្បាប់ និងការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធជាតិ និងអន្តរជាតិ ក៏បានឆ្លុះបញ្ចាំងឲ្យយើងឃើញអំពីស្មារតីគោរពសិទ្ធិមនុស្ស អធិបតេយ្យភាព ឯករាជ្យភាព និងបូរណភាពទឹកដីរបស់ប្រទេសនីមួយៗ ដែលទាមទារឲ្យមានការរក្សាបាននូវសន្តិសុខជាតិដោយមិនមានការជ្រៀតជ្រែកឬគាបសង្កត់ពីសំណាក់ប្រទេសដទៃដើម្បីកុំឲ្យអំពើហិង្សាគ្រប់ទម្រង់កើតមានឡើងទៀត ព្រោះវាអាចជាប្រភពដែលនាំឲ្យកើតមានឡើងនូវឧក្រិដ្ឋកម្មនានា ដូចជាឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍។

ជាស្មារតីសុទិដ្ឋិនិយមរបស់ខ្ញុំ ខ្ញុំបាទសង្ឃឹមយ៉ាងមុតមាំថា អំពើប្រល័យពូជសាសន៍នឹងមិនអាចកើតមានសារជាថ្មីនៅលើទឹកដីកម្ពុជាបានឡើយ ព្រោះយើងបានរួបរួមគ្នា បំផុសស្មារតីស្រឡាញ់សន្តិភាព សាមគ្គីភាព ការគោរពសិទ្ធិមនុស្ស និងចូលរួមអភិវឌ្ឍន៍ជាតិប្រកបដោយមនសិការ និងទំនួលខុសត្រូវខ្ពស់បំផុត។

ខ្ញុំសូមឲ្យកិច្ចសហការនេះ កើតមានឡើង និងរក្សាបាននូវប្រសិទ្ធភាពជារៀងរហូត។ ខ្ញុំសូមឲ្យគ្រប់ដៃគូជាតិ និងអន្តរជាតិ ដែលពាក់ព័ន្ធនឹងការងារនេះរក្សាបាននូវទំនាក់ទំនងល្អជារៀងដរាប។ ខ្ញុំសូមឲ្យកម្ពុជាមានសុខសន្តិភាព និងការអភិវឌ្ឍន៍ជារៀងរហូត។

ខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលតែងតែផ្តល់ឱកាសឲ្យខ្ញុំបាទបានចូលរួមក្នុងអង្គពិធីសំខាន់ៗនាពេលកន្លងមក និងពេលថ្មីៗនេះ ជាពិសេសប្រធានបទថ្មីៗ ចំណេះដឹងថ្មីៗ ពាក់ព័ន្ធទៅនឹងការរួមគ្នាទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជា។

ខ្ញុំបាទសូមសន្យាថា ខ្ញុំនឹងចូលរួមផ្សព្វផ្សាយនូវអនុសាសន៍គន្លឹះសំខាន់ៗ ដែលទទួលបានពីអង្គសន្និសីទ និងចែករំលែកទៅដល់មនុស្សជុំវិញខ្លួន ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍កុំឲ្យកើតមានសារជាថ្មីនៅកម្ពុជា។

ខ្ញុំសូមគោរពជូនពរមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាតួអង្គដ៏ស័ក្តិសម និងសំខាន់មិនអាចខ្វះបានក្នុងការចងក្រង និងផ្សព្វផ្សាយអំពីប្រវត្តិ-សាស្ត្រជាតិកម្ពុជា សូមទទួលបាននូវភាពរីកចម្រើនសុខដុមរមនា ពោរពេញទៅដោយវឌ្ឍនភាពតរៀងទៅ។ សូមអរគុណ!

### ៣) សម ទិចិត្រ

ខ្ញុំបាទពិតជាមានក្តីសោមនស្ស និងរីករាយក្រៃលែង ដោយត្រូវបានអញ្ជើញឲ្យចូលរួមធ្វើជាវាគ្មិនក្នុងសន្និសីទលើកទី១ ស្តីពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍ការពារ និងឆ្លើយតបតាមរយៈការអប់រំ និងការថែទាំសុខភាព» ចាប់ពីថ្ងៃទី២០ ដល់ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤ នៅសាលយុត្តិតេជោ រាជធានីភ្នំពេញ។ សន្និសីទនេះមានការចូលរួមជាគណៈអធិបតីដ៏ខ្ពង់ខ្ពស់បើកដោយសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងបិទសន្និសីទដោយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងនាមជាគ្រូបង្រៀនប្រវត្តិសាស្ត្រ និងគ្រូឧទ្ទេសថ្នាក់ជាតិជំនាញប្រវត្តិសាស្ត្រកម្ពុជាប្រជា-ធិបតេយ្យ(១៩៧៥-១៩៧៩)ម្នាក់ ខ្ញុំបាទពិតជាមានកិត្តិយសក្រៃលែងដែលបានធ្វើជាវាគ្មិនក្នុងកិច្ចពិភាក្សា ស្តីពី «យុវជន និងការអប់រំឧក្រិដ្ឋកម្មឃោរឃៅ»។ នេះ គឺជាលើកទី១ក្នុងឆាកជីវិតរបស់ខ្ញុំ ដែលបានចូលរួមក្នុងកម្មវិធីដ៏ធំបែបនេះ ដែលមានអ្នកចូលរួមពីថ្នាក់ដឹកនាំកំពូលរបស់ជាតិ និងអន្តរជាតិ និងបានចែករំលែកនូវបទពិសោធន៍ផ្ទាល់ខ្លួនពាក់ព័ន្ធនឹងការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហម ដើម្បីចូលរួមអប់រំ ផ្តល់វិធីសាស្ត្រជាច្រើនក្នុងការទប់ស្កាត់អំពើឧក្រិដ្ឋកម្មដ៏ឃោរឃៅដល់យុវជនជំនាន់ក្រោយកុំឲ្យអំពើនេះកើតឡើងវិញក្នុងទឹកដីនៃប្រទេសកម្ពុជា ក្នុងតំបន់ និងក្នុងពិភពលោក។

លើសពីនេះទៅទៀត ខ្ញុំបាទក៏ទទួលបាននូវបទពិសោធន៍ល្អៗ និងចំណេះដឹងថ្មីៗជាច្រើនទៀត ពីប្រសាសន៍ដ៏មានអត្ថន័យបំផុតរបស់សម្តេច វាគ្មិនជាតិនិងអន្តរជាតិដែលបានចែករំលែកនូវបទពិសោធន៍ដឹកនាំល្អៗ ក្នុងការចូលរួមចែករំលែកនៅក្នុងកិច្ចពិភាក្សាលើប្រធានបទសំខាន់ៗទាំង៥គឺ៖ ១) អំពើប្រល័យពូជសាសន៍និងអនុសញ្ញាបង្ការ និងផ្តន្ទាទោសអំពើប្រល័យពូជសាសន៍ ២) ការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ៣) យុវជន និងការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ៤) សុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និង ៥) តួនាទីស្ថាបត្យកម្ម និងសំណង់ក្នុងការ

ផ្សះផ្សាផ្លូវចិត្តរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ មិនតែប៉ុណ្ណោះ ខ្ញុំបាទបានទទួលនូវចំណេះដឹងក្នុងការរៀបចំដឹកនាំកម្មវិធីធំៗបែបនេះឲ្យទទួលបានជោគជ័យដោយរលូនផងដែរ។

ជាចុងក្រោយ ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់មជ្ឈមណ្ឌលឯកសារកម្ពុជា និងជាពិសេសលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបន្តផ្តល់ឱកាសដល់រូបខ្ញុំបាទជាបន្តបន្ទាប់ជារៀងរហូតមក។ ខ្ញុំបាទសង្ឃឹមថាយើងនឹងនៅតែបន្តការសហការគ្នា ដើម្បីចូលរួមចំណែកក្នុងការផ្សារជួយដល់សង្គមជាតិរបស់យើងទាំងអស់គ្នា ពិសេសចូលរួមចំណែកជ្រោមជ្រែងឲ្យអនាគតប្រទេសកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍។

### ៤) អ៊ុំ ថារ៉ា

ខ្ញុំបាទឈ្មោះ អ៊ុំ ថារ៉ា គឺជាគ្រូខ្ទេសថ្នាក់ជាតិមកពីស្រុកស្រីសន្ធរ ខេត្តកំពង់ចាម មានកិត្តិយសក្រៃលែង ដែលលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្តល់ឱកាសឲ្យខ្ញុំចូលរួមក្នុងសន្និសីទលើកទី១ ស្តីពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍៖ ការពារ និងឆ្លើយតបតាមរយៈការអប់រំ និងការថែទាំសុខភាព» រយៈពេល៣ថ្ងៃ ចាប់ពីថ្ងៃទី២០ ដល់ថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០២៤ នៅក្នុងសាលយុត្តិធេជោ រាជធានីភ្នំពេញ។

ខ្ញុំសង្កេតឃើញថា ការប្រព្រឹត្តទៅនៃសន្និសីទនេះរាប់ទាំងការធ្វើដំណើរ ការស្នាក់នៅ ការទទួលទានអាហារ ការគ្រប់គ្រងអ្នកចូលរួម ការចាត់ចែងពេលវេលា ការរើសយកទីកន្លែងសម្រាប់ស្នាក់នៅ និងទីកន្លែងសម្រាប់ប្រារព្ធពិធី គឺធ្វើបានល្អទាំងអស់។

ចំណែកការប្រព្រឹត្តទៅនៃសន្និសីទវិញ ខ្ញុំទទួលបានធាតុចូលយ៉ាងច្រើន ដូចជា៖ ប្រសាសន៍បើកអង្គសន្និសីទរបស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្រ្តីនៃព្រះរាជាណាចក្រកម្ពុជា ការចូលរួមមតិនិងការធ្វើបទបង្ហាញរបស់វាគ្មិនជាតិ និងអន្តរជាតិ ការផ្តល់ពេលវេលាសម្រាប់សួរសំណួរ ការបកស្រាយសំណួរ ជាពិសេសការមានប្រសាសន៍បើក និងបិទអង្គសន្និសីទរបស់សម្តេចទាំងពីរគឺ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភាកម្ពុជា និងជាប្រធានឧត្តមក្រុមប្រឹក្សាព្រះមហាក្សត្រកម្ពុជា។ ទាំងអស់នេះ សុទ្ធតែជាធាតុចូលសម្រាប់ជាគន្លឹះក្នុងការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងជាគន្លឹះនៃការអប់រំផ្សព្វផ្សាយដល់យុវជនជំនាន់ក្រោយ ក្នុងការទប់ស្កាត់ការវិលត្រឡប់នៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា ក៏ដូចជាក្នុងពិភពលោក។ សូមលោកនាយក និងសហការី ទទួលនូវការគោរពរាប់អាន ដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

### ៥) រស់ ចាន់ថន

នាងខ្ញុំ រស់ ចាន់ថន បានធ្វើដំណើរពីខេត្តតាកែវ ទៅភ្នំពេញដើម្បីចូលរួមសន្និសីទលើកទី១ ក្រោមប្រធានបទ «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍» នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០២៤ នៅឯសាលយុត្តិធេជោ ស្ថិតក្នុងបរិវេណបញ្ជាការដ្ឋានកងទ័ពជើងគោកនៃកងយោធពលខេមរភូមិន្ទ។ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីបើកសន្និសីទ ដែលមានអ្នកចូលរួមចំនួន៨២០នាក់ មានភ្ញៀវជាតិ អន្តរជាតិ អ្នកស្ម័គ្រចិត្តកម្ពុជា អ្នករស់រានមានជីវិតពីរបបប្រល័យពូជសាសន៍ ប៉ុល ពត អង្គទូត និងមន្ត្រីជាន់ខ្ពស់ជាច្រើនទៀត។ សន្និសីទនេះរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។

នាងខ្ញុំបានទទួលចំណេះដឹងថ្មីៗ ល្អៗ ពីវាគ្មិនដែលបានធ្វើបទបង្ហាញស្តីពី អនាគតប្រទេសកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍, អនុសញ្ញាបង្ការនិងផ្តន្ទាទោសអំពើប្រល័យពូជសាសន៍, ការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះពីរបបខ្មែរក្រហម, ការអប់រំយុវជនឲ្យយល់ច្បាស់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម,

បញ្ហាសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងវិធីសាស្ត្រទប់ស្កាត់កុំឲ្យអំពើប្រល័យពូជសាសន៍កើតឡើងនៅក្នុងប្រទេសកម្ពុជាម្តងទៀត។ របបខ្មែរក្រហមបានហាមប្រាមការប្រណិប័តន៍សាសនា បិទវត្តអារាម សាលារៀន មន្ទីរពេទ្យ ទីផ្សារ និងបិទសិទ្ធិសេរីភាពប្រជាជន។ ខ្មែរក្រហមអប់រំមនុស្សមិនឲ្យទុកចិត្តគ្នា។ សន្និសីទនេះ ក៏យកចិត្តទុកដាក់លើបញ្ហាសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ហើយ នាងខ្ញុំក៏ទទួលបានចំណេះដឹងថ្មីៗពីវាគ្មិនដែលបានធ្វើបទបង្ហាញ ដូចជាជំងឺស្ទះសរសៃឈាម និងជំងឺផ្សេងៗទៀត ។

លើសពីនេះ ខ្ញុំបានទស្សនាខ្សែភាពយន្តឯកសាររឿង «កុំស្មានបងភ្លេច» តាមរយៈភាពយន្តឯកសារនេះធ្វើឲ្យខ្ញុំនឹកឃើញពីការលំបាកវេទនា ការរត់គេចពីគ្រាប់បែកដែលអាមេរិកទម្លាក់មកលើប្រទេសកម្ពុជា ធ្វើឲ្យបេះដូងខ្ញុំញាប់ញ័រ។ នៅក្នុងឱកាសនោះ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បានលើកឡើងថា ទោះបីមានមនុស្សស្លាប់ក្នុងរបបខ្មែរក្រហមពិតមែន ប៉ុន្តែវប្បធម៌មិនស្លាប់នោះទេ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំបានទទួលព័ត៌មានថា កងទ័ពខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ និងបានបណ្តេញប្រជាជនចេញពីផ្ទះសម្បែងដោយឃោសនាថាអាមេរិកាំងមកទម្លាក់គ្រាប់បែក។ ប្រជាជនប្រញាប់ប្រញាល់រៀបចំចាកចេញពីទីក្រុងភ្នំពេញភ្លាមៗ។ ប្រជាជនបានរស់នៅក្នុងរបបថ្មី គឺរបប ប៉ុល ពត អស់រយៈពេល៣ឆ្នាំ ៨ខែ និង២០ថ្ងៃ ហើយនេះគឺជារឿងរ៉ាវប្រវត្តិសាស្ត្រដែលប្រជាជនកម្ពុជាមិនអាចបំភ្លេចបាន។

ខ្ញុំតែងតែក្តុកក្តួលក្នុងចិត្ត ស្រក់ទឹកភ្នែក ពេលនឹកឃើញដល់ឪពុក និងប្អូនប្រុសស្លាប់ក្នុងរបបខ្មែរក្រហមយ៉ាងវេទនា។ ខ្មែរក្រហមបានបង្អត់អាហារប្រជាជន បង្ខំប្រជាជនឲ្យធ្វើការហួសកម្លាំង មិនផ្តល់សម្លៀកបំពាក់ឲ្យប្រជាជន និងសម្លាប់ប្រជាជនដោយគ្មានការពិចារណា។ សន្និសីទនេះបានធ្វើឲ្យអន្តរជាតិទទួលស្គាល់ថា ប្រទេសកម្ពុជាមានរបបប្រល័យពូជសាសន៍ និងទុកជាឯកសារសម្រាប់អ្នកជំនាន់ក្រោយបានសិក្សា ហើយជឿជាក់ថារបបខ្មែរក្រហមមានពិតមែន។ សន្និសីទលើកទី១នេះ ក៏ធ្វើឲ្យនាងខ្ញុំចេះខន្តីផ្អែកលើធម៌ព្រះពុទ្ធសាសនា និងធ្វើឲ្យខ្ញុំចេះអធ្យាស្រ័យផ្សះផ្សាគ្នា។

នៅថ្ងៃបញ្ចប់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងជាប្រធានព្រឹទ្ធសភាចូលរួមជាគណៈអធិបតីដ៏ខ្ពង់ខ្ពស់ ដើម្បីថ្លែងសុន្ទរកថាបិទសន្និសីទលើកទី១ ស្តីពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍»។ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អំពាវនាវឲ្យប្រទេសមហាអំណាច និងអ្នកជំនាញខាងច្បាប់ជាតិ និងអន្តរជាតិ ព្រមទាំងប្រវត្តិវិទូ ដាក់ទណ្ឌកម្មចំពោះអ្នកណាដែលថា ប្រទេសកម្ពុជាគ្មានរបបប្រល័យពូជសាសន៍។

ជាចុងក្រោយ នាងខ្ញុំគឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមសូមថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជា និងប្រទេសផ្តល់ជំនួយដែលផ្តល់ឱកាសឲ្យនាងខ្ញុំបានចូលរួមក្នុងសន្និសីទលើកទី១ ស្តីពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍»។ នាងខ្ញុំបានទទួលយកចំណេះដឹងថ្មីៗ និងល្អៗពីសន្និសីទនេះ។



លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាស្ថាបនិកព្រះរាជបណ្ណាល័យហ្វូងម៉ែ ឡើងធ្វើបទបង្ហាញអំពីខ្សែភាពយន្តឯកសាររឿង «កុំស្មានបងភ្លេច ខ្មែរបាត់បង់តន្ត្រីរ៉ក់» នៅក្នុងសន្និសីទលើកទី១ ស្តីពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍» នៅសាលយុត្តិតេជោ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ការិយាល័យព័ត៌មានសាធារណៈ













«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍អំពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង រស់ សំពៅ អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៨៨២ ៥០៥ ឬ

អ៊ីម៉ែល ៖ truthsampeou.r@dccam.org

សូមអរគុណ!















# ជីវិតកូនប្រុសពុកក្នុងគុកខ្មែរក្រហម (ត)

ហង្ស ឆាំឆាន

### ៣.៧. ការចោទប្រកាន់ថាជាសាស្ត្រាចារ្យ និងខាយខ្ញុំ (ត)

ត្របែក សួរខ្ញុំថា ម៉េចហើយអូន គេមានវាយឬអត់? ខ្ញុំអួលដើមកនិយាយមិនរួចបានត្រឹមលើកដៃចង្អុលទៅកន្លែងដាច់ហូរឈាមៗ មិនបង្អង់បងសុន ក៏ទំពារត្រួយត្របែកបិទឲ្យៗ ពេលឡើងទៅលើផ្ទះក្នុងគុកមានពិរុទ្ធជនជាច្រើនមកលួចសួរខ្ញុំ ជាពិសេសគេចង់ដឹងថាមានវាយច្រើនឬតិច ហើយគេសន្និដ្ឋានថាប្អូនឯងអត់អីទេ ប៉ុណ្ណឹងអាចរួចទៅផ្ទះវិញៗ ល្ងាចម៉ោង២ខ្ញុំអត់ហ៊ានសម្រាកទេ ទៅធ្វើការតាមធម្មតាដើរកាត់មុខមន្ទីរមានអ្នកសម្លឹងមកខ្ញុំជាច្រើន ខ្ញុំធ្វើមិនដឹងដើរហួសទៅធ្វើការសែងដីដូចធម្មតារហូតដល់ពេលបាយ ល្ងាចចូលដាក់ខ្នោះ៤ដូចធម្មតាៗ

### ៣.៨. ខ្ញុំត្រូវទៅស្រោចទឹកដាំឪឡឹក និងការសួរចម្លើយឈ្មោះ គី

ព្រឹកឡើងពូ មឿង ហៅខ្ញុំចេញពីជួរចាត់ឲ្យទៅរែកទឹកស្រោចឪឡឹកឋិតនៅក្បែរកន្លែងសួរចម្លើយ ខ្ញុំពីម្សិលមិញៗ តាមពិតកន្លែងសួរចម្លើយឋិតនៅ ខាងត្បូងចម្ងាយ២០០ម៉ែត្រពីមន្ទីរសន្តិសុខរួម អ្នកទោសទាំងអស់ក្នុងស្រុកកោះជ័យមុននឹងបញ្ជូនទៅកន្លែងផ្សេងត្រូវយកមកសួរចម្លើយកន្លែងនេះ ពេលលែង ឬមុនហ្នឹងសម្លាប់ក៏ត្រូវយកមកកន្លែងនេះដែរៗ ម្ល៉េះហើយ កន្លែងសួរចម្លើយរវល់ច្រើនពេលខ្ញុំរែកទឹកស្រោចឪឡឹកថ្ងៃដំបូងពុំហ៊ានទៅជិតទេ ឃើញគេសួរអ្នកទោសដូចខ្ញុំ តែក្រោយមកឃើញគេចងមុខ ចងដៃដូចខ្ញុំ មកសួរចម្លើយក៏សសៀររែកទឹកនៅជិតលួចមើល និងលួចស្តាប់ៗ ថ្ងៃមួយអ្នកទោសម្នាក់ដែលរស់នៅភូមិជាមួយខ្ញុំឈ្មោះ គី ទើបនឹងមកដល់ល្ងាចមិញគេចងយកមកសួរចម្លើយ ខ្ញុំដឹងថា អាគី (គាត់អាយុតិចជាងខ្ញុំ) គេហៅមកសួរ ហើយចង់ដឹងថាវាមានរឿងអ្វី ព្រោះវាមិនចេះអក្សរទេមិនទាន់ទាំងទៅដល់ផង ស្រាប់តែឃើញគេចងជើង អាគី ព្យួរឡើងលើដើមអូយម៉ូយក្បាលដាំចុះ ជ្រលក់ចូលក្នុងពាងទឹកនៅពីក្រោមរួចវាយ សួរបន្តបន្ទាប់ចំនួន៣ដង ហើយ ខ្ញុំមិនហ៊ានទៅជិតទេតែរែកប៉ោតទឹកឈរនៅចម្ងាយប្រហែល ១០ម៉ែត្រចាំស្តាប់ និងឮពាក្យចុងក្រោយមិត្ត ភី សួរថា ហ្អែងស័ក្តិ៥មែនឬអត់? អាគី ដោយឈឺពេកទ្រាំមិនបានក៏ឆ្លើយថា អាណាថាអញស័ក្តិ៥ អញពាក់ស័ក្តិ១០ ហ្អែងមិនជឿហីទៅ កុំវាយអញទៀត មិត្តភី ក៏បន្តនិយាយថា «និយាយអញ្ចឹងទើបត្រឹមត្រូវ» ក្រោយពីសួរចម្លើយហើយពីរម៉ោងគេយកឈ្មោះ គី ទៅសម្លាប់កប់នៅក្បែរដើមស្វែងនៅទិសនិរតី ចម្ងាយ២០០ម៉ែត្រពីមន្ទីរសន្តិសុខៗ

### ៣.៩. បំណងធ្វើអត្តឃាតបែរទៅជាបាត់គ្រុន

អ្វីដែលលំបាកសម្រាប់ខ្ញុំក្នុងពេលនេះគឺរបួសខ្ញុំកាន់តែរីកធំទៅៗពុំមានថ្នាំលាបៗតែដីឥដ្ឋបាតស្រះ ហូរទឹក



ហង្ស ឆាំឆាន ពេលបួសជាព្រះសង្ឃៗ (ហង្ស ឆាំឆាន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

រងែរហាម រហូតដល់ធ្លាក់ខ្លួនទៅជាគ្រុនសន្ធំក្តៅ បើកភ្នែកស្ទើរមិនរួចៗ ពេលខ្ញុំគ្រុនឲ្យបងសុន ទៅសុំពូមឿន អង្គការក៏ព្រមឲ្យសម្រាករហូតដល់ជាសឹមមករែកទឹកវិញៗ ខ្ញុំមិនទម្រន់តាមជំងឺទេចង់ឈ្នះក៏ប្រើក្មេង២នាក់នៅភូមិជាមួយឈ្មោះ ឈិន និង ផល ដែលជាប់គុកដើរសេរីឲ្យទៅកាច់ត្រួយស្ដៅឲ្យបានច្រើនមកច្របាច់ផឹកឲ្យជាគ្រុន ព្រោះគេប្រាប់ថា ថ្នាំគ្រុនពួកខ្មែរក្រហមធ្វើពីស្តៅ គឺថ្នាំអាចម៌ទន្សាយ សព្វថ្ងៃនេះតែកុំផឹកច្រើនពេកអាចពុលងាប់ៗ ប្អូនឈិន និង ផល បានដូចចិត្តទៅកាច់ត្រួយស្ដៅនៅក្បែរនោះបាន២សម្ពាយ យកមកឲ្យ រួចជួយច្របាច់ទឹកឡើងពណ៌ខៀវបាន២កាមែលៗ ឃើញខ្ញុំច្របាច់បានស្តៅ២កាមែលអ្នកខ្លះថា កុំផឹកគ្រោះថ្នាក់

ណាស់អ្នកខ្លះទៀតប្រាប់ថា បើមិនផឹកធ្វើម៉េចជាគ្រុន តែផឹក១កាមែល បានហើយ។ ពេលគេទៅធ្វើការអស់ ខ្ញុំលើក១កាមែលមកផឹករាងល្ងីល្ងើ ដូចជាមិនប្រែប្រួលអ្វីទេ នៅតែក្ដៅបែកញើសដដែល ក៏ដាច់ចិត្តថា បើរាំពុលងាប់ក៏ងាប់ទៅ កុំនៅទាំលំបាកវេទនាទៀត។ គិតហើយលើក១កាមែលទៀតឆ្វេចភ្នែកផឹកទាល់តែអស់ ស្រាប់តែបែកញើសខ្លាយបាត់គ្រុន និងស្នាមរបួសក៏ក្រៀមរហូតដល់ជាសះស្បើយអស់។

## ៣.១០. ការធ្វើអន្តរាគមន៍ពីឪពុកមា

លោកពូ សំ អ៊ំពៅ គឺជាអនុប្រធានសន្តិសុខតំបន់ ២៨ ជាប្អូនពៅរបស់លោកឪពុកធម៌ស៊ូ បានទទួលដំណឹងពីបងគាត់រួចក៏ឆ្មៀតមកសួរនាំពីរឿងខ្ញុំជាមួយមិត្ត ភី ជាប្រធានមន្ទីរសន្តិសុខស្រុកកោះដ័យ។ ម៉ោង២៖៣០នាទីរសៀលពេលខ្ញុំកំពុងបែកញើសនិងជាគ្រុនហើយដេកម្នាក់ឯងក្នុងគុកដោយពុំមានជាប់ខ្នោះ បានឮសំឡេងម៉ូតូចូលមកជួបសន្តិសុខនៅយាមខាងមុខគុកសួររកមិត្តភី។ ខ្ញុំពុំដែលស្គាល់លោកពូ ពៅ ទេពីមុនព្រោះគាត់និងខ្ញុំពុំដែលជួបគ្នាទេ គាត់ឮតែឈ្មោះខ្ញុំជាលោកសង្ឃល្បីខាងទេសនានៅជនបទឯខ្ញុំឮល្បីថាគាត់ជាអ្នកសរសេរកាសែតខ្មែរឯករាជ្យ។ តែសំឡេងគាត់ប្រហែលនឹងសំឡេងលោកឪពុកធម៌ស៊ូ ពេលស្ដាប់គាត់និយាយគ្នាឮៗ និងសួររកមិត្តភី ខ្ញុំចាប់សង្ស័យដែរតែពុំហ៊ានចេញមកក្រៅ ក៏រង់ចាំស្ដាប់ពេលខ្លះឮ ពេលខ្លះមិនឮ។ ចុងក្រោយមិនដឹងជាគាត់និយាយជាមួយអ្នកណាទេថា «បើមិត្តឯងធ្វើបាបក្មួយខ្ញុំដូចជាធ្វើបាបខ្ញុំ បើសង្ស័យពេកទុកឲ្យជាប់សិនទៅ ថ្ងៃណារួចក៏បាន តែកុំឲ្យគ្នាធ្វើការធ្ងន់រហូតដល់គ្រោះថ្នាក់ជីវិត» ពុតែប៉ុណ្ណេះម៉ូតូក៏ចេញដំណើរទៅបាត់។ ខ្ញុំពុំបានទទួលដំណឹងអ្វីទាំងអស់ក្រៅពីប្រឹងធ្វើការលត់ដំខ្លួនដើម្បីរស់ប៉ុណ្ណេះ។ ល្ងាចនោះពេលបាយរួចដល់ពេលដាក់ខ្នោះ មិត្តសារ៉ន មកប្រាប់គេឲ្យទៅប្រាប់ខ្ញុំ និងមិត្តសុនដាក់ខ្នោះតែ ២បានហើយ។ យើងទាំងពីរនាក់អរណាស់ព្រោះជាប់ខ្នោះ ៤មានតែខ្ញុំពីរនាក់បងសុន ក្រៅពីនេះមានតែអ្នកជាប់ខ្នោះ ២ និងខ្នោះ១។ ខ្ញុំមិនដឹងគោលការណ៍គេយ៉ាងម៉េចទេរឿងអ្នកជាប់ខ្នោះច្រើននិងតិចនេះ។

## ៣.១១. បន្ថយខ្នោះនិងដូរទៅស្រោចបន្លែ

ព្រឹកឡើងពូមឿង ហៅខ្ញុំចេញពីដូររួចប្រាប់ថា ឆាន ឯងទៅស្រោចស្ពៃនៅអូរពីងពង់ម្ដង គ្រាន់នឹងបានពេលរកត្រីហូបនឹងគេ។ ពិតមែនតែស្រុកនេះនៅក្បែរភូមិកំណើតតែខ្ញុំមិនដែលមកទេ។ ពេលទៅដល់ចម្ការពីងពង់មានឈ្មោះ ឱម សានិត្យ ជាប្រធាននាំទៅ យើងមានគ្នាចំនួន៣នាក់គឺថែមឈ្មោះ ហេង និង ខ្ញុំ ទៅដល់ចម្ការ សានិត្យ គេប្រាប់ឲ្យខ្ញុំ និង ហេង ស្រោចឆៃថាវ។ ខ្ញុំចាប់ផុងមានផ្កាឈូកបាញ់ទឹកស្រោចដោយយកចិត្តទុកដាក់មុនគេលោកសានិត្យហៅមកណែនាំភ្លាម ឆាន មកនេះខ្ញុំប្រាប់របៀបស្រោច បើស្រោចដូច ឆាន ឯងរកពេលនិយាយគ្នាមិនបានទេ គឺគេដងទឹកពីផុងឲ្យពេញ រួចរត់ឲ្យលឿនពីដើមរងទោះដល់ចុងរងមិនដល់ក៏ហីទៅ កុំស្រោចតទៅទៀតត្រូវស្រោចតែ៤រងបានហើយ ឆាន ឯងព្រឹកនេះ អាហេង ក៏ស្រោចតែ៤រងដែរ ចាំល្ងាចថែម៤រងម្នាក់ទៀត។ ស្រោចហើយមកអង្គុយនិយាយលេងជាមួយខ្ញុំបន្តិចចាំទៅរកត្រី ឬកង្កែបស៊ី ចង់ហូបត្រីឬកង្កែបចាំខ្ញុំប្រាប់។ ក្រោយពីស្រោចឆៃថាវ៤រងមិនដល់កន្លះម៉ោងផងក៏ចប់ការងារ យើងនាំគ្នាអង្គុយនិយាយគ្នាលេង សានិត្យចាប់ផ្ដើមសួរខ្ញុំថា ឆាន ឯងរៀននៅប៉ុន្មានសរហូតដល់ចប់ឬ? ខ្ញុំភ្ញាក់ក៏សួរថាម៉េចបងដឹងថាខ្ញុំរៀននៅសាលាបាលីជាន់ខ្ពស់? រកនឹកមើលទៅខ្ញុំស្គាល់ ឆាន ឯងតាំងពីឃើញ ឆាន់ឯង គេបណ្ដើរមកដល់ តែកុំនិយាយរឿងនោះ ស្គាល់មិនស្គាល់ក៏មិនមានអីសំខាន់ទេ យើងជាប់គុកដូចតែគ្នា។ សំខាន់ទៅចាប់ត្រីស៊ីសិន ចាំខ្ញុំប្រាប់ហើយ នាំគ្នាធ្វើ២នាក់អាហេង ខ្ញុំទៅយកអង្ករមកដាំបាយ។ ដូចពូមឿង ប្រាប់មែនកន្លះខែខ្ញុំមានបាយមានម្ហូបហូបគ្រប់គ្រាន់មានសាច់ឈាមស្រស់ឡើងវិញ។ ស្រាប់តែលោក សានិត្យ ត្រូវបានគេបញ្ជូនចេញពីមន្ទីរសន្តិសុខរួមជាមួយនិងក្រុមគ្រួសារមិត្តហេង៤នាក់ទៀតមិនដឹងជាយកទៅលែង ឬយកទៅសម្លាប់ព្រោះបងស្រីលោក ហេង ជាប្រពន្ធទាហាន។

## ៣.១២. ការជួយដឹកអណ្ដូងជូនសហករណ៍

ព្រឹកឡើងខ្ញុំនិងអ្នកទោសផ្សេងទៀតត្រូវមកតម្រង់ជួរ ឲ្យអង្គការចាត់ឲ្យទៅធ្វើការតាមការដ្ឋានផ្សេងនៅម៉ោង៦ព្រឹក។ ពេលនេះពុំឃើញពូមឿង ទៀតទេមិត្ត សារ៉ន មកចាត់ចែងកម្លាំងម្ដង ខ្ញុំក៏មិនមានចាប់អារម្មណ៍ពីការបាត់មុខពូមឿងទេព្រោះអង្គការមានគ្នាច្រើនគេប្ដូរគ្នាធ្វើការធម្មតារបស់គេ។ ព្រឹកនេះមិត្តសារ៉ន សម្រឹងមកខ្ញុំនិងមិត្តឈ្មោះ ប៉ុមឲ្យទៅជួយជីកអណ្ដូងនៅភូមិពងទឹក។ ភូមិពងទឹកនៅចម្ងាយប្រមាណ៥០០ម៉ែត្រ ខាងជើងមន្ទីរសន្តិសុខស្រុកនៅពេលនោះមិត្ត ឆេង ជាអនុប្រធានភូមិមកទទួលកម្លាំងទៅឲ្យស្គាល់កន្លែងផង និងតាមការពារពួកខ្ញុំកុំឲ្យរត់ផង។ ទៅដល់ទីតាំង

ពួកយើងមានគ្នា៩នាក់ ២នាក់មិនចាំឈ្មោះបានចាប់ផ្តើមធ្វើការជាងមួយសប្តាហ៍ទើបហើយ។ ពេលនោះប្រជាជននៅសហករណ៍គេមិនចាប់អារម្មណ៍ពីការរត់របស់ខ្ញុំទេ ទោះបីជានៅព្រំដែនពុស្នុរការភ្លើងខ្លាំងៗចម្ងាយប្រហែលជាង ១០គីឡូម៉ែត្រយ៉ាងម៉េចក៏ដោយ។ អនុប្រធានភូមិគេបានឲ្យខ្ញុំ២នាក់ទៅហូបបាយនៅសហករណ៍ ហើយពេលនេះខ្ញុំបានជួបលោកឪពុកធម៌ស៊ូនៅសហករណ៍នេះ និងបានទទួលព័ត៌មានថ្មីៗជាពិសេសពីលោកពូពៅ។

## ៣.១៣. ការសម្លាប់អ្នកទោសដោយត្បូងចបនៅក្នុងស្រែកំពុងភ្ជួរ

ចប់ការដឹកអណ្តូងពីសហករណ៍ ខ្ញុំត្រូវបានគេចាត់ឲ្យទៅភ្ជួរដីស្រែខាងលិចមន្ទីរសន្តិសុខចម្ងាយ១០០ម៉ែត្រ ជាមួយអ្នកទោស៦នាក់ទៀតដែលខ្ញុំមិនធ្លាប់ស្គាល់ ពេលពួកខ្ញុំកំពុងភ្ជួរ ប្រហែលម៉ោង៩ មិត្ត ភី បានលីចបទៅកាប់ភ្លឺស្រែក្បែរពួកយើងភ្ជួរ។ អ្នកទោសម្នាក់ជាអតីតទាហាន លន់ នល់ ភ្ជួរពីមុខខ្ញុំស្នៀកខោខ្លីអត់អាវក្រឡេកឃើញមិត្តភី កំពុងកាន់ចបកាប់ដីក្បែរខ្លួន ក៏ភ្ញាក់របូតយាមនង្គ័លពីដៃដួលលុតជង្គង់នៅពីមុខមិត្តភី មិត្តភីក៏វាយនឹងត្បូងចបតែ១ចប ក៏ប្រកាច់ស្លាប់ភ្លាម ដឹងថាស្លាប់ហើយ មិត្តភីប្រាប់ខ្ញុំនិងអ្នកផ្សេងទៀតឲ្យសែងយកទៅកប់។ ពួកខ្ញុំទាំង៧នាក់ស្គមៗពុំសូវមានកម្លាំងកាប់ដីកប់បានជ្រៅទេ គឺបានត្រឹម២តឹកល្មមដាក់សពចូលបានក៏ឈប់ទៅ។ ឯគ្នាគាត់ ៥នាក់ទៀតជាអតីតទាហានដូចគ្នាបានស្រាតខោយកមុននឹងកប់ខ្មោចនោះ ហើយនិយាយថា «អាម៉ាក់អើយឯងបានទៅសោយសុខចោលយើងហើយ គ្នាសុំទោស គ្នានៅក្រោយពុំមានខោស្លៀកទៀតទេ ឲ្យគ្នាសុំខោឯងមកស្លៀកទុកដល់ថ្ងៃស្លាប់ដូចគ្នា» ពួកអ្នកទោសទាំងនោះ សុទ្ធតែស្គមស្បែកដណ្តប់ឆ្អឹងមានតែខោខ្លីស្លៀក គ្មានអាវពាក់ទេ។

## ៣.១៤. ហៅអ្នកទោសត្រកូល ហង្ស ទៅសម្លាប់

ក្រោយចប់ការងាររអណ្តូងរួចល្ងាចនោះខ្ញុំនិងអ្នកទោសផ្សេងទៀតហាក់ដូចជាសប្បាយចិត្តនាំគ្នាជជែកលេងសើចលាន់អឺលពេញគុក។ ម៉ោងប្រហែល៨ មិត្តភី ឡើងមកលើគុករួចស្រែកគំហកពីខាងក្រៅមកថា យើ! ពួកហ្អែងសប្បាយណាស់ឬ? មិនបេះពិចារណាខ្លួនឯងសោះថាខ្លួននៅឯណាឥឡូវនេះ? បន្ទាប់មកមិត្ត សារ៉ន ស្រែកប្រាប់ថាអ្នកទាំងអស់ស្តាល់គ្នាចាំស្តាប់ឈ្មោះ ហង្ស... អ្នកហៅនិយាយថា ហង្សអីទេភ្លេចហើយមើលអ្នកកាន់ពិលយកពិលមកមើលបន្តិចភ្លេចឈ្មោះហើយ។ អ្នកទោសដែលមានត្រកូល ហង្ស៥នាក់គឺ ១) ហង្ស យន្ត ជាប់ខ្នោះនៅក្រោមផ្ទះ ២) ហង្ស ឆាន (ខ្ញុំ) ៣) ហង្ស សុវណ្ណ ៤) ហង្ស មាស និង ៥) ហង្ស សារ៉ាន។

គ្រាន់តែឮឈ្មោះត្រកូល ហង្ស ម្នាក់ៗរកកល់ចង់ខ្យល់គ ព្រោះហៅម៉ោងនេះមានតែហៅចងទៅសម្លាប់។ ពេលអ្នកយកពិលមកបំភ្លឺទើបមិត្តសារ៉ន បញ្ជាក់ថា ហង្ស សារ៉ាន។ សារ៉ានជាអតីតទ័ពខ្មែរក្រហមពិការជើងម្ខាងនៅសមរភូមិកោះពាមរាំង ជាប់ទោសពាដងហើយដោយខុសសីលធម៌ទី៦គឺចាប់រំលោភស្ត្រីភេទ។ មិត្តសារ៉ាន ទៅបាត់ហើយ គាត់បានសុខហើយ នៅតែពួកយើងទេ មិនដឹងជាយ៉ាងម៉េច? កំពុងតែនិយាយស្រាប់តែអ្នកនៅចុងជួរខ្នោះខ្ញុំស្រែកប្រាប់ថាតា...(ខ្ញុំភ្លេចឈ្មោះគាត់) លោកតាមានអាយុ៦០ឆ្នាំ ហើយគាត់ជាប់គុកជាង១ឆ្នាំហើយ ដោយសារនិយាយការពារពុទ្ធសាសនា។ គាត់រាករូសពាថ្ងៃហើយដោយសារគ្រួសារយកអន្សមមួយល្អីមកឲ្យ ក្រោយពេលចូលឆ្នាំ ហូបហើយរាករហូតដាច់ខ្យល់នៅយប់នោះ ការស្រែកនេះបានឮដល់សន្តិសុខកំពុងអង្គុយយាមខាងក្រៅគុក ស្រែកប្រាប់ថាថ្មើរនេះហើយគ្មានកម្លាំងសែងទៅកប់ទេ នាំគ្នាដេកទៅកុំមាត់។ ពុពាក្យនេះម្នាក់ៗសម្ងំឈឹងខំប្រឹងដេករៀងៗខ្លួនពិតមែនស្ងាត់មាត់ តែស្នូរខ្នោះរណ្តំគ្នាដោយសារម្នាក់ៗងើបឡើងដេញការធ្វើទុករបស់សង្កើចចៃ និងកណ្តុររំខាន។ សូមបញ្ជាក់ថា ក្នុងគុកនេះកើតសង្កើចរាប់លាននៅក្នុងរនាបឫស្សីចៃរាប់សែននៅតាមជញ្ជាំង និងកណ្តុររាប់ពាន់ជាប់គុកដែររស់នៅលើស្លាកក្រោមរនាបដែលគេបិតយាំងមិនឲ្យអ្នកទោសខាងលើឲ្យបាយទឹកទៅអ្នកទោសប្រហារជីវិតនៅក្រោមផ្ទះ។ ដោយដេកមិនលក់បងសុនដឹងព័ត៌មានថាមិត្តមឿងគេចាប់ទៅបាត់ ហើយដោយសាររំលោភនារី កុសល ជាអ្នកទោសទើបមកដល់ថ្មី ហើយយកទៅសម្លាប់ថ្មីៗនេះ។ ព័ត៌មានគេថានារី កុសល ជាមេចលនាប្រឆាំងរបបខ្មែរក្រហមនៅអាងទឹកជូរក្នុងសង្កាត់បន្ទាយចក្រី។ នារីកុសល ជានិស្សិតទៅចល័តធ្វើប្រព័ន្ធស្រោចស្រពអាងទឹកជូរ នាងបានធ្វើចលនាជាមួយនារីនិងយុវជនផ្សេងទៀតនៅក្នុងកងចល័តពេលបែកការណ៍ខ្មែរក្រហមបានចាប់នាង និងបក្ខពួក ៦នាក់មកដាក់ខ្នោះក្រោយខ្ញុំកន្លះខែ។ ក្រោយមកពាថ្ងៃគេយកទៅសម្លាប់ទាំង៦នាក់។

កន្លងមកមានលេចឮព័ត៌មានក្នុងគុកថា អ្នកជាប់ទោសជានារីស្អាតៗជាច្រើនត្រូវកម្មាភិបាលក្នុងគុកនេះរំលោភជាពិសេស អ្នកដែលទើបមកដល់ថ្មី ដែលជានារីស្អាត

ហើយពួកវាដឹងថា នាងត្រូវប្រហារជីវិតបើពួកវាឆ្មៀតឱកាសបាន វារំលោភភ្លាមៗ។

### ៣.១៥. ការបះបោរអ្នកទោសគុកពោធិ៍បូរី

ល្ងាចថ្ងៃទី៣០ មេសា ប្រមាណជាម៉ោង៧យប់ឮសូរផ្ទុះកាំភ្លើងយន្តជាច្រើនគ្រាប់ ធ្វើឲ្យពួកអ្នកទោសក្នុងគុក មានការជ្រួលច្របល់ម្នាក់ៗ សុទ្ធតែមានការប្រុងប្រយ័ត្នខ្ពស់ ឯក្រុមសន្តិសុខក៏នៅមិនសុខដែរ តែពួកគេដឹងរឿងដោយសារអ្នករត់ពីសន្តិសុខពោធិ៍បូរី ប្រាប់ថាអ្នកជាប់ទោសពោធិ៍បូរីសម្លាប់សន្តិសុខ និងរត់ចេញពីគុកអស់ហើយ ឥឡូវនេះទ័ពស្រុកកំពុងដេញចាប់អ្នកទោសមកវិញៗ ពោធិ៍បូរីស្ថិតនៅខាងជើងមន្ទីរសន្តិសុខរួមប្រមាណជា២គីឡូម៉ែត្រ ជាគុកដាក់អ្នកទោស២កន្លែងគឺពោធិ៍បូរីខាងត្បូង ពោធិ៍បូរីខាងជើង ប្រគុកយ៉ុងយូយ។ អ្នកទោសជាប់នៅកន្លែងនេះ ៩៥ភាគរយ ជាអតីតទាហាន លន់ នល់។ ព័ត៌មានថាថ្ងៃនោះបុគ្គលិកសន្តិសុខចេញទៅក្រៅស្ទើរតែអស់ពីគុក នៅសល់បុគ្គលិក១០នាក់នៅចាំកន្លែង ចាំយាមនិងដឹកនាំអ្នកទោស១០០នាក់ធ្វើការធម្មតាៗ ដោយសារអ្នកយាមភាគច្រើនជាកូនក្មេង គ្មានបទពិសោធន៍មានការធ្វេសប្រហែស និងឃើញឱកាសល្អហុចឲ្យ។ ម៉ោងប្រមាណជា៣ល្ងាចសន្តិសុខម្នាក់អាយុប្រហែលជា១៥ឆ្នាំ ឈ្មោះ ណេត ឡើងទៅបត់ជើងលើបន្ទន់ព្យួរកាំភ្លើងអាអ៊ែរ១៥ មានចំពុះទុំងភ្ជាប់ជាមួយនៅខាងក្រៅ ទ្វារបន្ទន់។ ឃើញដូច្នេះ អ្នកទោសយើងដែលបានសង្កេតសភាពការណ៍រង់ចាំឱកាស និងបានបែងចែកកម្លាំងតាមមុខព្រួញរួចហើយ បានចាត់ការយ៉ាងរហ័សដូចផ្លេកបន្ទោរ គឺម្នាក់ហក់ឡើងលើបន្ទន់យកកាំភ្លើងតម្រោះចំពុះទុងចាក់មិត្ត ណេត ដែលកំពុងបត់ជើងធំមិនទាន់រួចចំទ្រូងខាងឆ្វេងដាច់ផ្ងារងាប់ភ្លាមនៅនឹងកន្លែង។ ក្រុមកន្លែងផ្សេងទៀតទៅប្រមូលកាំភ្លើងពីឃ្លាំងសន្តិសុខរាប់រយដើម និងសម្លាប់មិត្ត វ៉ន ជាសន្តិសុខអ្នកខ្លះទៀតទៅចាប់ចងសន្តិសុខឲ្យនាំផ្លូវចូលព្រៃព្រែកតាពុត និងទន្លេតូចបានឆ្ងាយ ហើយទើបលែងវិញ។ យោធាស្រុកកោះដ័យមកដល់ម៉ោងជាង៦ហើយ ពេលមកដល់ក៏ប្រកាសប្រាប់ប្រជាជនមិនឲ្យដើរប្រសេចប្រសាចប្រយ័ត្នគ្រោះថ្នាក់គេកំពុងធ្វើការៗ ការប្រកាសប្រាប់បានដឹងតែមួយចំនួននៅជិតគុក ទាំងពីរតែអ្នកនៅឆ្ងាយគុកអត់បានដឹង ក៏ចេញដើរ ត្រូវយោធាស្រុកបាញ់សម្លាប់អស់ជាច្រើននាក់ទៀត។ ទម្រាំយោធាស្រុកមកដល់ស្ដាប់ទៅអ្នកទោសដែលចេញទៅមានកាំភ្លើងគ្រប់ដៃ គ្រប់គ្រាន់ដើរទៅដល់ព្រំដែន និងខ្លះបានប៉ះជាមួយទ័ពខ្មែរក្រហមនៅព្រំដែន និងខ្លះឆ្លងចូលទឹកដីវៀតណាមរួចហើយ។ ក្រោយពីអ្នកទោសដោះលែងឲ្យត្រឡប់មកវិញ កម្មាភិបាល និងបុគ្គលិកសន្តិសុខដែលពាក់ព័ន្ធជាង៣០នាក់ ត្រូវយកទៅសម្លាប់ទាំងអស់ ក្រោមបទឃុបឃិតជាមួយខ្មាំង និងធ្វេសប្រហែស។

## ៤.ការបញ្ជូនអ្នកទោសទៅគុកទួលសំរិត

ព្រឹកថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៧៧ ម៉ោង៧ព្រឹក ខ្ញុំនិងបងសុនរួមនឹងអ្នកទោសផ្សេងទៀតចំនួន១២នាក់ ត្រូវបានបុគ្គលិកសន្តិសុខ២នាក់ នាំទៅស្នាក់ការសន្តិសុខទួលសំរិត ដែលស្ថិតនៅទិសខាងកើតឆ្លងបឹងប្រមាណជា៤គីឡូម៉ែត្រ។ ២គីឡូជុំវិញទួលសំរិត ពុំមានផ្ទះប្រជាជននៅទេ ខាងលិចនិងខាងជើងទួលព័ទ្ធទៅដោយបឹងខាងកើតនិងខាងត្បូងមានផ្ទះប្រជាជននៅឆ្ងាយៗ ជុំវិញគុកនេះ គឺជាវាលស្រែល្វឹងល្វើយរាប់ពាន់ហិកតា។ ក្រោយឆ្លងទូករួចពួកយើងដើរទៅដល់គុកនៅម៉ោង៩ព្រឹក អ្នកទោសនៅក្នុងគុកមានចំនួនសរុប៤៥នាក់ៗ អ្នកទោសភាគច្រើនជាអតីតទាហាន និងមន្ត្រីរដ្ឋការ លន់ នល់ ពេលទៅដល់ភ្លាមប្រធានស្នាក់ការគឺមិត្តចក់ បានបើកការប្រជុំមួយណែនាំពីរបៀបរបបរស់នៅក្នុងគុក និងរបបហូបចុកប្រចាំថ្ងៃរួចក៏ឲ្យពួកយើងទៅរកកន្លែងនៅរៀងៗខ្លួន និងយកចានទៅទទួលបាយ និងសម្លហូប។ អ្វីដែលពួកយើងចាប់អារម្មណ៍នោះគឺ យើងបានហូបបាយមួយចានពេញ និងមានសម្លឆ្ងាញ់គួរសម។ ល្ងាចម៉ោង២ ចុះធ្វើការលើកភ្លឺស្រែ អ្នកទោសអាចដើររកត្រីនៅក្បែរគុកមកស្លហូបបាន មិនសូវជាមានការតឹងតែងប៉ុន្មានទេ។ មួយអាទិត្យក្រោយម៉ោង៣ល្ងាច ខ្ញុំនិងបងសុនជាប្រជាជនថ្មី គេហៅឲ្យទៅសួរចម្លើយលើកទីពីរ ជាមួយប្រជាជនថ្មី២០នាក់ទៀត ដោយគេប្រាប់ថា សួរចម្លើយហើយ អាចរួចទៅផ្ទះបាន។

### ៤.១. ការសួរចម្លើយលើកទីពីរ

អ្នកទោសទាំង២២នាក់ចូលទៅអង្គុយក្នុងបន្ទប់ជាមួយគ្នាអាចស្ដាប់គ្នាបាន ត្រូវបានគេហៅឲ្យចូលម្នាក់ម្ដងៗតាមការស្ម័គ្រចិត្តអ្នកណាចូលមុនក៏បានឲ្យតែប្រជាជនថ្មី។ ការសួរសំណួរលើកទីពីរនេះមិនមានសម្ងតដូចសួរនៅពេលដំបូងទេ គ្រាន់តែសួរខ្ញុំថាមកជាប់ប៉ុន្មានឆ្នាំហើយ និងឲ្យនិយាយពីប្រវត្តិរស់នៅភ្នំពេញក៏ចប់ទៅ ខ្ញុំជាអ្នកទី២២ ចុងក្រោយគេ សួររហូតដល់ម៉ោង៦ល្ងាចទើប

(តទៅលេខក្រោយ)

រូបក្របមុខ ៖
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ (រូបខាងស្តាំ) អមដំណើរដោយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាស្ថាបនិកព្រះរាជបណ្ណាល័យ ហ្វូងម៉ៃ អញ្ជើញជាអធិបតីបិទសន្និសីទលើកទី១ ស្តីពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍»។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ ៖
ប្លង់វិទ្យាស្ថានស្លឹករឹតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា គូរដោយស្ថាបត្យករ ហ្សាហា ហាឌីត។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ៧៨ ៦៩៨ ៣៣៣

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 293, May 2024 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.